**ការាបេស្សាមិ** កិ. [ ករ+ណាបេ+ស្សាមិ.ភ. ] នឹងញុំាង...ឱ្យធ្វើ, នឹងឱ្យធ្វើ ។

**ការិត** គុ. [ ករ+ណេ+ត ] គឺ...ញុំាង...ឱ្យធ្វើហើយ ។ - **ត្ត** នបុំ. ភាវៈនៃ...នោះជា...គឺ...ញុំាង...ឱ្យធ្វើហើយ ។ - **បណ្ណតភាវោ** ឥ. បណ្ណតភាវគឺ...ញុំាង...ឱ្យធ្វើហើយ ។

**ការី** បុំ. [ ករ+ណី ] អ្នកធ្វើ, អ្នកធ្វើដោយប្រក្រតី, អ្នកមានកិ.ធ្វើជាប្រក្រតី; វិ. **ករោតីតិ> ការី, ករោតិ សីលេនាតិ> ការី, កាតុំ សីលមស្សាតិ> ការី** ។

ការុញ្ញតរ គុ. [ ការុញ្ញ+តរ ] ភាវៈនៃករុណាជាង, មានភាវៈនៃសេចក្ដីអាណិតជាង ។

ការុញ្ញតា ឥ. [ ករុណា+ណ្យ+តា.ស. ] ភាវៈនៃសេចក្ដីករុណា, ភាវៈនៃសេចក្ដីអាណិត; វិ. **ករុណាយ ភាវោ> ការុញ្ញំ, ការុញ្ញំ ឯវ> ការុញ្ញតា** ។

ការុញ្ញវស បុំ. [ ការុញ្ញ+វស ] អំណាចនៃភាវៈនៃសេចក្ដីករុណា ។

ការេតុ កិ. [ ករ+ណេ+តុ.ក. ] ចូរញុំាង...ឱ្យធ្វើ ។

ការេតុកាម គុ. [ ការេតុំ+កាម+ណ ] អ្នកចង់ដើម្បីញុំាង...ឱ្យធ្វើ ។

ការេតុំ អ. [ ករ+ណេ+តុំ. ] ដើម្បីញុំាង...ឱ្យធ្វើ ។

ការេន្តិ កិ. [ ករ+ណេ+អន្តិ.វ. ] ញុំាង...ឱ្យធ្វើ ។

ការេន្ត គុ. [ ករ+ណេ+អន្ត ] កាលញុំាង...ឱ្យធ្វើ ។

ការេមិ កិ. [ ករ+ណេ+មិ.វ. ] ញុំាង...ឱ្យធ្វើ ។

ការេយ្យុំ កិ. [ ករ+ណេ+ឯយ្យុំ.ស. ] គប្បីញុំាង...ឱ្យធ្វើ ។

ការេសិ កិ. [ ករ+ណេ+ឦ.អជ្ជ., ចុះស.អា. ] ញុំាង...ឱ្យធ្វើហើយ ។

ការេស្សថ កិ. [ ករ+ណេ+ស្សថ.ភ. ] នឹងញុំាង...ឱ្យធ្វើ ។

ការេស្សំ កិ. [ ករ+ណេ+ស្សំ.ភ. ] នឹងញុំាង...ឱ្យធ្វើ ។

កាល បុំ. [ កល+ណ ] (បរិច្ឆេទ) ដែលជនគប្បីរាប់ ដោយន័យថា កាលមានប្រមាណប៉ុណ្ណោះកន្លងទៅហើយដូច្នេះជាដើម ឬ



(បរិច្ឆេទ) ដែលញុំាងអាយុនៃសត្វឱ្យអស់ទៅ (កាល, ពេល, សម័យ, សេចក្ដីស្លាប់); វិ. **ឯត្តកោ អតិក្កន្តោតិអាទិនា កលីយតិ សង្ខាយតីតិ> កាលោ, សត្តានំ អាយុំ កលយតិ ខេបេតីតិ វា> កាលោ** ។ . កត គុ. អ្នកមានកាលៈធ្វើហើយ, អ្នកមានមរណកាលធ្វើហើយ; វិ. **កាលោ កតោ យេន សោ> កាលកតោ** ។ អ្នកគឺកាលៈ (សេចក្ដីស្លាប់) ធ្វើហើយ, អ្នកគឺមច្ចុឱ្យវិនាសហើយ; វិ. **កាលេន មច្ចុនា កតោ នាសិតោតិ> កាលកតោ** ។ . កតភាវ បុំ. ភាវៈនៃ...នោះជាអ្នកមានកាលៈធ្វើហើយ, ភាវៈនៃ...នោះជាអ្នកគឺកាលៈធ្វើហើយ ។ . កិរិយា ឥ. កិ.ធ្វើនូវកាលៈ, កិ.ធ្វើនូវមរណកាល ។ . អច្ចយ បុំ. សម័យជាទីប្រព្រឹត្តកន្លងទៅនៃកាល; វិ. **អច្ចេន្តិ ឯត្ថាតិ> អច្ចយោ, កាលស្ស អច្ចយោ> កាលច្ចយោ** ។ . ប្បវេទន នបុំ. កិ.ញុំាង...ឱ្យដឹងច្បាស់នូវកាល, កិ.សម្ដែងនូវកាល ។ . ភេទ បុំ. សេចក្ដីផ្សេងនៃកាល ។

កាលស្សេវ និ. អំពីកាលដែលពិត, អំពីព្រឹក, អំពីព្រលឹម ។

កាលានុកាល បុំ. [ កាល+អនុកាល ] កាលប្រព្រឹត្តតាមនូវកាល, កាលដ៏សមគួរដល់កាល, មួយដងមួយកាល ។

កាលិ អា.ឥ. ម្នាលទាសីឈ្មោះកាលី ។ ប្រើជា កាឡិ ក៏បាន ។

កាលិង្គរដ្ឋ នបុំ. [ កាលិង្គ+រដ្ឋ ] ដែនឈ្មោះកាលិង្គៈ ។

កាលីទាសី ឥ. [ កាលី+ទាសី ] ទាសីឈ្មោះកាលី, ខ្ញុំស្រីឈ្មោះកាលី ។

**កាលិយក្ខិនី** ឥ. [ កាលិ+យក្ខិនី ] យក្ខិនីឈ្មោះកាលី, មេយក្សឈ្មោះកាលី ។

**កាស** ពុំ. [ កាស+អ ] កិ.ក្អក, រោគក្អក ។

**កាសាយ** នពុំ. [ កសាយ+ណ ] សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់ (សំពត់កាសាយៈ); វិ. **កសាយេន រត្តំ> កាសាយំ** ។ . **និវត្ថ** គុ. (<និ+វស+ត) អ្នកស្លៀកនូវសំពត់កាសាយៈ, អ្នកស្លៀកនូវសំពត់ដែលជនជ្រលក់ហើយដោយទឹកចត់; វិ. **កាសាយំ និវាសេតីតិ> កាសាយនិវត្ថោ** ។ អ្នកបានសំពត់កាសាយៈស្លៀកហើយ; វិ. **កាសាយំ និវត្ថំ យេន សោ> កាសាយនិវត្ថោ** ។ . **បដិច្ឆន្ន** គុ. គឺសំពត់កាសាយៈបិទបាំងហើយ, បានសំពត់កាសាយៈបិទបាំងហើយ, ដ៏បិទបាំងហើយដោយសំពត់កាសាយៈ ។ . **វត្ថនិវត្ថ** គុ. ស្លៀកនូវសំពត់កាសាយៈ, ស្លៀកនូវសំពត់ដែលជ្រលក់ហើយដោយទឹកចត់ ។ . **វត្ថ** នពុំ. សំពត់កាសាយៈ, សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់ ។

**កាសាវ** នពុំ. [ កសាវ+ណ ] សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់, (សំពត់កាសាវៈ); វិ. **កសាវេន រត្តំ> កាសាវំ** ។ . **កណ្ឋ** គុ. មានសំពត់កាសាវៈពួដ៏ក, បានកព័ទ្ធព័ទ្ធហើយដោយសំពត់កាសាវៈ ។ . **កោដិ** ឥ. ទីកំផុតនៃសំពត់កាសាវៈ, ចុងនៃសំពត់កាសាវៈ ។ . **ធរ** គុ. អ្នកទ្រទ្រង់នូវសំពត់កាសាវៈ; វិ. **កាសាវំ ធារេតីតិ> កាសាវធរោ** ។

**កាសិក** គុ. [ កាសិ+ណិក ] អ្នកនៅក្នុងដែនកាសី, កើតក្នុងដែនកាសី ។



. **កោសលរដ្ឋ** នពុំ. ដែនឈ្មោះកាសីនិងដែនឈ្មោះកោសល ។ . **គាមក** ពុំ. ស្រុកតូចឈ្មោះកាសិកៈ ឬស្រុកតូចតាំងនៅក្នុងដែនកាសី ។ . **គាម** ពុំ. ស្រុកឈ្មោះកាសិកៈ ឬ ស្រុកតាំងនៅក្នុងដែនកាសី ។ . **វត្ថ** នពុំ. សំពត់ដែលកើតក្នុងដែនកាសី, សំពត់ដែលជននាំមកអំពីដែនកាសី ។ . **រាជ** ពុំ. ស្តេចក្នុងដែនកាសី ។ . **បុរ** នពុំ. បុរីនៃស្តេចនៅក្នុងដែនកាសី, ក្រុងឈ្មោះកាសី ។

**កាសិត្វា** អ. [ កាស+ឥ_អា+ត្វា ] ក្អកហើយ ។

**កាហាសិ** កិ. [ ករ+អ+ស្សតិ_ភ., ផ្លាស់ក>កាហ, លុបស្សប្តូរតិជាសិ ] នឹងធ្វើ ។

**កាហាមិ** កិ. [ ករ+អ+ស្សាមិ_ភ. ] នឹងធ្វើ (រូបសិទ្ធិដូច កាហាសិ) ។

**កាឡ** គុ. [ កឡ+ណ ] សភាវៈពោះបង់នូវពណ៌ស (ខ្មៅ, ពណ៌ខ្មៅ); វិ. **កឡតិ សុក្កន្តិ> កាឡោ , កាឡោ ឯវ> កាឡកោ** ។ . **កណ្ណី** អ.ឥ. ឈ្មោះមេកាឡកណ្ណី(ម្នាយស្រីអ្នកធ្វើនូវទីនៅនៃខ្លួនឱ្យទៅជាទីមានសម្បុរខ្មៅ, ម្នាយមេចង្រៃ) ។ . **កណ្ណិក** គុ. ជាកាឡកណ្ណី ។ . **ចម្ម** នពុំ. ស្បែកខ្មៅ, ស្បែកមានពណ៌ខ្មៅ ។ . **ត្ថេរវត្ថុ** នពុំ. រឿងនៃព្រះថេរៈឈ្មោះកាឡៈ ។ . **មត្តិកា** ឥ. បានដីបានពណ៌ខ្មៅ, ដីខ្មៅ, ដីស្អិតមានពណ៌ខ្មៅ ។ . **វណ្ណ** គុ. បានពណ៌ខ្មៅ ។ . **សិលាបទេស** ពុំ. ប្រទេសឈ្មោះកាឡសិលា ។ . **សីហ** អ.ន. ប្រទេសឈ្មោះកាឡសីហៈ, ភូមិឈ្មោះកាឡសីហៈ ។

**កាឡក** គុ. [ កាឡ+ណេក ឬក.ស. ] វត្ថុមានពណ៌ខ្មៅ, ធម៌មានពណ៌ខ្មៅ ។

**កាឡាយមត្ត** គុ. [ កាឡាយ+មត្ត ] មានសណ្តែកខ្មៅជាប្រមាណ, ប៉ុនសណ្តែកខ្មៅ ។

**កាឡី** ឥ. [ កាឡ+ឦ ] មានពណ៌ខ្មៅ, ស្រីមានសម្បុរខ្មៅ ។

**កាឡុទាយិត្ថេរ** ចុំ. [ កាឡុទាយិ+ថេរ ] ព្រះថេរៈឈ្មោះកាឡុទាយិ ។

**កិកិ** អ.ន. ឈ្មោះកិកិ ។

**កិច្ច** នចុំ. [ ករ+រិច្ច ] កម្មគឺបុគ្គលគប្បីធ្វើ (កិច្ច); វិ. **កាតព្វន្តិ> កិច្ចំ** ។ -**បរិយោសាន** នចុំ. កាលជាទីបំផុតចុះជុំវិញនៃកិច្ច, កាលជាទីចប់នៃកិច្ច, កាលជាទីស្រេចហើយនៃកិច្ច ។

**កិច្ចាកិច្ច** នចុំ. [ កិច្ច+អកិច្ច ] កិច្ច និងមិនមែនកិច្ច (អ<ន=ប្រែថា «មិនមែន»), កិច្ចនិងកិច្ចដ៏ចំរើន (អ=ប្រែថា«ចំរើន»), កិច្ចតូចនិងកិច្ចធំ(អ=ប្រែថា«ធំ») ។

**កិច្ឆ** គុ. [ កិរ+ឆ ] ធម្មជាតបោះបង់នូវសេចក្ដីសុខ (ក្រ, លំបាក, ត្រដាបត្រដួស); វិ. **កិរតិ សុខន្តិ> កិច្ឆំ** ។ (កិច្ឆ<កិត+ឆ) ធម្មជាតជាគ្រឿងលំបាក; វិ. **កិច្ឆតិ កាយ កិលមតីតិ> កិច្ឆា** ។ -**ជីវិក** គុ. អ្នកមានកិ.រស់នៅដោយលំបាក; វិ. **ជីវនំ> ជីវោ, កិច្ឆេន ជីវោ> កិច្ឆជីវោ, កិច្ឆជីវោ យស្ស អត្ថីតិ> កិច្ឆជីវី, កិច្ឆជីវី ឯវ> កិច្ឆជីវិកោ** ។



**កិច្ឆាធិគត** គុ. [ កិច្ឆ+អធិគត ] គឺ...បានហើយដោយលំបាក, -ដោយកម្រ ។

**កិញ្ចន** នចុំ. [ កិច+យុ, ចុះនិ.អក. ] កិលេសជាតជាគ្រឿងកង្វល់, កិលេសជាតជាគ្រឿងញាំញី; វិ. **កិញ្ចតិ ឯតេនាតិ> កិញ្ចនំ** ។ សេចក្ដីខ្វល់, កង្វល់; វិ. **កិញ្ចិយតេតិ> កិញ្ចនំ** ។

**កិញ្ចាបិ** និ. [ កឹ+ច+អបិ ] ប្រាកដមែនហើយ, ក៏មែនហើយ, ក៏ពិតមែនហើយ, សូម្បីតិចតួច ។

**កិញ្ចិ** វិ.ស.អ. [ កឹ+ចិ ] តិចតួច, អ្វីៗ, និមួយ,... ។

**កិដាគិរិ** ចុំ. ភ្នំឈ្មោះកិដា ។

**កិដ្ឋ** នចុំ. [ កស+ត ] ធញ្ញជាតដែលកើតអំពីកិ.ភ្ជួរ (សំទូង, សំណាប); វិ. **កសិតោ សម្ភូតំ> កិដ្ឋំ** ។ -**ខាទកីគោណោ** ចុំ. គោទំពាស៊ីនូវសំទូង ។ -**សម្ពាធ** គុ. ដ៏ចង្អៀតដោយសំទូង, ដែលតាន់តាប់ដោយសំទូង, -ដោយសំណាប ។

**កិតវ** ចុំ. [ កិត+អវ ] អ្នកលេង, គ្រឿងបិទបាំង ។

**កិត្តក** គុ. [ កិត្ត+ក ] មានប្រមាណប៉ុន្មាន, ប៉ុន្មាន; វិ. **កិត្តានិ បរិមាណានិ ឯតស្សាតិ> កិត្តកំ** ។

**កិត្តាវតា** និ. ដោយហេតុមានប្រមាណប៉ុន្មាន, ដោយហេតុមានប៉ុន្មាន ។

**កិត្តិ** ឥ. [ កិត+តិ ] វាចាជាគ្រឿងសម្ដែង (សេចក្ដីសរសើរ, កេរ្តិ៍ឈ្មោះ); វិ. **កិត្តេតិ ឯតាយាតិ> កិត្តិ** ។ -**វណ្ណភណន-**

**សង្ខាត** គុ. ពោលគឺកិរិយាពោលនូវគុណាគឺបុគ្គលគប្បីពណ៌នា គឺសេចក្ដីសរសើរ, ពោលគឺកិរិយាពោលនូវកេរ្តិ៍ឈ្មោះនិងសេចក្ដីសរសើរ ។

**កិត្តេន្ត** គុ. [ កិត+ណេ+អន្ត ] កាលសម្ដែង ។

**កិន្តិ** និ. [ កឹ+ឥតិ ] ថាអ្វី, ថាដូចម្ដេច ។

**កិបិល្លិក** បុំ. ស្រមោចក្រហម(ស្រមោចភ្លើង, អង្ក្រង) ។

**កិមង្គំ** និ. [ កឹ+អង្គំ ] នឹងបាច់ពោលទៅថ្វី, ចាំបាច់និយាយទៅថ្វី(ពាក្យមានអ្វីជាហេតុ) ។

**កិមត្ថំ** និ. ដើម្បីអ្វី ។

**កិមត្ថ** បុំ. [ កឹ+អត្ថ ] ប្រយោជន៍អ្វី, គុ. មានអ្វីជាប្រយោជន៍ ។

**កិមិល** អ.ន. សក្យៈឈ្មោះកិមិលៈ ។

**កិរ** និ. ឮថា, បានឮថា, មានសេចក្ដីតំណាលថា ។

**កិរិយវាទ** បុំ. [ កិរិយ+វាទ ] អ្នកពោលថាកម្មគឺបុគ្គលធ្វើហើយឈ្មោះថាគឺបុគ្គលធ្វើ, អ្នកមានលទ្ធិជាគ្រឿងពោលថា កម្មឈ្មោះថាគឺបុគ្គលធ្វើ ។

**កិរិយា** ឥ. [ ករ+រិយ ] ធម្មជាតិដែលជនគប្បីធ្វើ; វិ. **កាតព្វាតិ> កិរិយា** ។ នបុំ. កិ.ធ្វើ, ដំណើរធ្វើ; វិ. **ករីយតេតិ> កិរិយំ** ។

**កិលញ្ជ** បុំ. [ កិល+ជន+ក្វិ ] កន្ទេល, កន្ទេលផែង ។



**កិលន្ត** គុ. [ កិលម+ត ] លំបាកហើយ, នឿយហត់ហើយ ។ - **កាយ** គុ. មានកាយលំបាកហើយ, មានកាយនឿយហត់ហើយ; វិ. **កិលន្តោ កាយោ យស្ស សោ> កិលន្តកាយោ** ។ - **ភាវ** បុំ. ភាវៈនៃ...ជាអ្នកលំបាកហើយ ។ - **សរីរ** គុ. អ្នកមានសរីរៈហត់នឿយហើយ ។ - **រូប** គុ. មានរូបលំបាកហើយ ។ - **ឥន្ទ្រិយ** គុ. មានឥន្ទ្រិយលំបាកហើយ ។

**កិលមតិ** កិ. [ កិលម+អ+តិ.វិ. ] លំបាក, នឿយ ។

**កិលមថ** បុំ. [ កិលម+ថ ] សេចក្ដីលំបាក, សេចក្ដីនឿយ; វិ. **កិលមនំ> កិលមថោ** ។

**កិលមន** នបុំ. [ កិលម+យុ ] សេចក្ដីលំបាក; វិ. **កិលមិយតេតិ> កិលមនំ** ។ - **កិច្ច** នបុំ. កិច្ចគឺសេចក្ដីលំបាក, កិច្ចដោយសេចក្ដីលំបាក ។ - **ភាវ** បុំ. ភាវៈនៃសេចក្ដីលំបាក, ភាវៈគឺសេចក្ដីលំបាក ។

**កិលមន្ត** គុ. [ កិលម+អ+អន្ត ] កាលលំបាក, កាលនឿយហត់ ។

**កិលមន្តិ** កិ. [ កិលម+អ+អន្តិ.វ. ] លំបាក, នឿយហត់ ។

**កិលមិស្សថ** កិ. [ កិលម+អ+ឥ.អា.+ស្សថ.ភ. ] នឹងលំបាក, នឹងនឿយហត់ ។

**កិលមេន្តិ** កិ. [ កិលម+ណេ+អន្តិ.វ. ] ញុំាង...ឱ្យលំបាក, ... ។

**កិលិដ្ឋ** គុ. [ កិលិស+ត ] សៅហ្មងហើយ, កខ្វក់ហើយ, ។ - **កម្ម** នបុំ.

កម្មដ៏សៅហ្មង, អំពើដ៏សៅហ្មង ។ - **គត្ត** គុ. មានខ្លួនសៅហ្មងហើយ ។ - **តរ** គុ. ជាអ្នកសៅហ្មងជាង, ជាអ្នកគឺ...ឱ្យសៅហ្មងជាង ។ - **និវាសនបារុបន** គុ. មានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់សៅហ្មងហើយ, មានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់គឺធូលីឱ្យសៅហ្មងហើយ ។ - **វត្ថ** នថុំ. សំពត់សៅហ្មងហើយ, សំពត់គឺធូលីឱ្យសៅហ្មងហើយ ។

**កិលិន្នបយោស** ថុំ. [ កិលិន្ន+បយោស ] បាយបាយាសដ៏ជ្រាយ, បាយាសដ៏ជ្រាយ (**កិលិន្ន**<កិលិទ+ត, ត>ន្ន) ។

**កិលិស្សតិ** គិ. [ កិលិស+យ+តិ.វ. ] សៅហ្មង ។

**កិលិស្សេយ្យ** គិ. [ កិលិស+យ+ឯយ្យ.ស. ] គប្បីសៅហ្មង, គប្បីឱ្យសៅហ្មង ។

**កិលេស** ថុំ. [ កិលិស+ណ ] ធម៌ជាគ្រឿងសៅហ្មង (កិលេស); វិ. **កិលិស្សន្តិ ឯតេហីតិ> កិលេសា** ។ - **កាម** ថុំ. កិលេសកាម, សេចក្ដីប្រាថ្នាដោយអំណាចនៃកិលេស ។ - **ចោរ** ថុំ. ចោរគឺកិលេស ។ - **ជយ** ថុំ. កិ.ឈ្នះនូវកិលេស ។ - **ទរ** ថុំ. សេចក្ដីក្រវល់ក្រវាយគឺកិលេស, សេចក្ដីក្រវល់ក្រវាយដោយអំណាចនៃកិលេស ។ - **ធុត្ត** គុ. ទីដែលបុគ្គលទៅបានដោយលំបាកគឺកិលេស (ធុត្ត<ធុ+តប+រ; វិ. **ធុត្តេន គមិយតេតិ> ធុត្តំ**) ។ - **និព្វាន** នថុំ. កិលេសនិព្វាន, កិ.រលត់នៃកិលេស ។ - **បរិនិព្វាន** នថុំ. កិលេសបរិនិព្វាន, កិ.រលត់ជុំវិញនៃកិលេស, កិ.រលត់ស្និទ្ធនៃកិលេស ។ - **ពន្ធ** នថុំ. វត្ថុជាគ្រឿងចងគឺកិលេស, ចំណង



គឺកិលេស ។ - **ពន្ធនាភាវ** ថុំ. កិ.មិនមាននៃវត្ថុជាគ្រឿងចងគឺកិលេស, កិ.មិនមាននៃចំណងគឺកិលេស (ពន្ធន+អភាវ) ។ - **ភយ** នថុំ. ភ័យគឺកិលេស, ភ័យកើតអំពីកិលេស ។ - **មយ** គុ. ដែលកើតអំពី កិលេស ។ - **មល** នថុំ. មន្ទិលគឺកិលេស ។ - **មារសង្ខាត** គុ. គឺបណ្ឌិតពោលថាមារគឺកិលេស, ពោលគឺមារគឺកិលេស, ពោលថាមារគឺកិលេស ។ - **មារ** ថុំ. មារគឺកិលេស ។ - **រតិ** ឥ. សេចក្ដីត្រេកអរក្នុងកិលេស, សេចក្ដីត្រេកអរដោយអំណាចនៃកិលេស ។ - **វដ្ដ** នថុំ. វដ្ដៈគឺកិលេស ។ - **វន** នថុំ. ព្រៃគឺកិលេស, កិលេសដូចជាព្រៃ ។ - **វនថ** គុ. ដើមឈើតាំងនៅក្នុងព្រៃគឺកិលេស, កិលេសដូចជាឈើតាំងនៅក្នុងព្រៃ ។ - **វូបសមននិព្វានរតិ** ឥ. សេចក្ដីត្រេកអរក្នុងព្រះនិព្វានជាទីញ៉ាំងកិលេសឱ្យចូលទៅរម្ងាប់, សេចក្ដីត្រេកអរក្នុងនិព្វានជាទីចូលទៅរម្ងាប់នូវកិលេស ។ - **សង្កិលិដ្ឋ** គុ. ដែលគ្រឡូកគ្រឡំដោយកិលេស ។ - **សន្តត្ត** គុ. អ្នកក្ដៅក្រហាយព្រោះកិលេស,អ្នកក្រហល់ក្រហាយព្រោះកិលេស, អ្នករសាប់រសល់ព្រោះកិលេស ។ - **អាទិមលេវិរហិត** គុ. ដែលប្រាសហើយចាកមន្ទិលមានកិលេសជាដើម, ដែលវៀរហើយចាកមន្ទិលមានកិលេសជាដើម ។ - **ឧបសម** ថុំ. ជាទីចូលទៅរម្ងាប់នូវកិលេស, ជាទីញ៉ាំងកិលេសឱ្យចូលទៅរម្ងាប់, ជាទីស្ងប់នៃកិលេស ។

**កិលេសេតិ** គិ. [ កិលិស+ណេ+តិ.វ. ] ញ៉ាំង...ឱ្យសៅហ្មង ។

**កិលេសោឃ** ថុំ. [ កិលេស+ឱឃ ] អន្លង់គឺកិលេស, ធម៌ដូចជាអន្លង់គឺ

កិលេស, កិលេសដូចជាអន្លង់ ។

**កិស** គុ. [ កិស+អ ] ស្គម ។ - **សរីរតា** ឥ. ភាវៈនៃ....នោះជាអ្នកមានសរីរៈស្គម; វិ. **កិសំ សរីរំ យស្ស សោ> កិសសរីរោ, តស្ស ភាវោ> កិសសរីរតា** ។

**កិសាគោតមី** អ.ន. កុមារិកាឈ្មោះកិសាគោតមី ។ - **វត្ថុ** នពុំ. រឿងនៃកុមារិកាឈ្មោះកិសាគោតមី ។

**កិស្មិញ្ចិបិ** វិ.ស.អ. [ កឹ+ស្មឹ+ចិ+បិ ] សូម្បីអ្វីៗ, សូម្បីតិចតួច,... ។

**កឹ** និ. ឬ, អី., ដូចម្ដេច, ប្រយោជន៍អ្វី ។

**កឹអគ្ឃនក** គុ. [ កឹ+អគ្ឃន+ក ] មានតម្លៃប៉ុន្មាន; វិ. **កឹ អគ្ឃនំ យស្ស សោ> កឹអគ្ឃនកោ** ។

**កឹការណា** នពុំ. [ កឹ+ការណា ] ហេតុដូចម្ដេច, ហេតុអ្វី ។

**កឹកណិកជាលា** ឥ. [ កឹកណិក+ជាល ] បណ្ដាញនៃកណ្ដឹង ។

**កឹនានាករណា** គុ. [ កឹ+នានាករណ ] មានអ្វីជាគ្រឿងធ្វើផ្សេងៗគ្នា, មានអំពើផ្សេងៗគ្នាដូចម្ដេច ។

**កឹនាម** និ. ឈ្មោះអ្វី, ឈ្មោះដូចម្ដេច ។

**កឹនុខោ** និ. អ្វីហ្ន៎, ដូចម្ដេចហ្ន៎, ព្រោះហេតុអ្វីអេះ ,... ។

**កឹសមាចារ** គុ. [ កឹ+សមាចារ ] អ្នកមានសមាចារៈដូចម្ដេច, អ្នកមានអ្វីជាសមាចារៈ, អ្នកមានមារយាទដូចម្ដេច, អ្នកមានមារយាទជាគ្រឿងប្រព្រឹត្តល្អដូចម្ដេច ។



**កឹសីល** គុ. [ កឹ+សីល ] អ្នកមានសីលដូចម្ដេច, អ្នកមានអ្វីជាសីល; វិ. **កឹ សីលំ យេសំ តេ> កឹសីលា** ។

**កីដ** ពុំ. [ កិដ+ណ ] កណ្ដូប (ដង្កូវ) ។

**កីទិស** គុ. [ កឹ+ទិស+អ ] ដូចជាអ្វី, ប្រាកដដូចម្ដេច, ប្រាកដយ៉ាងណាទៅ ។

**កីវទូរ** គុ. [ កីវ+ទូរ ] ឆ្ងាយប៉ុន្មាន, ចម្ងាយប៉ុន្មាន, ចម្ងាយប៉ុន្មានទៅ ។

**កីឡតិ** គិ. [ កីឡ+អ+តិ.វ. ] លេង, ប្រឡែង ។

**កីឡន** នពុំ. [ កីឡ+យុ ] ជាទីលេង, កិ.លេង; វិ. **កីឡតិ ឯត្ថាតិ> កីឡនំ, កីឡយតេតិ> កីឡនំ** ។ - **កាល** ពុំ. កាលជាទីលេង ។ - **អត្ថ** ពុំ. ប្រយោជន៍ដល់កិ.លេង, ត្រូវការដល់កិ.លេង ។

**កីឡន្តិ** គិ. [ កីឡ+អ+អន្តិ.វ. ] លេង ។

**កីឡន្ត** គុ. [ កីឡ+អន្ត ] កាលលេង, កំពុងលេង ។

**កីឡមាន** គុ. [ កីឡ+មាន ] កាលលេង, កំពុងលេង ។

**កីឡាបយមាន** គុ. [ កីឡ+ណាបយ+មាន ] កាលញុំាង...ឱ្យលេង ។

**កីឡាបេតិ** គិ [ កីឡ+ណាបេ+តិ.វ. ] ញុំាង...ឱ្យលេង ។

**កីឡាមណ្ឌល** នពុំ. [ កីឡា+មណ្ឌល ] មណ្ឌលជាទីលេង, មណ្ឌលនៃកីឡា ។

**កីឡិត** គុ. [ កីឡ្+ឥ-អា.+ត ] គឺ...លេងហើយ ។

**កីឡិតព្វ** គុ. [ កីឡ្+ឥ-អា+តព្វ ] គឺ...គប្បីលេង ។

**កីឡិតុំ** អ. [ កីឡ្+ឥ-អា.+តុំ ] ដើម្បីលេង ។

**កីឡិតុកាម** គុ. [ កីឡិតុំ+កម+ណ ] អ្នកចង់ដើម្បីលេង, អ្នកចង់លេង ។

**កីឡិត្វា** អ. [ កីឡ្+ឥ-អា+ត្វា ] លេងហើយ ។

**កីឡិស្សតិ** កិ. [ កីឡ្+អ+ស្សតិ-ភ., ចុះឥ-អា. ] នឹងលេង ។

**កីឡិត្វ** អ. [ កីឡ្+អ+ឪ-អដ្ឋ. ] លេងហើយ ។

**កុក្កុច្ច** នបុំ. [ កុកត+ណ្យ ] ភាវៈនៃកម្មដែលបុគ្គលធ្វើហើយគួរខ្ពើម (សេចក្ដីក្ដៅក្រហាយ, សេចក្ដីសង្ស័យ, សេចក្ដីរង្កៀស); វិ. **កុកតស្ស ភាវោ> កុក្កុច្ចំ** ។ - **មត្ត** គុ. កម្មត្រឹមតែសេចក្ដីសង្ស័យ, ហេតុគ្រាន់តែសេចក្ដីរង្កៀស ។

**កុក្កុច្ចាយន្ត** គុ. [ កុក្កុច្ច+អាយ+អន្ត ] កាលប្រព្រឹត្តនូវសេចក្ដីសង្ស័យ, កាលប្រព្រឹត្តនូវសេចក្ដីរង្កៀស (កាលសង្ស័យ, កាលរង្កៀស) ។

**កុក្កុច្ចាយិត្វា** អ. [ កុក្កុច្ច+អាយ+ឥ-អា.+ត្វា ] ប្រព្រឹត្តនូវសេចក្ដីសង្ស័យហើយ, ប្រព្រឹត្តនូវសេចក្ដីរង្កៀសហើយ (សង្ស័យហើយ, រង្កៀសហើយ) ។

**កុក្កុដ** បុំ. [ កុ+កុដ+អ ] សត្វកាយនូវផែនដី ឬ ក្ដាប់នូវដី (មាន់); វិ.



**កុំ បឋវឹ កុដតីតិ> កុក្កុដោ** ។ ម្យ៉ាងទៀត (<កុក+អដ) សត្វតែងកាន់យកនូវចំណី; វិ. **កុកតិ គោចរមាទទាតីតិ ចា> កុក្កុដោ** ។ - **អណ្ឌខាទិកា** ឥ. អ្នកចំពាស៊ីនូវពងនៃមាន់; វិ. **កុក្កុដណ្ឌានិ ខាទតីតិ> កុក្កុដណ្ឌខាទិកា** ។ - **អណ្ឌខាទិកវត្ថុ** នបុំ. រឿងនៃកុមារិកាអ្នកចំពាស៊ីនូវពងនៃមាន់ ។ - **មិត្តវត្ថុ** នបុំ. រឿងនៃនេសាទឈ្មោះកុក្កុដមិត្ត ។ - **វតីនគរ** នបុំ. នគរឈ្មោះកុក្កុដវតី ។ - **សិខ** នបុំ. រយនៃមាន់ ។ - **សេដ្ឋី** បុំ. សេដ្ឋីឈ្មោះកុក្កុដៈ ។ - **អារាម** បុំ. អារាមឈ្មោះកុក្កុដៈ ។

**កុក្កុដី** ឥ. [ កុក្កុដ+អី ] មេមាន់ ។

**កុក្កុរ** បុំ. [ កុក+ឧរ ] (សត្វ) ចាប់នូវប្រើគហេនមន្ទ្រាយជាដើម (ឆ្កែ); វិ. **កុកតិ សសាមិយោ អាទទាតីតិ> កុក្កុរោ** ។

**កុក្កុល** បុំ. [ កុក្កុ+លេ+អ ] (សភាវៈ) កាត់នូវដៃ (ផេះក្ដៅ); វិ. **កុក្កុំ ហត្ថំ លុនាតិ ឆិន្ទតីតិ> កុក្កុលោ** ។ - **សទិស** គុ. ប្រាកដស្មើដោយផេះក្ដៅ ។

**កុច្ឆិ** ឥ. [ កុស+ឆិ, ស>ច ] ផ្ទៃ, ពោះ; វិ. **កុស្សិយតិ អក្កោសិយតីតិ> កុច្ឆិ** ។ - **គត** គុ. ទៅហើយក្នុងផ្ទៃ (តាំងនៅក្នុងផ្ទៃ) ។ - **ទាហ** បុំ. សេចក្ដីក្ដៅក្រហាយក្នុងផ្ទៃ, កិ.រោលរាលក្នុងផ្ទៃ ។ - **បូរមត្ត** គុ. អាហារគ្រាន់តែពេញក្នុងផ្ទៃ, អាហារត្រឹមតែកិ.ញ៉ាំងផ្ទៃឱ្យពេញ ។ - **បូរ** គុ. ដែលញ៉ាំងផ្ទៃឱ្យពេញ, កិ. ពេញក្នុងផ្ទៃ ។ - **ប្បមាណ** គុ. ប្រមាណនៃផ្ទៃ ។ - **រោគ** បុំ.

រោគក្នុងផ្ទៃ, រោគកើតក្នុងផ្ទៃ ។

**កុជ្ឈតិ** កិ. [ កុធ+យ+តិ.វ. ] ក្រោធ, ខឹង ។

**កុជ្ឈន្ត** គុ. [ កុធ+យ+អន្ត ] កាលក្រោធ, កាលខឹង ។

**កុជ្ឈាបន** នបុំ. [ កុធ+យ+ណាបេ+យុ ] កិ.ញុំាង...ឱ្យក្រោធ, -ខឹង ។ -**វស** បុំ. អំណាចនៃកិ.ញុំាង...ឱ្យក្រោធ ។

**កុជ្ឈាបេន្ត** គុ. [ កុធ+យ+ណាបេ+អន្ត ] កាលញុំាង...ឱ្យក្រោធ ។

**កុជ្ឈាបេហិ** កិ. [ កុធ+យ+ណាបេ+ហិ.ក. ] ចូរញុំាង...ឱ្យក្រោធ ។

**កុជ្ឈាមិ** កិ. [ កុធ+យ+មិ.វ. ] ក្រោធ ។

**កុជ្ឈាយថ** កិ. [ កុធ+យ+ណាយ+ថ.វ. ] ក្រោធ, ឱ្យក្រោធ ។

**កុជ្ឈិតព្វ** គុ. [ កុធ+យ+ឥ.អា.+តព្វ ] គឺ...គប្បីក្រោធ ។

**កុជ្ឈិត្វា** អ. [ កុធ+យ+ឥ.អា.+ត្វា ] ក្រោធហើយ, ខឹងហើយ ។

**កុជ្ឈិស្សតិ** កិ. [ កុធ+យ+ឥ.អា.+ស្សតិ.ភ. ] នឹងក្រោធ ។

**កុជ្ឈេយ្យ** កិ. [ កុធ+យ+ឯយ្យ.ស. ] គប្បីក្រោធ ។

**កុញ្ចិកច្ឆិទ្ទ** នបុំ. [ កុញ្ចិក+ឆិទ្ទ ] ប្រហោងនៃសោ ។

**កុញ្ចិកហត្ថ** គុ. [ កុញ្ចិក+ហត្ថ ] អ្នកមានសោក្នុងដៃ; វិ. **កុញ្ចិកំ ហត្ថេ យស្ស សោ> កុញ្ចិកហត្ថោ** ។

**កុញ្ជរ** បុំ. [ កុំ+ជរ+អ ] (សត្វ) ញុំាងផែនដីឱ្យគ្រាំគ្រា (ដំរី); វិ. **កុំ ឋ-ឋវី ជរាបេតីតិ> កុញ្ជរោ** ។ -**សង្ឃាត** គុ. ពពួកដំរី, គឺបណ្ឌិតពោលថាកុញ្ជរ ។ -**សាលា** ឥ. កុញ្ជរសាលា, រោងនៃដំរី (សាលាមានសណ្ឋានដូចជាសណ្ឋាននៃដំរី) ។



**កុដ** បុំ. នបុំ. ក្អម, ឆ្នាំង, ជាវ (ជាវគឺប្រដាប់ដែលគេរំលាយមាស) ។

**កុដជ** បុំ. [ កុដ+ជ ] (ឈើ) កាត់បង់នូវរោគ (ដើមក្លែងគង់); វិ. **រោគំ កុដតិ ឆិន្ទតីតិ> កុដជោ** ។

**កុដមុខវដ្ដិ** ឥ. [ កុដ+មុខ+វដ្ដិ ] កណ្ដាប់ដៃមាត់នៃក្អម ។

**កុដិកណ្ណ** គុ. [ កុដិ+កណ្ណ ] មានត្រចៀកពាក់នូវគ្រឿងប្រដាប់មានតម្លៃមួយកោដិ(១) (តាមទម្លាប់ថា «មានត្រចៀកយារ») ។ -**សោណត្ថេរ** បុំ. ព្រះថេរឈ្មោះសោណៈមានត្រចៀក... ។

**កុដិក** នបុំ. [ កុដិ+ក ] កុដិតូច, ខ្ទមតូច ។

**កុដិ** ឥ. [ កុដ+ឥ ] កុដិ (ផ្ទះ) ។ -**ទូសកភិក្ខុ** បុំ. ភិក្ខុអ្នកប្រទូស្តនូវកុដិ ។

**កុដុម្ព** នបុំ. ទ្រព្យ, សម្បត្តិ ។

**កុដុម្ពិក** បុំ. [ កុដុម្ព+ណិក ] (ជន) អ្នកមានទ្រព្យ, អ្នកមានសម្បត្តិ; វិ. **កុដុម្ពំ យស្ស អត្ថិតិ> កុដុម្ពិកោ** ។ -**បុត្ត** បុំ. កូននៃជនអ្នកមានទ្រព្យ, កូននៃជនអ្នកមានសម្បត្តិ, កូននៃកុដុម្ពិកៈ ។

**កុដ្ឋិ** បុំ. [ កុដ្ឋ+ឥ, ឥ>ឥ ] អ្នកមានរោគឃ្លង់; វិ. **កុដ្ឋំ យស្ស អត្ថិតិ> កុដ្ឋិ** ។ -**ភាវប្បត្តិ** ឥ. កិ.ដល់នូវភាវៈនៃ...ជាអ្នកមានរោគឃ្លង់ ។ -**ភាវ** បុំ. ភាវៈនៃ....ជាអ្នកមានរោគឃ្លង់ ។

១ មើល «កោដិកណ្ណ» ផង ។

**កុណប** នពុំ. សព, សាកសព ។ - **គន្ធប្បដិកូលតា** ឥ. ភាវៈនៃ...ជា...បដិកូលដោយក្លិននៃសាកសព, ភាវៈនៃ...ជា...មានក្លិននៃសាកសពជាបដិកូល ។

**កុណី** គុ. [ កុណា+ឦ ] អ្នកមានអវយវៈជាគ្រឿងខ្វះបង្ហាញ (ក្ញែង); វិ. **កុណោ យស្ស អត្ថិតិ> កុណី** ។

**កុណ្ឋ** គុ. [ កុណ្ឋ+អ ] ខ្ចក, ពិល, រិល រេច ។ - **កុទ្ទាល** ពុំ. ចបរិល, ចបគរិល ។ - **ធារ** គុ. មានមុខរិល, មានមុខពិល ។ - **បាទ-ច្ឆិន្នជវ** គុ. មានជើងខ្ចក និងមានសន្ទុះដាច់ហើយ, មានសន្ទុះដាច់ហើយ ដោយអំណាចនៃជើងខ្ចក, មានសន្ទុះដាច់ហើយ ព្រោះមានជើងខ្ចក ។

**កុណ្ឌក** ពុំ. [ កុណ្ឌ+អ+ក.ស. ] (ផង់នៃអង្ករ, កំទេចនៃអង្ករ) កន្ទក់ ។ - **អង្គារបូវ** ពុំ. នំគឺបុគ្គលធំមិនលើកដើរភ្លើង ដែលមាសីឈ្មោះបុណ្ណកធ្វើហើយដោយកន្ទក់, នំអំបែង គឺមាសីឈ្មោះកុណ្ឌកធ្វើហើយដោយកន្ទក់ ។ - **មុដ្ឋិ** ឥ. ក្តាប់នៃកន្ទក់, កន្ទក់មានក្តាប់ជាប្រមាណ ។ - **សិន្ធវបោតកជាតក** នពុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយកូននៃសេះសិន្ធវៈស៊ីនូវកន្ទក់ ។ - **អាទិ** គុ. (វត្ថុ) មានកន្ទក់ជាដើម ។

**កុណ្ឌធានកេសី** អ.ន. ព្រះថេរីឈ្មោះកុណ្ឌលកេសី ។ - **ថេរីវត្ថុ** នពុំ. រឿងនៃព្រះថេរីឈ្មោះកុណ្ឌលកេសី ។

**កុណ្ឌល** នពុំ. [ កុណ្ឌ+អល ] កុណ្ឌល (គ្រឿងប្រដាប់ត្រចៀក,



ទំហូ) ។

**កុណ្ឌិកា** ឥ. [ កុឌិ+ក.ស.+អា.ឥ. ] កុណ្ឌី (ប្រដាប់សម្រាប់ដាក់ទឹកជ្រូច) ។

**កុណ្ឌិធានវន** អ.ន. វិហារឈ្មោះកុណ្ឌិធានវ័ន ។

**កុត្តហលជាត** គុ. [ កុត្តហល+ជាត ] ជាអ្នកមានសេចក្តីជ្រួលជ្រើមកើតហើយ, ជាអ្នកមានការរីករាយកើតហើយ (កុតូហល<កុ+តុល+អ, ចុះ ហ.អា.; វិ. **កុំ បាបំ តុលយតីតិ> កុតូហលំ**) ។

**កុទាចនំ** កា.ស. [ កី+ទាចនំ, កី>កុ ] ក្នុងកាលណា១, ក្នុងកាលណាខ្លះ, ជួនកាល, ជួនណា,...។

**កុទ្ទាល** ពុំ. [ កុំ+ទល+ណ ] គ្រឿងទំលាយនូវផែនដី (ចប); វិ. **កុំ បឋវិ ទលតីតិ> កុទ្ទាលោ** ។ - **អត្ថ** ពុំ. ប្រយោជន៍ដល់ចប, សេចក្តីត្រូវការដល់ចប ។ - **បណ្ឌិត** អ.ន. ឈ្មោះកុទ្ទាលបណ្ឌិត ។ - **ផល** នពុំ. ផ្លែនៃចប ។ - **អាទិហត្ថ** គុ. មានវត្ថុមានចបជាដើមក្នុងដៃ ។

**កុទ្ធ** គុ. [ កុធ+ត ] ក្រោធហើយ, ខឹងហើយ ។ - **បុព្វ** គុ. ធ្លាប់ក្រោធហើយ (ខឹងហើយក្នុងកាលមុន) ។ - **មនុស្ស** ពុំ. មនុស្សក្រោធហើយ ។ - **មានស** គុ. មានចិត្តក្រោធហើយ, មានឆន្ទៈកើតក្នុងចិត្តក្រោធហើយ ។

**កុធារី** ឥ. [ កុ+ធរ+ណី ] ដឹង, ប៉ូវថៅ (ប្រើជា **កុឋារី** ក៏មាន) ។

**កុបិត** គុ. [ កុប+ត.ភា.+ត ] កំរើកហើយ, គឺ...ឱ្យកំរើកហើយ (ក្រោធ, ខឹង) ។ . **ភាវ** បុំ. ភាវៈនៃ...ជា...កំរើកហើយ ។ . **មានស** គុ. អ្នកមានចិត្តកំរើកហើយ, អ្នកមានឆន្ទៈមានក្នុងចិត្តកំរើកហើយ ។

**កុប្បតិ** កិ. [ កុប+យ+តិ.វ. ] កំរើក (ក្រោធ, ខឹង) ។

**កុប្បន្តិ** កិ. [ កុប+យ+អន្តិ.វ. ] កំរើក, កក្រើក ។

**កុប្បឹសុ** កិ. [ កុប+យ+ឥំសុ.អជ្ជ. ] កំរើកហើយ ។

**កុព្វន្តិ** កិ. [ ករ+ឱ+អន្តិ.វ. ] ធ្វើ, រមែងធ្វើ ។

**កុព្វតោ** គុ. [ ករ+ឱ+អន្ត+ស.វិ. ] កាលធ្វើ(នៃ...កាលធ្វើ) ។

**កុមារ** បុំ. [ កុ+មរ+ណ, កុម+អារ, កុមារ+រ ] អ្នកគួរវាសនូវផែនដី, (មារក) ដែលគេប្រាថ្នា, អ្នកតែងលេង (កុមារ, ក្មេង); **កុំ ភូមី មរតិ ភិន្ទតិ ចិលេខតីតិ> កុមារោ, កាមិយតីតិ> កុមារោ, កុមារតិ កីឡតីតិ> កុមារោ** ។ . **កស្សបត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះកុមារកស្សប ។ . **បរិវារ** បុំ. បរិវារនៃកុមារ, កុមារជាបរិវារ ។ . **បរិហារ** នបុំ. វត្ថុជាគ្រឿង នាំទៅជុំវិញនៃកុមារ, វត្ថុជាគ្រឿងរក្សានូវកុមារ ។ . **វណ្ណ** គុ. មានភេទដូចជាភេទនៃកុមារ ។

**កុមារក** បុំ. ដូចជា «កុមារ» ដែរ ប្លែកតែចុះ «កបច្ចយ» ខាងចុង ប្រែថា «កុមារ,ក្មេង ឬកុមារតូច, ក្មេងតូច» ។ . **វណ្ណ** បុំ. ភេទដូចជាភេទនៃកុមារ ។



**កុមារិកា** ឥ. កុមារិកា, ក្មេងស្រី ឬ កុមារីតូច, ក្មេងស្រីតូច ។ . **កាល** បុំ. កាលនៃ...ជាកុមារិកា ។ . **វណ្ណាធិវាស** បុំ. អំណាចនៃភេទ មានភេទនៃកុមារិកាជាដើម ។

**កុមារីសត** នបុំ. [ កុមារី+សត ] រយនៃកុមារី ។

**កុមុទ** នបុំ. [ កុ+មុទ+ណ ] (ជលជាត) ត្រេកអរក្នុងទឹក ឬត្រេកអរក្នុងផែនដី (កុមុទ, ផ្កាកុមុទ); វិ **កុយំ មុទតិ ហាសតីតិ> កុមុទំ** ។ . **ឧប្បល** នបុំ. ផ្កាកុមុទនិងផ្កាឧប្បល ។

**កុម្ភការ** បុំ. [ កុម្ភ+ករ+ណ ] (ជន) អ្នកធ្វើនូវឆ្នាំង ឬ ក្អម (ស្មូនឆ្នាំង); វិ. **កុម្ភំ ករោតីតិ> កុម្ភការោ** ។ . **សាលា** ឥ. សាលា (រោង) នៃជនអ្នកធ្វើនូវឆ្នាំង, រោងនៃស្មូនឆ្នាំង ។

**កុម្ភឃោសក** អ.ន. សេដ្ឋីឈ្មោះកុម្ភឃោសកៈ ។ . **វត្ថុ** នបុំ. រឿងនៃ... ។

**កុម្ភទាសី** ឥ. [ កុម្ភ+ទាសី ] ទាសីអ្នកនាំទៅនូវទឹកដោយក្អម (កុម្ភទាសី) ។

**កុម្ភភារ** បុំ. [ កុម្ភ+ភារ ] ភារៈមានកុម្ភៈជាប្រមាណ, ទ្រព្យមានទម្ងន់មួយកុម្ភៈ ។

**កុម្ភិមុខ** នបុំ. [ កុម្ភិ+មុខ ] មាត់នៃឆ្នាំង, មាត់នៃក្អម ។

**កុម្ភីល** បុំ. [ ក+ឧភ+ឦលេ, ឧភ+រ ] ក្រពើ; វិ. **កេន ជលេន ឧភតិ បូរេតីតិ> កុម្ភោ (ជលាសយោ), តត្ថ ឥលតិ គច្ឆតីតិ> កុម្ភីលោ** ។

**កុម្ភូបម** គុ. [ កុម្ភ+ឧបមា ] មានឧបមាដោយក្អម, មានក្អមជាគ្រឿងប្រៀបធៀប ។

**កុម្មាសបូវ** បុំ. [ កុម្មាស+បូវ ] នំគឺបុគ្គលធ្វើហើយដោយសណ្ដែក, នំសណ្ដែក, នំកុម្មាស, (ជាឈ្មោះនំមួយប្រភេទដែលគេប្រើក្នុងប្រទេសឥណ្ឌា) ។

**កុររឃរ** អ.ន. ក្រុងឈ្មោះកុររឃរៈ ។ - **នគរ** នបុំ. នគរឈ្មោះកុររឃរៈ ។

**កុរុ** នបុំ. [ ករ+រុ ] (វត្ថុ) ធ្វើនូវកម្លាំង (បាយ); វិ. **ករោតិ ពលន្តិ> កុរុំ** ។

**កុរុង្គ** បុំ. [ កុ+រង្គ+អ, ចុះនិ.ភា. ] (សត្វ) ដើរទៅលើដី (ប្រើស ឬម្រឹគឈ្មោះកុរុង្គៈ); វិ. **កុយំ រង្គតីតិ> កុរុង្គោ** ។ - **ជាតកាទិ** គុ. (ជាតក) មានកុរុង្គជាតកជាដើម ។ ប្រើជា **កុរង្គ** ក៏មាន ។

**កុរុតេ** កិ. [ ករ+ឱ+តេ.វ. ] ធ្វើ ។

**កុរុធម្ម** បុំ. [ កុរុ+ធម្ម ] កុរុធម៌, ធម៌នៃអ្នកដែនកុរុ ។

**កុរុរដ្ឋ** នបុំ. [ កុរុ+រដ្ឋ ] ដែនឈ្មោះកុរុ ។ - **វាសី** បុំ. ជនអ្នកនៅក្នុងដែនកុរុ, អ្នកមានកិ.នៅក្នុងដែនកុរុជាប្រក្រតី ។

**កុរុមាន** គុ. [ ករ+ឧ+មាន ] កាលធ្វើ ។

**កុរុរាជ** បុំ. [ កុរុ+រាជ ] ស្ដេចក្នុងដែនកុរុ, ស្ដេចជាធំក្នុងដែនកុរុ ។

**កុល** នបុំ. [ កុល+អ ] (វង្ស) ជាហេតុតភ្ជាប់នូវគ្នានឹងគ្នា (ត្រកូល); វិ. **កុលតិ អញ្ញមញ្ញមេតេនាតិ> កុលំ** ។ - **កុមារិកា** ឥ. កុមារិកានៃត្រកូល, ក្មេងស្រីនៃត្រកូល ។ - **គាម** បុំ. ស្រុកនៃត្រកូល ។ - **គេហ** នបុំ. ផ្ទះនៃត្រកូល ។ - **ឃរគមន** នបុំ. កិ. ទៅកាន់ផ្ទះនៃត្រកូល ។ - **ឃរគមនភាវ** បុំ. ភាវៈគឺកិ.ទៅកាន់ផ្ទះនៃត្រកូល, ភាវៈនៃកិ.ទៅកាន់ផ្ទះនៃត្រកូល ។ - **ទត្តិយ** គុ. ដែលត្រកូលឱ្យហើយ ឬ ជារបស់ដែលត្រកូលគេឱ្យ ។ - **ទមក** គុ. អ្នកទូន្មាននូវត្រកូល ។ - **ទូសកកម្ម** នបុំ. កម្មនៃបុគ្គលអ្នកទ្រុស្តនូវត្រកូល ។ - **ធីតា** ឥ. ធីតានៃត្រកូល, កូនស្រីនៃត្រកូល ។ - **ប្បដិបាដិ** ឥ. លំដាប់នៃត្រកូល ។ - **បរិវដ្ដ** បុំ. កិ.វិលទៅជុំវិញនៃត្រកូល, ជួរនៃត្រកូល ។ - **បុត្ត** បុំ. កុលបុត្រ, កូនរបស់ត្រកូល ។ - **វំស** បុំ. វង្សនៃត្រកូល ។ - **វំសានុគត** គុ. ទៅតាមហើយនូវវង្សនៃត្រកូល, ប្រព្រឹត្តទៅតាមហើយនូវវង្សនៃត្រកូល ។ - **ភាតា** បុំ. បងប្អូនប្រុសនៃត្រកូល ។ - **សតិក** គុ. មានរយនៃត្រកូល, ប្រកបដោយរយនៃត្រកូល; វិ. **កុលានំ សតំ> កុលសតំ, កុលសតំ យេសមត្ថីតិ> កុលសតិកា, កុលសតេន និយុត្តា> កុលសតិកា** ។ - **សន្តក** គុ. ជារបស់នៃត្រកូល ។ - **សម្ពន្ធវស** បុំ. អំណាចនៃកិ.ជាប់ព្រមដោយត្រកូល, អំណាចនៃកិ.ទាក់ទងដោយត្រកូល ។



**កុលាល** បុំ. [ កុ+លល+ណ ] អ្នកប្រាថ្នានូវដី ឬ អ្នកក្រាលនូវសិល្បៈរបស់ខ្លួន, អ្នកកាន់យកនូវដីធ្វើ (ស្មូនឆ្នាំង); វិ. **កុំ លលយតិ ឥច្ឆតីតិ> កុលាលោ, កុលតិ អត្តនោ សិប្បំ បត្ថរតីតិ> កុលាលោ** ។ - **ចក្ក** នបុំ. ចក្រនៃស្មូនឆ្នាំង ។

-ភាជនសទិស គុ. ប្រាកដស្មើដោយភាជន៍នៃស្មូនឆ្នាំង, ប្រមាណដោយភាជន៍នៃបុគ្គលអ្នកកាន់យកនូវដីធ្វើ ។

**កុណ្ឌក** នចុំ. [ កុ+កុ+ណ្ហ ] សម្បក (វិ. **កុច្ឆិកមណ្ឌចិនាសនាធិកំ លុនាតីតិ> កុណ្ឌកំ**) ។

**កុលុបគ** គុ. [ កុល+ឧប+គម+ក្វិ ] អ្នកចូលទៅកាន់ត្រកូល; វិ. **កុលំ ឧបគច្ឆតីតិ> កុលុបគោ** ។ -**ថេរ** ចុំ. ព្រះថេរៈអ្នកចូលទៅកាន់ត្រកូល, ព្រះថេរៈជាជីតូន ។

**កុលុបច្ឆេទ** ចុំ. [ កុល+ឧប+ឆិទ+ណ ] កិ.ចូលទៅកាត់បង់នូវត្រកូល, ការចូលទៅផ្តាច់បង់នូវត្រកូល; វិ. **កុលំ ឧបច្ឆិន្ទយតេតិ> កុលុបច្ឆេទនំ, កុលុបច្ឆេទនំ> កុលុបច្ឆេទោ** ។

**កុសត្ត** គុ. [ កុស+រត្ត ] ចុងនៃស្លា (ដែលធ្លាប់ប្រែថា ចុងនៃស្បូវ) ។

**កុសរាជសន្តក** គុ. [ កុសរាជ+សន្តក ] ជារបស់នៃស្តេចឈ្មោះកុសៈ ។

**កុសល** នចុំ. [ កុស+លា ] (គុណជាត) គួរក្នុងកិផ្តាច់បង់នូវបាប (កុសល; គុ. ឈ្លាស, ប៉ិន, ប្រសើរ, វាងវៃ); វិ. **កុសេ បាបច្ឆេទនេ អលន្តិ> កុសលំ** ។ (គុណជាត) ផ្តាច់នូវធម៌ដ៏អាក្រក់គឺធម៌ជាអកុសល; វិ. **កុសតិ បាបកេ អកុសលេ ធម្មេ ឆិន្ទតីតិ> កុសលំ** ។ ម្យ៉ាងទៀត (កុស+លុ+អ) គុណជាតកាត់នូវកិលេសមានរាគៈជាដើមដេកនៅក្នុងសន្តានដោយអាការៈដែលបណ្ឌិតគួរខ្ពើម; វិ. **កុច្ឆិតេនាការេន សន្តានេ សេន្តីតិ> កុសា, រាគាទយោ តេ លុនាតិ ឆិន្ទតីតិ> កុសលំ** ។ -**កម្មករណ** នចុំ. កិ.ធ្វើនូវកម្មជាកុសល ។ -**កម្មករណកាល** ចុំ. កាលនៃកិ.ធ្វើនូវកម្មជាកុសល, កាលជាទីធ្វើនូវកម្មជាកុសល ។ -**កម្មប្បតិដ្ឋាករណ** នចុំ. កាលជាទីធ្វើនូវទីជាទីពឹងគឺកម្មជាកុសល, កាលជាទីធ្វើនូវគុណជាតិជាទីពឹងគឺកម្មជាកុសល ។ -**កម្មបថ** ចុំ. គន្លងគឺកម្មជាកុសល ។ -**កោដ្ឋាស** ចុំ. ចំណែកនៃធម៌ជាកុសល, ចំណែកនៃកម្មជាកុសល ។ -**តា** ឥ. ភាវៈនៃ...នោះជាអ្នកឆ្លាត, -ឈ្លាស, -ប្រសប់ ។ -**ត្ត** នចុំ. ភាវៈនៃ...នោះជាអ្នកឈ្លាស ។ -**បាថេយ្យ** នចុំ. វត្ថុជាប្រយោជន៍ក្នុងផ្លូវជាកុសល ឬ វត្ថុជាប្រយោជន៍ដល់ផ្លូវគឺកុសល, ស្បៀងគឺកុសល; វិ. **បថេ បថស្ស វា ហិតំ> បាថេយ្យំ** ។ <បថ+ណេយ្យ ។ -**វិធិ** ឥ. វិធីនៃចិត្តជាកុសល ។





**កុសលាកុសល** នចុំ. [ កុសល+អកុសល ] កុសលនិងអកុសល ។ -**កម្មករណ** នចុំ. ជាទីធ្វើនូវកម្មជាកុសលនិងកម្មជាអកុសល ។ -**កម្មវីជ** នចុំ. ពូជគឺកម្មជាកុសលនិងអកុសល ។

**កុសលាភិនិព្វត្ត** គុ. [ កុសល+អភិនិព្វត្ត ] ដែលកើតចំពោះហើយអំពីកម្មជាកុសល, គឺកម្មជាកុសលឱ្យកើតចំពោះហើយ ។

**កុសលូបទេស** ចុំ. [ កុសល+ឧបទេស ] ឧបទេសនៃបុគ្គលអ្នកឈ្លាស, ឧបាយជាគ្រឿងណែនាំនៃបុគ្គលអ្នកឈ្លាស, ឧបាយជាគ្រឿងចូលទៅសម្តែងនៃបុគ្គលអ្នកប្រសប់ ។ <ឧប+ទិស+ណ ។

**កុសាវតី** ឥ.ន. ក្រុងឈ្មោះកុសិនារា ។

**កុសីត** គុ. [ កុ+សទ, សទ>សីទ, ទ>ត+អ ] អ្នកលិចចុះ ដោយអាការគឺបណ្ឌិតគប្បីខ្ពើម, ម្យ៉ាងទៀត អ្នកលេចចុះ ក្នុងកិលេសគឺបណ្ឌិតគប្បីខ្ពើម (អ្នកខ្ជិល); វិ. **កុច្ឆិតេនាការេន សីទតីតិ> កុសីតោ, កុច្ឆិតេ កិលេសេ សីទតីតិ> កុសីតោ** ។ **-បុគ្គល** ចុំ. បុគ្គលអ្នកខ្ជិល ។ **-មាណវ** ចុំ. មាណពអ្នកខ្ជិល, មាណពអ្នកខ្ជិលច្រអូស ។

**កុសុម** នចុំ. [ កុស+ឧម ] ផ្កា, ផ្កាឈើ ។

**កុសុម្ភរត្ត** គុ. [ កុសុម្ភ+រត្ត ] ដែលបុគ្គលជ្រលក់ហើយដោយផ្កាដកគាំ ។

**កុហក** ចុំ. [ កុហ+ណ្វុ ] អ្នកកុហក, អ្នកបំភាន់, អ្នកបញ្ឆោត, អ្នកលលួង, អ្នកបោកប្រាស, អ្នកញ៉ាំងគេឱ្យភាន់ភាំង; វិ. **កុហយតីតិ> កុហកោ** ។ **-ចោរ** ចុំ. ចោរអ្នកកុហក ។ **-តាបស** ចុំ. តាបសអ្នកកុហក, តាបសអ្នកញ៉ាំងលោកឱ្យភាន់ភាំង ។ **-ព្រាហ្មណវត្ថុ** នចុំ. រឿងនៃព្រាហ្មណ៍អ្នកកុហក ។

**កុហឹ** អ.ន. [ កឹ+ហឹ, កឹ>កុ ] ក្នុងទីណា, ត្រង់ទីណា ។

**កូដ** [ កុ+អដ+អ, កុដ+ណ ] ធម្មជាតប្រព្រឹត្តទៅដោយអាការគឺបណ្ឌិតគួរខ្ពើម (គុ. កោង, កាច, បៀតបៀន, ដំ, ក្ដៅក្រហាយ, ន.កំពូល, ញញួរ); វិ. **កុច្ឆិតេនាការេន អដតីតិ> កូដំ** ។ **-ជដិល** ចុំ. ជដិលកោង, ជដិលកោងកាច ។ **-ដ្ដក-រណ** នចុំ. កិ.ធ្វើនូវក្ដីកោង ។ **-ដ្ដបរាជិត** គុ. អ្នកមានក្ដីកោងចាញ់ហើយ, អ្នកចាញ់ហើយដោយក្ដីកោង ។ **-សក្ខិ** ចុំ. សាក្សីកោង, បន្ទាល់កោង ។ **-សហស្ស** នចុំ. ពាន់នៃកំពូល, ពាន់នៃញញួរ ។



**កូដាគារ** នចុំ. [ កូដ+អគារ ] ផ្ទះប្រកបដោយកំពូល; វិ. **កូដេន យុត្តំ អគារំ> កូដាគារំ** ។ ផ្ទះ គឺបុគ្គលសង្គ្រោះហើយដោយកំពូល; វិ. **កូដេន សង្គហិតំ អគារំ> កូដាគារំ**, (ផ្ទះមានកំពូល, ភ្នំយោង) ។ **-កណ្ណិកា** ឥ. យោជាងនៃផ្ទះមានកំពូល ។ **-កុច្ឆិប្បមាណ** គុ. មានផ្ទៃនៃផ្ទះមានកំពូលជាប្រមាណ, មានប្រមាណប៉ុនផ្ទៃនៃផ្ទះមានកំពូល ។ **-មត្ត** គុ. មានផ្ទះគឺបុគ្គលសង្គ្រោះហើយដោយកំពូលជាប្រមាណ, ប៉ុនផ្ទះមានកំពូល ។ **-សត** នចុំ. រយនៃផ្ទះគឺបុគ្គលសង្គ្រោះហើយដោយកំពូល, រយនៃផ្ទះមានកំពូល ។ **-សាលា** ឥ. សាលា (រោង) គឺផ្ទះដែលបុគ្គលសង្គ្រោះហើយដោយកំពូល ។

**កូល** នចុំ. [ កុល+ណ ] (វត្ថុ) បិទរាំងនូវទឹកមិនឱ្យហូរចេញទៅខាងក្រៅ (ច្រាំង, ឆ្នេរ); វិ. **កូលតិ អាវរតិ ឧទកំ ពហិ និគ្គមិតុំ ន ទេតីតិ> កូលំ** ។

**កេចិ** វិ.ស.អ. [ កឹ+ចិ ] ពួកមួយ, ពួកខ្លះ, អ្នកខ្លះ, នីមួយ ។

**កេទារ** នចុំ. [ ក្លេទប្ដូរម+អ, ពុទ្ធណា ] ស្រែ (វិ. **ក្លេទយតីតិ> កេទារំ**) ។ **-ន្តរ** នចុំ. ចន្លោះនៃស្រែ ។ **-មរិយាទា** ឥ. ភ្លឺស្រែ, ភ្លឺនៃស្រែ ។

**កោដិកបក្ខភជន** នចុំ. [ កោដិក+បក្ខ+ភជន ] កិ.កប់រកនូវពួកនៃជន

អ្នករៃបអប, កិ.គប់រកនូវពួកនៃជនដែលចាក់បណ្ដោយ, ការគប់រកនូវពួកនៃជនអ្នកអួតអាង ។

**កេលាស** នចុំ. ភ្នំឈ្មោះកេលាស ឬភ្នំឈ្មោះកៃលាស ។ - **កូដប្បដិភាគ** គុ. មានចំណែកប្រៀបដោយកំពូលនៃភ្នំឈ្មោះកៃលាស ។

**កេឡិ** ឥ. [ កិឡ+ឥ ] កិ.លេង, កិ.ឡុកឡឺយ, កិ.ចំអក, កិ.ចំអកចំអន់ (ប្រើជា «កេលិ» ក៏មាន) ។

**កេវដ្ដ** ចុំ. [ កេ+វដ្ដ+ណ ] ជនអ្នកវិលទៅក្នុងទឹកដើម្បីប្រយោជន៍ដល់កិ.ចាប់នូវត្រី ឬ ជនអ្នកញ៉ាំងទឹកឱ្យវិល (ព្រានប្រម៉ង់, ព្រានសន្ទូច); វិ. **កេ ឧទកេ មច្ឆគហណត្ថាយ វដ្ដតីតិ> កេវដ្ដោ, កំ ឧទកំ វដ្ដេតីតិ> កេវដ្ដោ** ។ - **គាមវាសី** ចុំ. ជនអ្នកនៅក្នុងស្រុកនៃព្រានប្រម៉ង់, ជនអ្នកមានកិ.នៅក្នុងស្រុកនៃព្រានប្រម៉ង់ជាប្រក្រតី; វិ. **កេវដ្ដគាមេ វសតីតិ> កេវដ្ដគាមវាសី, កេវដ្ដគាមេ វសិតុំ សីលមស្សាតិ> កេវដ្ដគាមវាសី** ។ - **គាម** ចុំ. ស្រុកនៃព្រានប្រម៉ង់ ។ - **ជេដ្ឋកបុត្ត** ចុំ. កូននៃព្រានប្រម៉ង់ជាច្បង, កូនច្បងនៃព្រានប្រម៉ង់ ។

**កេវល** គុ. [ កេវ+អល ] ទាំងអស់, ទាំងស្រុង, តែប៉ុណ្ណោះ, មិនមានសេសសល់, សុទ្ធ (វិ. **កេវនំ វចក្កនំ> កេវលំ**) ។

**កេវលី** គុ. [ កេវល+ឦ ] មានកំពូលដ៏សុទ្ធ ។

**កេស** ចុំ. [ កេ+សី+អ ] សភាវៈដេកគឺប្រព្រឹត្តទៅលើក្បាល (សក់); វិ. **កេ សិរស្មិំ សយន្តិ បវត្តន្តីតិ> កេសា** ។ ម៉្យាងទៀត សភាវៈស្ថិតនៅលើក្បាល; វិ. **កេ មត្ថកេ សេន្តិ តិដ្ឋន្តីតិ> កេសា** ។ - **កល្យាណ** នចុំ. លំអគឺសក់, លំអនៃសក់ ។ - **កលាប** ចុំ. បាច់នៃសក់, សំណុំនៃសក់ ។ - **អគ្គមត្ត** គុ. មានចុងនៃសក់ជាប្រមាណ, ប៉ុនចុងនៃសក់ ។ - **មស្សុ** នចុំ. សក់និងពុកមាត់ ។ - **លុញ្ចន** នចុំ. កិ.ដកនូវសក់ ។ - **អាទិសមុហសង្ខាត** គុ. ពោលគឺប្រជុំនៃអាការមានសក់ជាដើម, គឺបណ្ឌិតរាប់ត្រួតហើយថាប្រជុំនៃកោដ្ឋាសៈមានសក់ជាដើម ។



**កេសវ** អ.ន. ឈ្មោះកេសវៈ ។ - **តាបស** ចុំ. តាបសឈ្មោះកេសវៈ ។

**កេសី** អ.ន. តាបសឈ្មោះកេសី, តាបសឈ្មោះកេសវៈ ។

**កេសោរោបន** នចុំ. [ កេស+អវ+រុប+យុ ] កិ.ដាក់ចុះនូវសក់, កិ.កោរនូវសក់ ។ - **អត្ថ** ចុំ. ប្រយោជន៍ដល់កិ. ដាក់ចុះនូវសក់ ។ - **សត្ថ** នចុំ. សស្ត្រាសម្រាប់ដាក់ចុះនូវសក់, កាំបិតសម្រាប់កោរនូវសក់ ។

**កោ** វិ.ស.អ. [ កឹ+សិ.វិ. ] អ្នកណា, ណា, អ្វី, ដូចម្ដេច ។

**កោកនទ** នចុំ. [ កោក+នទ+អ ] ឈ្មោះកោកនទៈ, ជាទីបន្លឺនៃសត្វធ្វើនូវសម្លេងថាកិកិ ។ ម៉្យាងទៀតឬជាគញ្ញាំងពួកសត្វធ្វើនូវសម្លេងថាកិកិឱ្យបន្លឺឡើង; វិ. **កោកេ នាទយតីតិ> កោកនទំ.** (ឈូកក្រហម) ។

**កោក** អ.ន. ឈ្មោះកោកៈ ។ - **សុនខលុទ្ទកវត្ថុ** នចុំ. រឿងនៃព្រាន

ព្រោះឆ្កែឈ្មោះកោកៈ, រឿងនៃព្រានអ្នកបណ្ដើរនូវឆ្កែឈ្មោះកោកៈ ។

**កោកាលិក** អ.ន. ឈ្មោះកោកាលិកៈ ។ - **វត្ថុ** នពុំ. រឿងនៃភិក្ខុឈ្មោះកោកាលិកៈ ។

**កោចិ** វិ.ស.អ. [ កឹ+ចិ+សិ.វិ. ] អ្នកណា, អ្នកណានីមួយ, ណានីមួយនិមួយ, តិចតួច ។

**កោជវ** ពុំ. កម្រាល, ព្រំ (ពាមទម្លាប់ជារម្រ៉ឹង) ។

**កោញ្ចុ** ពុំ. [ កោញ្ច+អ ] ក្រៀល, សត្វក្រៀល ។ - **រវ** សម្រែកនៃក្រៀល, កិ.ស្រែកនៃក្រៀល, កិ.ស្រែកដូចជាក្រៀល ។ - **សកុណ** សត្វស្លាបក្រៀល, សត្វក្រៀល ។

**កោណ្ឌញ្ញ** អ.ន. ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ។

**កោដុម្ពរមហាវិហារវាសី** ពុំ. [ កោដុម្ពរមហាវិហារ+វស+ណី ] អ្នកនៅក្នុងវិហារធំឈ្មោះកោដុម្ពរ ។

**កោដិកណ្ណ** គុ. [ កោដិ+កណ្ណ ] មានត្រចៀកទ្រទ្រង់នូវគ្រឿងសម្រាប់ពាក់មានតម្លៃមួយកោដិ; វិ. **កោដិអគ្ឃនកបិលន្ធនធារិនោ កណ្ណា យស្ស សោ> កោដិកណ្ណោ** ។

**កោដិ** ឥ. [ កុដ+ឥ ] កោដិ, ទីបំផុត, ចុង, មុខ ។ - **ប្បត្ត** គុ. ដល់ហើយនូវទីបំផុត ។ - **សតសហស្ស** ប.ស. សែននៃកោដិ ។

**កោដិតខាណុក** ពុំ. [ កោដិត+ខាណុក ] ផង្គត់ដែលបុគ្គលបោះហើយ, បង្គោលដែលបុគ្គលដាំហើយ, -ដែលបុគ្គលដោតហើយ ។



កោដិត<កុដ+ឥ+ត ។

**កោដ្ដេត្វា** អ. [ កុដ្ដ+ណេ+ត្វា ] ដំហើយ, ផែហើយ, វាយហើយ, បុកហើយ, ចិញ្ច្រាំហើយ ។

**កោដ្ដេន្ត** គុ. [ កុដ្ដ+ណេ+អន្ត ] កាលដំ, កាលផែ, កាលវាយ, ... ។

**កោដ្ដេតិ** កិ. [ កុដ្ដ+ណេ+តិ.វ. ] ដំ, វាយ, បុក,... ។

**កោដ្ដេន្តី** ឥ. [ កុដ្ដ+ណេ+អន្ត+ឦ ] កាលដំ, កាលបុក,... ។

**កោដ្ដេតព្វយុត្តក** គុ. [ កោដ្ដេតព្វ+យុត្តក ] ជារបស់គួរគឺ...គប្បីដំ, -គប្បីផែ,... ។

**កោដ្ដន** នពុំ. [ កុដ្ដ+យុ ] កិ.ដំ, កិ.បុក,...។ - **អត្ថ** ពុំ. ប្រយោជន៍ដល់កិ.ដំ,... ។ - **បចនាទិ** គុ. (កិច្ច) មានកិ.បុក និងកិ. ចំអិនជាដើម ។

**កោដ្ដាបេត្វា** អ. [ កុដ្ដ+ណាបេ+ត្វា ] ញុំាង...ឱ្យពោះហើយ, -ឱ្យដោតហើយ, -ឱ្យដំហើយ, -ឱ្យវាយហើយ, -ឱ្យចិញ្ច្រាំហើយ,... ។

**កោដ្ឋគ្គ** គុ. [ កោដ្ឋ+អគ្គ ] មានដីប្រសើរគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីឡើងកាន់ជង្រុក, មានដីល្អោងគឺ..., មានដីលើសគឺ... ។

**កោដ្ឋសត** នពុំ. [ កោដ្ឋ+សត ] រយនៃជង្រុក ។

**កោដ្ឋាគារ** ពុំ. នពុំ. [ កោដ្ឋ+អគារ ] ផ្ទះគឺជង្រុក (ឃ្លាំង) ។

**កោដ្ឋាគារិក** គុ. [ កោដ្ឋាគារ+ណិក ] អ្នកប្រកបក្នុងផ្ទះគឺជង្រុក, អ្នក

ប្រកបក្នុងឃ្លាំង (នាយឃ្លាំង); វិ. **កោដ្ឋាគារេ និយុត្តោ> កោដ្ឋាគារិកោ** ។

**កោដ្ឋាទិ** គុ. [ កោដ្ឋ+អាទិ ] មានជង្រុកជាដើម ។

**កោដ្ឋាស** បុំ. [ កោដ្ឋ+អី+អ ] ចំណែក (វិ. **កោដ្ឋំ វុច្ចតិ សរីរំ, តត្ថ សេតីតិ> កោដ្ឋាសោ**) ។

**កោណ្ឌ** គុ. [ កុណ្ឌ+ណ ] កំបុត, ខ្លៅ, ឆោត, អាក្រក់, ឈាមក ។

**កោណ្ឌធាន** អ.ន. ព្រះថេរៈឈ្មោះកោណ្ឌធាន ។ . **ត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះកោណ្ឌធាន ។

**កោតុហល** នបុំ. [ កុ+តុដ+អល ] កិ.ភ្ញាក់ផ្អើល, សេចក្ដីជ្រួលជ្រើម, ការរំជួល ។ . **ជាត** គុ. អ្នកបានសេចក្ដីភ្ញាក់ផ្អើលកើតហើយ; វិ. **កោតុហលំ ជាតំ យេសំ តេ> កោតុហលជាតា** ។

**កោតុហលិក** បុំ. [ កោតុហល+ណិក ] បុរសឈ្មោះកោតុហលិក, បុរសអ្នកមានសេចក្ដីភ្ញាក់ផ្អើល; វិ. **កោតុហលំ យស្ស អត្ថីតិ> កោតុហលិកោ** ។ . **កាល** បុំ. កាលនៃឃោសកៈជាបុរសឈ្មោះកោតុហលិកៈ ។

**កោធនទ្ធិ** ឥ. [ កោធ+នទ្ធិ ] ខ្សែជាគ្រឿងចងគឺសេចក្ដីក្រោធ, ខ្សែជាគ្រឿងត្របែងគឺសេចក្ដីក្រោធ ។

**កោធនមត្ត** គុ. [ កោធន+មត្ត ] មោសជាតគ្រាន់តែសេចក្ដីក្រោធ ។

**កោធន** បុំ. [ កុធ+យុ ] (បុគ្គល) អ្នកក្រោធ, អ្នកខឹង; វិ. **កុជ្ឈតីតិ> កោធនោ** ។ អ្នកមានកិ. ក្រោធជាប្រក្រតី; វិ. **កុជ្ឈិតុំ សីលមស្សាតិ> កោធនោ** ។



**កោធ** បុំ. [ កុធ+ណ ] សេចក្ដីក្រោធ, សេចក្ដីខឹង, កំហឹង; វិ. **កុជ្ឈនំ> កោធោ** ។ . **វគ្គវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវកោធវគ្គ; វិ. **កោធវគ្គំ វណ្ណេតិ ឯតាយាតិ> កោធវគ្គវណ្ណនា** ។ . **វស** បុំ. អំណាចនៃសេចក្ដីក្រោធ ។

**កោធាភិភូ** គុ. [ កោធ+អភិ+ភូ+អ ] អ្នកគ្របសង្កត់នូវសេចក្ដីក្រោធ; វិ. **កោធំ អភិភវតីតិ> កោធាភិភូ** ។

**កោធាភិភូត** គុ. [ កោធ+អភិភូត ] អ្នកគឺសេចក្ដីក្រោធគ្របសង្កត់ហើយ; វិ. **កោធេន អភិភូតោ> កោធាភិភូតោ**) ។

**កោធុប្បាទ** បុំ. [ កោធ+ឧប្បាទ ] កិ.ញ៉ាំងសេចក្ដីក្រោធឱ្យកើតឡើង, កិ.កើតឡើងនៃសេចក្ដីក្រោធ ។

**កោនាគមន** អ.ន. ព្រះពុទ្ធព្រះនាមកោនាគមនៈ ។

**កោប** បុំ. [ កុប+ណ ] កិ.កម្រើក, សេចក្ដីក្រោធ, សេចក្ដីខឹង, កំហឹង; វិ. **កុបនំ> កោបោ** ។ . **និព្ពាបនមត្ត** គុ. (កុសល) ត្រឹមតែកិ.ញ៉ាំងសេចក្ដីក្រោធឱ្យរលត់ ។ . **មត្ត** គុ. មោសជាតត្រឹមតែសេចក្ដីក្រោធ, មោសជាតគ្រាន់តែកិ.កម្រើក ។

**កោបេតុំ.** អ. [ កុប+ណេ+តុំ ] ដើម្បីញ៉ាំង...ឱ្យកម្រើកបាន ។

**កោមារភច្ច** បុំ. [ កុមារភត+ណ្យ ] ពេទ្យដែលរាជកុមារឱ្យចិញ្ចឹមហើយ, ពេទ្យឈ្មោះកុមារភច្ចៈ; វិ. **កុមារេន ភតោ បោសាបិតោតិ> កុមារភតោ, កុមារភតោ ឯវ>**

កោមារភច្ចោ ។

**កោមុទី** ឥ. [ កោមុទ+ណី ] ជាទីរីកនៃផ្កាកុមុទ (វិ. **កុយំ បឋវិយំ មោទន្តីតិ> កុមុទា, កុមុទានំ សមូហោ> កោមុទោ, កោមុទោ ឯត្ថ អត្ថីតិ> កោមុទី**) ។

**កោលដ្ឋិមត្ត** គុ. [ កោលដ្ឋិ+មត្ត ] មានគ្រាប់នៃក្របៅជាប្រមាណ, ប៉ុនគ្រាប់នៃក្របៅ ។ **កោលដ្ឋិ <កោល+អដ្ឋិ** ។

**កោលរុក្ខ** បុំ. [ កោល+រុក្ខ ] ដើមនៃក្របៅ ។ - **វាសី** បុំ. អ្នកនៅទៀបដើមនៃក្របៅ, អ្នកមានគិ.នៅទៀបដើមនៃក្របៅជាប្រក្រតី ។

**កោលាប** គុ. [ កុលា+វាច ] ពុក, ណើពុក (ប្រើជា **កោឡាប** ក៏មាន) ។

**កោលាហល** បុំ. [ កុលា+វាហល ] កោលាហល, ការជ្រួលជ្រើម, សំឡេងគឹកកង, សម្លេងជាគ្រឿងបាននូវគិ.ប្រួសច្រាប់ (វិ. **កោលនំ> កោលោ, តមាហលតិ ចិន្តតីតិ> កោលាហលោ**) ។

**កោលិត** គុ. [ កុល+ណិក ] អ្នកកើតក្នុងត្រកូល; វិ. **កុលេ ជាយតីតិ> កោលិកោ, សោ ឯវ> កោលិតោ** ។ វ.ន. ឈ្មោះកោលិតៈ ។ - **គ្គាម** បុំ. កោលិតគ្រាម, ស្រុកឈ្មោះកោលិតៈ ។ - **បរិព្វាជក** បុំ. បរិព្វាជកឈ្មោះកោលិតៈ ។ - **មាណវ** បុំ. មាណពឈ្មោះកោលិតៈ ។



**កោលិយ** គុ. [ កោល+ណិយ ] អ្នកកើតទៀបដើមក្របៅ ឬអ្នកនៅទៀបដើមក្របៅ (ក្រុងឈ្មោះកោលិយ); វិ. **កោលរុក្ខេ ជាយន្តីតិ> កោលិយា, កោលរុក្ខេ វសន្តីតិ វា> កោលិយា** ។ - **កម្មករ** បុំ. ជនអ្នកធ្វើនូវការងារនៃព្រះរាជានៅក្នុងក្រុងកោលិយៈ, កម្មករនៃអ្នកក្រុងកោលិយៈ ។ - **ធីតា** ឥ. ធីតានៃជនអ្នកក្រុងកោលិយៈ ។ - **នគរវាសី** បុំ. អ្នកនៅក្នុងក្រុងកោលិយៈ ។

**កោវិទ** បុំ. [ កុ+វិទ+ណ ] អ្នកបាននូវវាចា, អ្នកបាននូវសំដី (អ្នកឆ្លាត, ឈ្លាស, វាងវៃ); វិ. **កុំ វាចំ វិន្ទតីតិ> កោវិទោ** ។

**កោវិលាររុក្ខ** បុំ. [ កោវិលារ+រុក្ខ ] ដើមរលួស, ដើមរលួសផ្កុង ។ ប្រើជា **កោវិឡារ** ក៏មាន ។ <កុ+វិទ+អារ = វិ. **កុំ បថវឹ វិទារយតិ មូលេនាតិ> កោវិឡារោ** ។

**កោសជ្ជ** នបុំ. [ កុសិត+ណ្យ ] ភាវៈនៃបុគ្គលអ្នកលិចចុះក្នុងកិលេស គឺបណ្ដែតព្រើខ្ជិល (ភាវៈនៃបុគ្គលខ្ជិល; ភាវៈនៃសេចក្ដីខ្ជិល, សេចក្ដីខ្ជិល) វិ. **កុច្ឆិតេ កិលេសេ សីទតីតិ> កុសីតោ; កុសីតស្ស ភាវោ> កោសជ្ជំ; កុសីតោ ឯវ វា> កោសជ្ជំ** ។ - **វស** បុំ. អំណាចនៃសេចក្ដីខ្ជិល ។

**កោសម្ពិក** គុ. [ កោសម្ពី+ណិក ] អ្នកនៅក្នុងក្រុងកោសម្ពី; វិ. **កោសម្ពិយំ វសន្តីតិ> កោសម្ពិកា** ។ - **វត្ថុ** នបុំ. រឿងនៃភិក្ខុអ្នកនៅក្នុងក្រុងកោសម្ពី ។ - **សេដ្ឋី** បុំ. សេដ្ឋីអ្នកនៅក្នុងក្រុងកោសម្ពី ។ - **វាសិតិស្សត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈ

ឈ្មោះតិស្សៈនៅក្នុងក្រុងកោសម្ពី ។

**កោសល** អ.ន. ដែនឈ្មោះកោសល ។ - **ជនបទ** ថុំ. ជនបទឈ្មោះកោសល ។ - **នរិន្ទ** គុ. ព្រះរាជាជាធំជាងនរៈឈ្មោះកោសល, ព្រះរាជាជាធំរបស់នរៈក្នុងដែនកោសល ។ - **រដ្ឋ** នថុ. ដែនឈ្មោះកោសល ។ - **រាជ** ថុំ. ស្តេចជាធំក្នុងដែនកោសល ។ - **សំយុត្ត** អ.ន. គម្ពីរឈ្មោះកោសលសំយុត្ត ។

**កោសិយ** អ.ន. ឈ្មោះកោសិយៈ ។

**កោសុ** និ. [ កោ+សុ ] អ្នកណាអេះ, អ្នកណាហ្ន៎ ។

**កោហញ្ញ** នថុ. [ កុហក+ណ្យ ] ភាវៈនៃអ្នកកុហក, ភាវៈនៃអ្នកញ៉ាំងលោកឱ្យភាន់ភាំង; វិ. **កុហកស្ស ភាវោ> កោហញ្ញំ** ។

**កោឡាបរុក្ខ** ថុំ. [ កោឡាប+រុក្ខ ] ឈើពុក, ដើមឈើពុក ។



# ខ

**ខចិត្វា** អ. [ ខច+ត.រា.+ត្វា ] វិចិត្រហើយ, ច្នៃហើយ ។

**ខជ្ជក** នថុ. [ ខាទ+ត+ក.ស. ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី); វិ. **ខាទិតព្វន្តិ> ខជ្ជំ; ខជ្ជំ ឯវ> ខជ្ជកំ** ។

**ខជ្ជ** នថុ. [ ខាទ+ត ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី); វិ. **ខាទិតព្វន្តិ> ខជ្ជំ** ។ - **មំស** នថុ. បង្អែមនិងសាច់ ។ - **វិកតិ** ឥ. វត្ថុគឺបុគ្គលគប្បីទំពាស៊ីគឺបុគ្គលធ្វើឱ្យវិសេស; ឱ្យប្លែក; បង្អែមដ៏ប្លែក ។

**ខជ្ជោបនក** ថុំ. អំពិលអំពែក ។ - **សទិស** គុ. ប្រាកដស្មើដោយអំពិលអំពែក, ដូចជាអំពិលអំពែក ។

**ខញ្ជ** គុ. [ ខញ្ជ+អ ] ខ្វក, មនុស្សខ្វក; វិ. **ខញ្ជតីតិ> ខញ្ជោ** ។ - **ប្បហារ** ថុំ. កិ.ប្រហារនៃមនុស្សខ្វក, កិ.ប្រហារនូវអាចម៍នៃពពៃនៃមនុស្សខ្វក (កិ.ប្រហារដោយអាចម៍នៃពពៃ) ។

**ខដខដសទ្ទ** ថុំ. [ ខដខដ+សទ្ទ ] សំឡេងថាខដខដៈ ។

**ខណ** ថុំ. [ ខិ+យុ ] កាលជាទីអស់ទៅ ឬ កាលជាទីរស់ទៅនៃអាយុនៃសត្វ (ខណៈ, ស្របក់, មួយរំពេច); វិ. **ខិយតិ ឯត្ថាតិ> ខណោ; សត្តានំ អាយុ ខិយតិ ហាយតិ ឯត្ថ កាលេតិ វា> ខណោ** ។ - **មត្ត** គុ. កាលត្រឹមតែមួយខណៈ ។

**ខណាតីត** គុ. [ ខណ+អតីត ] មានខណៈកន្លងទៅហើយ, កន្លងហើយយូរណាស់ ។

**ខណិក** គុ. [ ខណ+ណិក ] ប្រព្រឹត្តទៅក្នុងខណៈ, ប្រព្រឹត្តទៅអស់កាលមួយស្របក់ ឬមួយរំពេច ។ . **ឥត្តរប្បច្ចុបដ្ឋានត្ត** ពុំ. សេចក្តីថាកាយប្រព្រឹត្តទៅក្នុងខណៈ និងកិ.ប្រាកដចំពោះថាជារបស់ណាមក, អត្ថថាកាយជាទីចូលទៅតាំងនៅចំពោះថាជារបស់ណាមកប្រព្រឹត្តទៅអស់កាលមួយរំពេច ។

**ខណ្ឌ** ពុំ., គុ. [ ខណ្ឌ+អ ] កំណាត់, ចំណែក, ដុំ, បាក់, ដាច់; (វិ. **ខណ្ឌយតិ សមុច្ឆាយតីតិ> ខណ្ឌោ**) ។ . **ទន្ត** គុ. អ្នកមានធ្មេញបាក់ ។ . **សីលាទិតា** ឥ. ភាវៈនៃទោសជាតមានសីលដាច់ជាដើម; វិ. **ខណ្ឌំ សីលំ> ខណ្ឌសីលំ; ខណ្ឌសីលំ អាទិ យស្ស តំ> ខណ្ឌសីលាទិ; ខណ្ឌសីលាទិនោ ភាវោ> ខណ្ឌសីលាទិតា** ។

**ខណ្ឌាខណ្ឌិក** គុ. [ ខណ្ឌខណ្ឌ+ណិក ] មានបំណែកតូចនិងបំណែកធំ (ឱ្យជារបស់មានបំណែកតូចនិងបំណែកធំ); វិ. **ខណ្ឌាខណ្ឌា យស្ស អត្ថីតិ> ខណ្ឌាខណ្ឌិកំ** ។

**ខណ្ឌាទិភាវប្បត្ត** គុ. [ ខណ្ឌាទិភាវ+បត្ត ] ដល់ហើយនូវភាវៈនៃទោសជាតមានសីលដាច់ជាដើម ។

**ខណ្ឌិច្ចាទិ** គុ. [ ខណ្ឌិច្ច+អាទិ ] (វិការៈ) មានភាវៈនៃបុគ្គលមានធ្មេញបាក់ជាដើម; វិ. **ខណ្ឌិតស្ស ភាវោ> ខណ្ឌិច្ចំ** ។

**ខត្តិយ** ពុំ. [ ខត្ត+ឥយ ] ពូជពង្សនៃខត្តៈ, ជាធំក្នុងខេត្តដែរ, ជាអធិបតីនៃស្រែ (ក្សត្រិយ៍) ។ . **កញ្ញា** ឥ. កញ្ញានៃក្សត្រិយ៍ ។ . **ធីតា** ឥ. ធីតានៃក្សត្រិយ៍ ។ . **បព្វជិត** គុ. ជាក្សត្រិយ៍បួស



ហើយ, ជាក្សត្រិយ៍ទ្រង់ផ្នួសហើយ ។ . **បរិវារ** គុ. មានក្សត្រិយ៍ជាបរិវារ ។ . **ព្រាហ្មណកុល** នពុំ. ត្រកូលនៃក្សត្រិយ៍ និងត្រកូលនៃព្រាហ្មណ៍ ។ . **មហាសាលព្រាហ្មណមហាសាលកុល** នពុំ. ត្រកូលនៃខត្តិយមហាសាលនិងព្រាហ្មណមហាសាល ។ . **មហាសាល** នពុំ. ក្សត្រិយ៍ជាមហាសាល ។ . **មាន** ពុំ. មានះនៃក្សត្រិយ៍, មានះថាអញជាក្សត្រិយ៍; វិ. **ខត្តិយោ (អហំ) ឥតិ មានោ> ខត្តិយមានោ** ។ . **រាជធីតា** ឥ. ធីតានៃព្រះរាជាជាក្សត្រិយ៍ ។ . **មាយា** ឥ. មាយានៃក្សត្រិយ៍, ពុតនៃក្សត្រិយ៍ ។ . **វំស** ពុំ. វង្សនៃក្សត្រិយ៍ ។ . **សុខុមាល** គុ. ជាក្សត្រិយ៍ចំរើនទៅក្នុងសេចក្តីសុខ, ជាក្សត្រិយ៍ចំរើនដោយសេចក្តីសុខ, ជាក្សត្រិយ៍ល្អិតពន់, ជាក្សត្រិយ៍ទន់ល្អ ។

**ខទិរ** ពុំ. [ ខទ+ឥរ; ខាទ+រ ] (ឈើ) ជាគ្រឿងជាប់មាំ ឬឈើដែលបាណកជាតតែងចំពាស៊ី (គគី, សង្កែ); វិ. **ខទន្តិ ធន្តានេនាតិ> ខទិរោ; ខាទិយតិ បាណកេហីតិ វា> ខទិរោ** ។ . **ខាណុ** ពុំ., នពុំ. ដង្កត់នៃឈើគគី ។ . **គហណោ, . ន** នពុំ. ស្បាតនៃគគី, ជាទីស្បាតដោយដើមគគី (ជាទីស្មុកស្មាញដោយដើមសង្កែ) ។ . **អង្គារជាតក** នពុំ. ជាតកគឺបណ្តិតកំណាត់ហើយដោយរងើកភ្លើងនៃឈើគគី ។ . **អង្គាររាសិ** ពុំ. គំនរនៃរងើកភ្លើងជាវិការៈនៃឈើគគី ។ . **ថម្ភ** ពុំ. សសរជាវិការៈនៃឈើគគី ។ . **ការុ** នពុំ. ឱសនៃឈើគគី, ឱសជាវិការៈនៃឈើគគី, ឱសជាវិការៈនៃដើមសង្កែ ។ . **រុក្ខកណ្ឌក** ពុំ. បន្លានៃឈើគគី, បន្លានៃឈើសង្កែ ។ . **រុក្ខ** ពុំ. ដើមនៃគគី, ដើមនៃសង្កែ ។ . **វនិយ-**

**រេវតត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះរេវតៈនៅក្នុងព្រៃនៃឈើគគី, នៅក្នុងព្រៃដ៏ដេរដាសដោយដើមគគី ។

**ខនតិ** កិ. [ ខន+អ+តិ.វ. ] ជីក, គាស់ ។

**ខនថ** កិ. [ ខន+អ+ថ.ក. ] ចូរជីក, ចូរគាស់ ។

**ខនាបេត្វា** អ. [ ខន+ណាបេ+ត្វា ] ញុំាង...ឱ្យជីកហើយ ។

**ខនាបេស្សាមិ** កិ. [ ខន+ណាបេ+ស្សាមិ.ភ. ] នឹងញុំាង...ឱ្យជីក ។

**ខនិ** កិ. [ ខន+អ+ឦ.អជ្ជ. ] ជីកហើយ ។

**ខនិត** គុ. [ ខន+ឥ.អា.+ត ] គឺ...ជីកហើយ ។

**ខនិត្វា** អ. [ ខន+ឥ.អា.+ត្វា ] ជីកហើយ ។

**ខនិយមាន** គុ. [ ខន+ឥ.អា.+យ+មាន ] គឺ...កាលជីក ។

**ខន្តិ** ឥ. [ ខម+តិ ] ខន្តី, សេចក្តីអត់ធន់; វិ. **ខមនំ> ខន្តិ** ។ **. ពល** នបុំ. កម្លាំងនៃខន្តី ។ **. មេត្តោទក** នបុំ. ទឹកគឺខន្តីនិងមេត្តា, ខន្តីនិងមេត្តាដូចជាទឹក ។ **. វាទិជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយតាបសឈ្មោះខន្តិវាទី ។ **. វាទិភូត** គុ. ជាតាបសឈ្មោះខន្តិវាទី, ជាតាបសឈ្មោះខន្តិវាទីកើតហើយ ។ **. សោរច្ច** នបុំ. ខន្តីនិងភាវៈនៃបុគ្គលអ្នកត្រេកអរដោយល្អ, ខន្តិនិងភាវៈនៃសេចក្តីត្រេកអរដោយល្អ, សេចក្តីអត់ធន់និងសេចក្តីស្ងប់ស្ងៀម(**សោរច្ច**<សុរត+ណ្យ = វិ. **សុរតស្ស ភាវោ សោរច្ចំ, សុរតោ ឯវ> សោរច្ចំ**) ។



**ខន្ធ** បុំ. [ ខន+ធម្មម+ត ] ខន្ធ, គំនរ គង, ដើម, កំណាត់ឈើ, ហ្វូង, ពួក, ប្រជុំ, ក ។ **. អដ្ឋិក** នបុំ. ឆ្អឹងនៃក ។ **. គុត្ត** នបុំ. គុត្តគឺការរក្សានូវខន្ធ, គុត្តដែលកើតអំពីខន្ធ, គុត្តប្រចាំខន្ធ ។ **. ធាតុអាយ-តនឥន្ទ្រិយពលពោជ្ឈង្គសតិប្បដ្ឋានបរិទីបក** គុ. ជាគ្រឿងសំដែងនូវខន្ធ និងធាតុ និងអាយតនៈ និងឥន្ទ្រិយ និងពលៈ និងពោជ្ឈង្គ និងសតិប្បដ្ឋាន ។ **. ធាតុអាយតនពោធិ-បក្ខិយធម្ម** បុំ. ខន្ធនិងធាតុនិងអាយតនៈនិងពោធិបក្ខិយធម៌ ។ **. ធាតុអាយតនាទិភេទ** គុ. ផ្សេងដោយធម៌មានខន្ធ និងធាតុ និងអាយតនៈជាដើម ។ **. ធាតុអាយតនមត្ត** គុ. ធម៌ត្រឹមតែខន្ធ និងធាតុ និងអាយតនៈ ។ **. បរិហរណគុត្ត** នបុំ. គុត្តគឺកិ.រក្សានូវខន្ធ ។ **. បរិហរណសម** គុ. ស្មើដោយកិ.រក្សានូវខន្ធ, ស្មើដោយកិ.នាំទៅជុំវិញនូវខន្ធ ។ **. រសាទិ** គុ. មានរសនៃដើមជាដើម, មានរសដែលកើតអំពីដើមជាដើម ។ **. លោកា-ទិសង្ខាត** គុ. ពោលគឺលោកមានខន្ធលោកជាដើម, គឺបណ្ឌិតរាប់ព្រមហើយថាលោកមានខន្ធលោកជាដើម ។ **. វដ្ដ** បុំ. វដ្ដៈគឺខន្ធ ។ **. វស** បុំ. អំណាចនៃខន្ធ ។ **. សម** គុ. ស្មើដោយខន្ធ ។ **. អា-ទិប្បដិសំយុត្ត** គុ. ប្រកបព្រមចំពោះហើយដោយធម៌មានខន្ធជាដើម ។ **. អាទិភេទ** គុ. ផ្សេងដោយធម៌មានខន្ធជាដើម ។ **. វារ** បុំ. ប្រទេសជាទីបិទបាំងដោយកំណាត់ឈើ (របាំង, កញ្ចែត); វិ. **ខន្ធេហិ អាវារេន្តិ ឯត្ថាតិ> ខន្ធាវារោ** ។

**ខមនីយ** គុ. [ ខម+អនីយ ] គឺ... គប្បីអត់បាន, គឺ...គប្បីអត់ធន់បាន;

វិ. **ខមិតព្វន្តិ> ខមនីយំ** ។

**ខមន្តិ** កិ. [ ខម+អ+អន្តិ_វ. ] គួរ, អត់, អត់ឱន ។

**ខមថ** កិ. [ ខម+អ+ថ_ប. ] ចូរអត់, ចូរអត់ទោស, សូមអត់,... ។

**ខម** គុ. [ ខម+អ ] អត់, អត់ធន់, គួរ ។

**ខមាបនុបាយ** ពុំ. [ ខមាបន+ឧបាយ ] ឧបាយជាគ្រឿងញុំាង...ឱ្យអត់, ..ឱ្យអត់ទោស ។

**ខមាបិត** គុ. [ ខម+ណាបេ+ឥ_អា.+ត ] គឺ...ឱ្យអត់ហើយ, ..ឱ្យអត់ទោសហើយ; វិ. **ខមាបិយិត្ថាតិ> ខមាបិតោ** ។ . **កាល** ពុំ. កាលនៃ...គឺ...ឱ្យអត់ហើយ, ..ឱ្យអត់ទោសហើយ ។

**ខមាបិយមាន** គុ. [ ខម+ណាបេ+ឥ_អា.+យ+មាន ] គឺ...កាលឱ្យអត់,... ។

**ខមាបេតិ** កិ. [ ខម+ណាបេ+តិ_វ. ] ញុំាង...ឱ្យអត់,... ។

**ខមាបេតុំ** អ. [ ខម+ណាបេ+តុំ ] ដើម្បីញុំាង...ឱ្យអត់,... ។

**ខមាបេត្វា** អ. [ ខម+ណាបេ+ត្វា ] ញុំាង...ឱ្យអត់ហើយ,... ។

**ខមាបេថ** កិ. [ ខម+ណាបេ+ថ_ប. ] ចូរញុំាង....ឱ្យអត់,... ។

**ខមាបេយ្យ** កិ. [ ខម+ណាបេ+ឯយ្យ_ស. ] គប្បីញុំាង...ឱ្យអត់,... ។

**ខមាបេសិ** កិ. [ ខម+ណាបេ+ឥ_អជ្ជ., ចុះស_អា. ] ញុំាង...ឱ្យអត់ហើយ ។





**ខមាបេហិ** កិ. [ ខម+ណាបេ+ហិ_ប. ] ចូរញុំាង...ឱ្យអត់,... ។

**ខមាបេសុំ** កិ. [ ខម+ណាបេ+ឧំ_អជ្ជ., ចុះស_អា. ] ញុំាង...ឱ្យអត់ហើយ,... ។

**ខមាបេស្សាមិ** កិ. [ ខម+ណាបេ+ស្សាមិ_ភ. ] នឹងញុំាង...ឱ្យអត់,... ។

**ខមាមិ** កិ. [ ខម+អ+មិ_វ. ] អត់, អត់ទោស,... ។

**ខមិស្សតិ** កិ. [ ខម+អ+ឥ_អា+ស្សតិ_ភ. ] នឹងអត់,... ។

**ខយ** ពុំ. [ ខិ+អ ] កិ.អស់, ការអស់ទៅ; វិ. **ខយនំ> ខយោ** ។ . **បត្ត** គុ. ដល់ហើយនូវកិ.អស់ទៅ ។ . **វយធម្ម** គុ. មានកិ.អស់ទៅនិងកិ.សូន្យទៅជាធម្មតា; វិ. **ខយវយោ ធម្មោ យស្ស តំ> ខយវយធម្មំ** ។ . **វយបត្ត** គុ. ដល់ហើយនូវកិ.អស់ទៅ និងកិ.សូន្យទៅ ។ . **វយ** ពុំ. កិ.អស់ទៅនិងកិ.សូន្យទៅ ។ . **សង្ខាត** គុ. ពោលគឺកិ.អស់ទៅ, គឺបណ្ឌិតរាប់ព្រមហើយថាកិ.អស់ទៅ ។

**ខរតរ** គុ. [ ខរ+តរ ] ក្លាជាង, ខ្លាំងជាង, រឹងជាង ។

**ខរមន្តី** គុ. [ ខរ+មន្តី ] មានសេចក្ដីគិតដ៏ក្លា, មានគំនិតពោះពុត, មានគំនិតរង់រាច, មានគំនិតរាងវៃ ។

**ខល** នបុំ. [ ខល+អ ] ទីដែលគេគប្បីសំអាត (លាន) ។ . **កាល** ពុំ. កាលជាទីធ្វើនូវលាន ។ . **អគ្គ** គុ. មានដ៏ប្រសើរគឺបុគ្គលគប្បី

ឱ្យក្នុងកាលជាទីនាំមកកាន់លាន, មានដីលើសគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីធ្វើនូវលាន ។ - **ភណ្ឌកាល** បុំ. កាលជាទីធ្វើនូវកិ.បញ្ចាន់ក្នុងលាន, កាលជាទីធ្វើនូវកិ.រោយក្នុងលាន ។ - **ភណ្ឌគ្គ** គុ. មានដីថ្មោងគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីបញ្ចាន់ក្នុងលាន ។ - **មណ្ឌលមត្ត** គុ. មានមណ្ឌលនៃលានជាប្រមាណ, ប៉ុនមណ្ឌលនៃលាន ។ - **មណ្ឌលសទិស** គុ. ប្រាកដស្មើដោយមណ្ឌលនៃពកន ។

**ខលិត** គុ. [ ខល+ឥ_អា.+ត ] ដែល...ភ្លាំងភ្លាត់ហើយ, ...ភ្លាត់ហើយ, ន. សេចក្ដីភ្លាំងភ្លាត់ ។

**ខលិត្វា** អ. [ ខល+ឥ_អា.+ត្វា ] ភ្លាត់ហើយ ។

**ខល្លាដសីស** នបុំ. [ ខល្លាដ+សីស ] ក្បាលនៃបុគ្គលទំពែក, សីសៈទំពែក (**ខល្លាដ**<ខ+លា+ដ = អ្នកកាន់យកនូវសីសៈទទេ (ទំពែក); វិ. **ខំ គុច្ឆំ សីសំ លាតីតិ> ខល្លាដោ** ។

**ខលុ** និ. ឮថា, បានឮថា, គេឮថា, សេចក្ដីដំណាលថា ។

**ខាទតិ** កិ. [ ខាទ+អ+តិ_វ. ] ស៊ី, ទំពាស៊ី ។

**ខាទន** នបុំ. [ ខាទ+យុ ] កិ.ស៊ី. កិ.ទំពាស៊ី; វិ. **ខាទយតេតិ> ខាទនំ** ។ - **បិវនសមត្ថ** គុ. អាចក្នុងកិ.ទំពាស៊ី និងកិ.ផឹក ។ - **វស** បុំ. អំណាចនៃកិ.ទំពាស៊ី ។ - **សមត្ថ** គុ. អាចក្នុងកិ.ទំពាស៊ី ។

**ខាទនីយ** គុ. [ ខាទ+អនីយ ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី); វិ. **ខាទិតព្វន្តិ> ខាទនីយំ** ។ - **ភោជនីយសយន** នបុំ. វត្ថុគឺបុគ្គលគប្បីទំពាស៊ី និងវត្ថុគឺបុគ្គលគប្បីបរិភោគ និងទីជាទីដេក ។ - **អាទិទានឱបម្ម** នបុំ. ភាវៈនៃវាចាជាគ្រឿងប្រៀបដោយកិ.ឱ្យនូវវត្ថុមានវត្ថុគឺបុគ្គលគប្បីទំពាស៊ីជាដើម (**ឧបមាយ ភាវោ> ឱបម្មំ**) ។



**ខាទមាន** គុ. [ ខាទ+អ+មាន ] កាលទំពាស៊ី ។

**ខាទសិ** កិ. [ ខាទ+អ+សិ_វ. ] ស៊ី, ទំពាស៊ី ។

**ខាទន្ត** គុ. [ ខាទ+អ+អន្ត ] កាលទំពាស៊ី ។

**ខាទន្តិ** កិ. [ ខាទ+អ+អន្តិ_វ. ] ស៊ី, ទំពាស៊ី ។

**ខាទាបេសិ** កិ. [ ខាទ+ណាបេ+ឦ_អជ្ជ., ទុះស_អា. ] ញ៉ាំង...ឱ្យទំពាស៊ីហើយ ។

**ខាទាបេស្សាមិ** កិ. [ ខាទ+ណាបេ+ស្សាមិ_ភ. ] នឹងញ៉ាំង...ឱ្យទំពាស៊ី ។

**ខាទាម** កិ. [ ខាទ+អ+ម_ប. ឬស្សាម_ភ. ] ចូរទំពាស៊ី, នឹងទំពាស៊ី ។

**ខាទាហិ** កិ. [ ខាទ+អ+ហិ_ប. ] ចូរទំពាស៊ី ។

**ខាទិ** កិ. [ ខាទ+អ+ឦ_អជ្ជ. ] ទំពាស៊ីហើយ ។

**ខាទិត** គុ. [ ខាទ+ឥ_អា.+ត ] គឺ...ទំពាស៊ីហើយ, ស៊ីហើយ ។ - **បីតនច្ចគីតវាទិតាទិ** គុ. វត្ថុគឺ...ទំពាស៊ី និងវត្ថុគឺ...ផឹក និងគ្រឿងគប្បីការកិ.រាំ និងកិ.ច្រៀង និងកិ.ប្រគំជាដើម ។ - **បុព្វ** គុ.

គឺ...ធ្លាប់ទំពាស៊ីហើយ, គឺ...ទំពាស៊ីហើយក្នុងកាលមុន ។ - **មំស** នបុំ. សាច់គឺ...ទំពាស៊ីហើយ ។

**ខាទិតុំ** អ. [ ខាទ+ឥ.អា.+តុំ ] ដើម្បីទំពាស៊ី ។

**ខាទិត្វា** អ. [ ខាទ+ឥ.អា+ត្វា ] ទំពាស៊ីហើយ ។

**ខាទិត្ត** កិ. [ ខាទ+អ+ឥ.អា.+ត្ថ.ហី. ] ទំពាស៊ីហើយ ។

**ខាទិយមាន** គុ. [ ខាទ+ឥ.អា.+យ+មាន ] គឺ...កាលទំពាស៊ី, គឺ...កាលស៊ី ។

**ខាទិស្សាមិ** កិ. [ ខាទ+អ+ឥ.អា.+ស្សាមិ.ភ. ] នឹងទំពាស៊ី ។

**ខាទេយ្យ** កិ. [ ខាទ+អ+ឯយ្យ.ស. ] គប្បីទំពាស៊ី ។

**ខាណុ, ខានុក** បុំ., នបុំ. ដង្គត់, បង្គោល ។ - **សញ្ញី** បុំ. អ្នកមានសេចក្ដីសំគាល់ថាដង្គត់ ។ - **មត្ត** គុ. ត្រឹមតែដង្គត់, មានដង្គត់ជាប្រមាណ ។ - **មត្ថក** បុំ. ទីបំផុតនៃដង្គត់, ចុងនៃដង្គត់, ក្បាលនៃដង្គត់ ។

**ខានុកោណ្ឌញ្ញ** អ.ន. ព្រះថេរៈឈ្មោះខានុកោណ្ឌញ្ញៈ ។ - **ត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈឈ្មោះខានុកោណ្ឌញ្ញៈ ។

**ខាយតិ** កិ. [ ខា+យ+តិ.វ. ] ប្រាកដ, ជាក់ស្ដែង ។

**ខាយិ** កិ. [ ខា+យ+ឦ.អជ្ជ. ] ប្រាកដហើយ, ជាក់ស្ដែងហើយ ។

**ខាយិំសុ** កិ. [ ខា+យ+ឧំ.អជ្ជ. ] ប្រាកដហើយ ។



**ខារិក** គុ. [ ខារ+ណិក ] មានរសខារ ។

**ខារបរិសេក** បុំ. [ ខារ+បរិ+សិច+ណ ] កិ.ស្រោចដោយទឹកដីផ្សា ។

**ខារិភណ្ឌក** នបុំ. [ ខារិ+ភណ្ឌក ] ភណ្ឌៈគឺគ្រឿងបរិក្ខារ, ភណ្ឌៈសម្រាប់នាំនូវបរិក្ខារ (តាមទម្លាប់ថា «ភណ្ឌៈគឺម្រែក») ភណ្ឌៈមានខារិជាប្រមាណ ។

**ខិឌ្ឌាបសុតតា** ឥ. [ ខិឌ្ឌបសុត+តា ] ភាវៈនៃ...ជាអ្នកខ្វល់ខ្វាយក្នុងកិ.លេង; វិ. **ខិឌ្ឌាបសុតស្ស ភាវោ> ខិឌ្ឌាបសុតតា** ។

**ខិត្ត** គុ. [ ខិប+ត ] គឺ...បោះទៅហើយ, -ចោលទៅហើយ, -គ្រវែងទៅហើយ, -បាញ់ទៅហើយ ។ - **កាល** បុំ. កាលនៃ...គឺ...បោះទៅហើយ,... ។

**ខិប** កិ. [ ខិប+អ+ហិ.ប., លុបហិ ] ចូរបោះទៅ, ចូរចោលទៅ, ចូរគ្រវែងទៅ ។

**ខិបតិ** កិ. [ ខិប+អ+តិ.វ. ] បោះទៅ, ចោលទៅ, គ្រវែងទៅ ។

**ខិបតុ** កិ. [ ខិប+អ+តុ.ប. ] ចូរបោះទៅ,... ។

**ខិបន្ត** គុ. [ ខិប+អ+អន្ត ] កាលបោះទៅ,... ។

**ខិបមាន** គុ. [ ខិប+អ+មាន ] កាលបោះទៅ ។

**ខិបាបេសិ** កិ. [ ខិប+ណាបេ+ឦ.អជ្ជ.ចុះស.អា. ] ញុំាង...ឱ្យបោះទៅហើយ, -ឱ្យគ្រវែងទៅហើយ ។

**ខិបិ** កិ. [ ខិប+អ+ឦ.អជ្ជ. ] បោះទៅហើយ, ផ្ដាត់ទៅហើយ ។

**ខិបិត** គុ. [ ខិប+ឥ.អា.+ត ] គឺ...កណ្ដាស់ហើយ, គឺ...បោះទៅហើយ ។ - **កាសាទិ** គុ. មានរោគកណ្ដាស់ និងរោគក្អកជាដើម ។ - **រោគ** ពុំ. រោគកណ្ដាស់, រោគគឺកិ.កណ្ដាស់ ។ - **សទ្ទ** ពុំ. សំឡេងកណ្ដាស់, ស្នូរគឺកិ.កណ្ដាស់, ស្នូរនៃកិ.កណ្ដាស់, ស្នូរគឺ...បោះទៅហើយ ។

**ខិបិតុំ** អ. [ ខិប+ឥ.អា.+តុំ ] ដើម្បីបោះទៅ, វិកិ.បោះទៅ ។

**ខិបិត្វា** អ. [ ខិប+ឥ.អា.+ត្វា ] កណ្ដាស់ហើយ, បោះទៅហើយ ។

**ខិបិយមាន** គុ. [ ខិប+ឥ.អា.+យ+មាន ] គឺ...កាលបោះទៅ ។

**ខិបីសុ** កិ. [ ខិប+អ+ឥំ.អជ្ជ. ] បោះទៅហើយ ។

**ខិបេយ្យំ** កិ. [ ខិប+អ+ឯយ្យំ.ស. ] គប្បីបោះទៅ ។

**ខិប្បតរ** គុ. [ ខិប្ប+តរ ] ឆាប់ជាង, រហ័សជាង ។

**ខិប្បំ** កិវិ. ឆាប់, ឆាប់ៗ, ប្រញាប់, រហ័ស, រួសរាន់, ទាន់ហាន់ ។

**ខិប្បាភិញ្ញោ** គុ. [ ខិប្ប+អភិញ្ញាណ ] អ្នកមានអភិញ្ញាណដ៏ឆាប់, អ្នកមានគុណជាតជាគ្រឿងដឹងចំពោះដ៏រហ័ស ។

**ខីណ** គុ. [ ខិ+ត, ត>ណ ] អស់ហើយ ។ - **ត្ត** នពុំ. ភាវៈនៃ...ជា...អស់ហើយ ។ - **តា** ឥ. ភាវៈនៃ...ជា...អស់ហើយ ។ - **បត្ត** គុ. មានស្លាបអស់ហើយ ។ - **បាថេយ្យ** គុ. មានវត្ថុជាប្រយោជន៍ក្នុងផ្លូវអស់ហើយ, មានស្បៀងអស់ហើយ; វិ. **បថេ ហិតំ> បាថេយ្យំ, ខីណំ បាថេយ្យំ យេសំ តេ> ខីណបា**



**ថេយ្យា** ។ - **ភាវ** ពុំ. ភាវៈនៃ...ជា...អស់ហើយ ។ - **មច្ឆ** គុ. មានត្រីអស់ហើយ ។ - **សំយោជន** គុ. អ្នកមានសំយោជនៈអស់ហើយ, អ្នកមានធម៌ជាគ្រឿងញុំាងសត្វឱ្យប្រកបព្រមអស់ហើយ ។

**ខីណាសវ** គុ., ពុំ. [ ខីណ+អាសវ ] អ្នកមានអាសវៈអស់ហើយ, ព្រះខីណាស្រព ។ - **ឧសភ** ពុំ. ព្រះខីណាស្រពដូចជាគោឧសភ, ព្រះខីណាស្រពអ្នកប្រសើរ, ព្រះខីណាស្រពអ្នកអង់អាច ។ - **ព្រាហ្មណ** ពុំ. ព្រាហ្មណ៍ជាព្រះខីណាស្រព, ព្រាហ្មណ៍មានអាសវៈអស់ហើយ ។ - **ភាវ** ពុំ. ភាវៈនៃ...ជាអ្នកមានអាសវៈអស់ហើយ ។ - **សហស្ស** នពុំ. ពាន់នៃព្រះខីណាស្រព ។ - **សាមណេរ** ពុំ. សាមណេរជាព្រះខីណាស្រព ។ - **សីស** នពុំ. សីសៈ (ក្បាល) នៃព្រះខីណាស្រព ។

**ខីយតិ** កិ. [ ខិ+ឦយ+តិ.វ. ] អស់, អស់ទៅ ។

**ខីយន្ត** គុ. [ ខី+អ+អន្ត, ផ្លាស់ ឦនៃធាតុជា ឦយ ] កាលតិះដៀល ។

**ខីយមាន** គុ. [ ខី+ឈ+មាន ] កាលតិះដៀល ។

**ខីយមាន** គុ. [ ខិ+ឦយ ឬណយ+មាន ] កាលអស់ទៅ, កាលឱ្យអស់ទៅ ។

**ខីយិត្វា** អ. [ ខី+ឥ.អា.+ត្វា ] តិះដៀលហើយ ។

**ខីយេ** កិ. [ ខិ+ឦយ+ឯយ្យ.ស. ] គប្បីអស់ទៅ ។

**ខីរ** នពុំ. [ ខិ+ឦរ ] ធម្មជាតអស់ទៅដោយកិ.រឹត(ទឹកដោះ, ទឹកដោះក្រាស់), វិ. **ខីយតិ ឧបហនោតិ> ខីរំ** ។ - **បក** គុ.

អ្នកបៅនូវទឹកដោះ, កំពុងបៅនូវទឹកដោះ; វិ. **ខីរំ បិវតីតិ> ខីរបោ** ។ . **មុខ** គុ. មានទឹកដោះក្នុងមាត់, មានមាត់កំពុងផឹកនូវទឹកដោះ ។ . **មូល** នចុំ. តម្លៃនៃទឹកដោះ ។ . **យាគុ** ឥ. បបរ គឺបុគ្គលចំអិនហើយដោយទឹកដោះ, បបរលាយដោយទឹកដោះ ។ . **សទិស** គុ. ប្រាកដស្មើដោយទឹកដោះ ។ . **សប្បិមធុផាណិត** នចុំ. ទឹកដោះស្រស់ និងទឹកដោះថ្លា និងទឹកឃ្មុំ និងទឹកអំពៅ ។

**ខីរោទក** នចុំ. [ ខីរ+ឧទក ] ទឹកដ៏លាយហើយដោយទឹកដោះស្រស់; វិ. **ខីរេន សំសដ្ឋំ ឧទកំ> ខីរោទកំ** ។

**ខីលជាត** គុ. [ ខីល+ជាត ] ជាអ្នកដូចជាសសរខឿនកើតហើយ, ជាអ្នករឹងត្អឹង, (ជាត ទុកជាសកត្ថៈ មិនបាច់ប្រែក៏បាន) ។

**ខុជ្ជ** គុ. [ កុ>ខុ+វជ+ណ, លុបវ ] អ្នកដើរទៅដែលគេគួរខ្ពើម, ឬអ្នកដល់នូវដំណើរដែលគេគួរខ្ពើម (គម); វិ. **កុច្ឆិតំ វជតីតិ> ខុជ្ជោ** ។ . **ធាតុក** គុ. មានធាតុនៃបុគ្គលគម, មានធាតុគម ។ . **ឧត្តរា** អ.ឆ. ភិក្ខុនីឈ្មោះខុជ្ជុត្តរា ។

**ខុទ្ទក** គុ. [ ខុទ្ទ+ក.ស. ] តូច ។ . **គ្គាមភោជក** ពុំ. អ្នកបរិភោគនូវស្ទួយក្នុងស្រុកតូច (មេស្រុក); វិ. **ខុទ្ទកគ្គាមំ ភុញ្ជតីតិ> ខុទ្ទកគ្គាមភោជកោ** ។ . **មហន្ត** គុ. ទាំងតូចទាំងធំ ។ . **មហល្លកទារក** ពុំ. ទារកតូចនិងទារកធំ, ក្មេងតូចនិងក្មេងអ្នកកាន់យកនូវភារៈនៃខ្លួនជាមនុស្សធំ ។ . **វគ្គុលិយ** គុ. ប្រចៀវតូច ។ . **សាខា** ឥ. មែកតូច ។ . **សាខាភញ្ជន** នចុំ. កិ.កាច់នូវមែកតូច, កិ.បំបាក់នូវមែកតូច ។ . **សោណ្ឌី** ឥ. ត្រពាំងទឹកតូច ។ . **ច្ឆិទ្ទកវាតបាន** នចុំ. បង្អួចមានប្រហោងតូច ។



**ខុទ្ទ** [ ខុ ឬខុម+ទ ] គុ. តូច, ពុំ. សេចក្តីឃ្លាន, សេចក្តីលំបាក ។ . **បូវ** ពុំ. នំតូច ។

**ខុទ្ទានុខុទ្ទក** គុ. [ ខុទ្ទ+អនុខុទ្ទក ] តូចនិងតូចដោយលំដាប់, តូចនិងតូចតាមលំដាប់, កិ.ត្រូវនូវអាបត្តិតូចដោយលំដាប់ ។

**ខុទ្ទាភិភូត** គុ. [ ខុទ្ទ+អភិភូត ] គឺសេចក្តីឃ្លានគ្របសង្កត់ហើយ, គឺសេចក្តីលំបាកគ្របសង្កត់ហើយ ។

**ខុប្បិបាសា** ឥ. [ ខុទ្ទ+បិបាសា ] សេចក្តីប្រាថ្នាដើម្បីស៊ី និងសេចក្តីប្រាថ្នាដើម្បីផឹក, សេចក្តីឃ្លាននិងសេចក្តីស្រេក ។ . **បីឡិត** គុ. គឺសេចក្តីឃ្លាន និងសេចក្តីស្រេកបៀតបៀនហើយ ។

**ខុភតិ** កិ. [ ខុភ+អ+តិ.វ. ] កំរើក, រញ្ជួយ, ញាប់ញ័រ ។

**ខុរ** ពុំ., នចុំ. [ ខុរ+អ ] កាំបិតកោរ, ក្រចក ។ . **អគ្គ** គុ. ចុងនៃកាំបិតកោរ, កាលជាទីបំផុតនៃកម្មគឺបុគ្គលគប្បីធ្វើដោយកាំបិតកោរ ។ . **ធារា** ឥ. មុខនៃកាំបិតកោ ។ ធម្មជាតជាគ្រឿងកាត់នូវផែនដី (ក្រចក); វិ. **ខុរតិ ឆិន្ទតិ បឋវី អនេនាតិ> ខុរំ** ។

**ខុសិត** គុ. [ ខុស+ឥ.អា.+ត, ចុះនិ.អា. ] គឺ...ដេរហើយ, .ប្រមេចហើយ ។

**ខុសោន្ត** គុ. [ ខុស+អ+អន្ត, ចុះនិ.អា. ] កាលដេរ, កាលប្រមេច ។

**ខេត្ត** នចុំ. [ ខិត+ត ] ទីដែលជនព្រោះនូវពូជ ឬទីជាទីព្រោះនូវពូជ

(ស្រែ, ចំការ); វិ. ពីជានិ ខិបិយន្តិ ខិបន្ត្យស្មិន្តិ ខា> ខេត្តំ ។ ម្យ៉ាងទៀត (<ខិត្ត+តា+ត) ទីរក្សានូវពូជដែលជនព្រោះហើយ; វិ. ខិត្តំ ពីជំ តាយតីតិ ខា> ខេត្តំ ។ . អារាមុយ្យានយោគ្គាទិក គុ. មានស្រែ និងសួន និងឧទ្យាន និងយាន ជាដើម ។ . កសនកាល ចុំ. កាលជាទីភ្ជួរនូវស្រែ ។ . កោដ្ឋាស ចុំ. ចំណែកនៃស្រែ ។ . អគ្គ គុ. មានដីប្រសើរគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីជំរះនូវស្រែ ។ . ដ្ឋាន នចុំ. ទីនៃស្រែ, ទីជាខេត្ត, ទីដូចជាខេត្ត ។ . វត្ថុអាទិ គុ. មានស្រែនិងទីជាទីនៅជាដើម (ខ្លះថា មានស្រែ និងចំការជាដើម) ។

**ខេបយឹសុ** គិ. [ ខិប+ណេយ+ឥំ_អជ្ជ. ] ញុំាង...ឱ្យអស់ទៅហើយ ។

**ខេបិតត្ត** នចុំ. [ ខេបិត+ត្ត ] ភាវៈនៃ...នោះជា...គឺ...ឱ្យអស់ទៅហើយ ។

**ខេបេតុំ** អ. [ ខិប+ណេ+តុំ ] ដើម្បីញុំាង...ឱ្យអស់ទៅ ។

**ខេបេត្វា** អ. [ ខិប+ណេ+ត្វា ] ញុំាង...ឱ្យអស់ទៅហើយ ។

**ខេបេន្តិ** គិ. [ ខិប+ណេ+អន្តិ_វ. ] ញុំាង...ឱ្យអស់ទៅ ។

**ខេមក** អ.ន. ឈ្មោះខេមកៈ ។ . **សេដ្ឋីបុត្តវត្ថុ** នចុំ. រឿងនៃសេដ្ឋីបុត្តឈ្មោះខេមកៈ ។

**ខេម** គុ., នចុំ. [ ខិ+ម ] ធម្មជាតជាគ្រឿងអស់ទៅនៃភ្លើងមានភ្លើងគឺរាគៈជាដើម ឬធម្មជាតជាទីអស់ទៅនៃឧបស័គ្គ មានឧបស័គ្គគឺឧបទ្រពជាដើម (ជាគ្រឿងក្សេម, ជាទីក្សេម, សេចក្ដីក្សេម); វិ.



ខយន្តិ ឯតេន រាគគ្គិអាទយោតិ> ខេមំ, ខយន្តិ ឯត្ថ ឧបទ្ទវុបសគ្គាទយោតិ> ខេមំ ។

**ខេមន្ត** ចុំ. [ ខេម+អន្ត ] ទីបំផុតនៃសេចក្ដីក្សេម, ទីបំផុតគឺសេចក្ដីក្សេម ។

**ខេមា** អ.ន. ឈ្មោះខេមា ។ . **ភិក្ខុនីវត្ថុ** នចុំ. រឿងនៃភិក្ខុនីឈ្មោះខេមា ។

**ខេមី** គុ. [ ខេម+ឦ ] អ្នកមានសេចក្ដីក្សេម (អ្នកមានធម៌ជាទីអស់ទៅនៃភ័យ); វិ. ខេមំ យស្ស អត្ថីតិ> ខេមី ។

**ខេឡ** ចុំ. [ ខី+ឡ ] សភាវៈរមែងអស់ទៅ (ទឹកមាត់); វិ. ខីយតីតិ> ខេឡោ ។ . **បិណ្ឌ** ចុំ. ដុំនៃទឹកមាត់ ។ . **សិង្ឃានិកាទិអសុចិមក្ខិតដ្ឋាន** នចុំ. ទីដែលប្រឡាក់ហើយដោយវត្ថុមិនស្អាត មានទឹកមាត់និងទឹកសម្បោរជាដើម, ទីគឺអសុចិមានទឹកមាត់និងទឹកសម្បោរជាដើមប្រឡាក់ហើយ ។ . **អាទិ** គុ. មានទឹកមាត់ជាដើម ។

**ខេឡាសិកវាទ** ចុំ. [ ខេឡាសិក+វាទ ] គឺ.ពោលថាភិក្ខុឈ្មោះទេវទត្តអ្នកស៊ីនូវបច្ច័យដូចជាទឹកមាត់ដោយប្រក្រតី; វិ. ខេឡំ វិយ បច្ចយំ អសតិ ខាទតិ សីលេនាតិ> ខេឡាសី, ខេឡាសី ឯវ> ខេឡាសិកោ, ខេឡាសិកោ ឥតិ វាទោ> ខេឡាសិកវាទោ ។

**ខោ** និ. ឯង, ពិត, មែនពិត,... ។

**ខោភយមាន** គុ. [ ខុភ+ណយ+មាន ] កាលញុំាង...ឱ្យកំរើក, កាលឱ្យញាប់ញ័រ, កាលឱ្យរញ្ជួយ ។

**ខោភេតុំ** អ. [ ខុភ+ណេ+តុំ ] ដើម្បីញុំាង...ឱ្យកំរើក ។

**ខោមកប្បាសិក** គុ. [ ខោមកប្បាស+ណិក ] សំពត់ដែលគេធ្វើអំពីសំបកឈើនិងសំពត់ដែលគេធ្វើអំពីកប្បាស, សំពត់ដែលគេធ្វើអំពីសំបកឈើនិងកប្បាស ។



**គគន** នពុំ. [ គក+យុ, ច>គ ] ទីជាទីទៅនៃសត្វមានសត្វស្លាបជាដើម (អាកាស); វិ. **គច្ឆន្តេត្ថ ចិហង្គមាទយោតិ> គគនំ** ។ - **តល** នពុំ. ផ្ទៃនៃអាកាស ។ - **មជ្ឈ** ពុំ., នពុំ. កណ្ដាលនៃអាកាស ។

**គង្គា** ឥ.ន. មេទឹកឈ្មោះគង្គា, ទន្លេឈ្មោះគង្គា, ស្ទឹងឈ្មោះគង្គា ។ - **តីរ** នពុំ. ឆ្នេរនៃស្ទឹងឈ្មោះគង្គា ។ - **នទី** ឥ. ស្ទឹងឈ្មោះគង្គា, ទន្លេគង្គា ។

**គង្គោទក** នពុំ. [ គង្គា+ឧទក ] ទឹកក្នុងស្ទឹងឈ្មោះគង្គា ។

**គង្គោរោហណសមាគម** ពុំ. [ គង្គា+ឱរោហណ+សមាគម ] ការជាទីមកព្រមក្នុងកាលជាទីចុះកាន់ស្ទឹងឈ្មោះគង្គា, កាលជាទីប្រជុំក្នុងកាលជាទី..., កិ.ប្រជុំក្នុងកាលជាទីចុះកាន់ទន្លេគង្គា ។

**គច្ឆ** កិ. [ គម+អ+ហិ.ប., លុបហិ ] ចូរទៅ, ចូរដល់ ។

**គច្ឆ** នពុំ. [ គម+ណ>គច្ឆ ] គុម្ពឈើ ។ - **ភូមិបោថនដ្ឋាន** នពុំ. ទីជាទីវាយនូវគុម្ពឈើនិងផែនដី ។ - **មូល** នពុំ. ប្រទេស (ឬទី) ជាទីតាំងនៃគុម្ពឈើ, ទីជិតនៃគុម្ពឈើ ។

**គច្ឆថ** កិ. [ គម+អ+ថ.ប. ] ចូរទៅ, ចូរដល់ ។

**គច្ឆតិ** កិ. [ គម+អ+តិ.វ. ] ទៅ, ដល់ ។

**គច្ឆន្ត** គុ. [ គម+អ+អន្ត ] កាលទៅ, កាលដល់ ។

**គច្ឆន្តិ** កិ. [ គម+អ+អន្តិ.វ. ] ទៅ, ដល់ ។

**គច្ឆន្តុ** កិ. [ គម+អ+អន្តុ_ប. ] ចូរទៅ, ចូរដល់ ។

**គច្ឆមាន** គុ. [ គម+អ+មាន ] កាលទៅ, កំពុងទៅ ។

**គច្ឆាហិ** កិ. [ គម+អ+ហិ_ព. ] ចូរទៅ, ចូរដល់ ។

**គច្ឆឹសុ** កិ. [ គម+អ+ឹសុ_អជ្ជ. ] ទៅហើយ ។

**គច្ឆេយ្យ** កិ. [ គម+អ+ឯយ្យ_ស. ] គប្បីទៅ ។

**គជុត្តម** ចុំ [ គជ+ឧត្តម ] ដំរីដ៏ឧត្តម, ដំរីដ៏ខ្ពង់ខ្ពស់ ។

**គជ្ជន្ត** គុ. [ គជ្ជ+អ+អន្ត ] កាលគ្រហឹម, កាលគំរាម, កាលគំរន ។

**គណជេដ្ឋក** គុ. [ គណ+ជេដ្ឋក ] ប្រសើរបំផុតក្នុងពួក, ចំរើនបំផុតជាងពួក, ជាធំជាងពួកឬជាធំក្នុងពួក, ជាច្បងក្នុងពួក, ជាច្បងរបស់គណៈ ។

**គណទេវបុត្ត** ចុំ. [ គណ+ទេវបុត្ត ] ឈ្មោះគណទេវបុត្ត, ទេវបុត្តជាគណៈ, ទេវបុត្តដែលតាំងនៅដោយពួក ។

**គណនា** ឥ. [ គណ+យុ+អា_ឥ. ] ធម្មជាតិដែលជនរាប់, កិ.រាប់, ការរាប់; វិ. **គណិយតេតិ> គណនា** ។

**គណពន្ធ** គុ. [ គណ+ពន្ធ ] កិ.ចងគ្នាដោយគណៈ, .ជាពួក, កិ.ចូលគ្នាជាពួក ។

**គណយំ** គុ. [ គណ+ណយ+អន្ត+សិ.វិ. ] កាលរាប់ ។

**គណរាជកុល** នចុំ. [ គណ+រាជ+កុល ] ត្រកូលនៃស្ដេចជាគណៈ,



ត្រកូលនៃព្រះរាជាដែលតាំងនៅដោយភាវៈជាពួក ។

**គណសង្គណិក** គុ. [ គណសង្គណា+ណិក ] មានកិ.ច្រឡំដោយពួក, ប្រព្រឹត្តទៅក្នុងកិ.ច្រឡូកច្របល់ដោយពួក (អត្ថិតទ្ធិត ឬ វុត្តិតទ្ធិត) ។

**គណសជ្ឈាសយ** ចុំ. [ គណ+សជ្ឈាសយ ] កិ.ស្វាធ្យាយដោយពួក, ការស្វាធ្យាយដោយអំណាចនៃពួក, ការសូធ្យដោយអំណាចនៃពួក ។

**គណសេដ្ឋ** គុ. [ គណ+សេដ្ឋ ] ប្រសើរបំផុតជាងពួក, ប្រសើរបំផុតក្នុងពួក ។

**គណាចរិយ** ចុំ. [ គណ+អាចរិយ ] អាចារ្យនៃពួក, អាចារ្យរបស់ពួក ។

**គណាបេថ** កិ. [ គណ+ណាបេ+ថ_ព. ] ចូរញុំាង...ឱ្យរាប់ ។

**គណាបេន្ត** គុ. [ គណ+ណាបេ+អន្ត ] កាលញុំាង...ឱ្យរាប់, កាលរាប់ ។

**គណិយមាន** គុ. [ គណ+ឥ_អា.+យ+មាន ] គឺ...កាលរាប់ ។

**គណី** គុ. [ គណ+ណី ] ជាធំក្នុងពួក, ជាអាចារ្យនៃពួក ។ ន.ឥ. ផែនដី ។

**គណេតុំ** អ. [ គណ+អ, អ>ឯ+តុំ ] ដើម្បីរាប់, វិកិ.រាប់ ។

**គណេត្វា** អ. [ គណ+អ+ត្វា ] រាប់ហើយ, អើពើហើយ ។

**គណេន្តិ** កិ. [ គណ+អ+អន្តិ_វ. ] រាប់, អើពើ ។

**គណ្ឋ** ចុំ. [ គន្ថ+អ, ផ្លាស់ន្ថជាណ្ឋ ] កិលេសជាគ្រឿងដោតក្រង ឬ កិលេសជាទីចាក់ស្រែះ; វិ. **គន្ថេតិ ឯតេហិ ឯត្ថ វាតិ> គណ្ឋា** ។ ប្រើជា «គន្ថ» ក៏មាន ។

**គណ្ឋិក** ចុំ. [ គណ្ឋ+ណិក ] ឡេវ, ក្រវិល, ក្តុំ, ពក, ដុំ ។ . **ជាត** គុ. មានពកកើតហើយ ។

**គណ្ឋិត** គុ. [ គន្ថ>គណ្ឋ+ឥ.អា.+ត ] គឺ...ដោតក្រងហើយ, គឺ... ចាក់ស្រែះហើយ ។

**គណ្ឋិ** ឥ. [ គន្ថ+ឥ>គណ្ឋិ ] បង្វិច, បង្វិចទ្រព្យ (វត្ថុដែលគេវិច ឬ ខ្ចប់) ។ . **ភេទកចោរ** ចុំ. ចោរអ្នកទំលាយបង្វិច ។ . **ភេទកចោរវត្ថុ** នចុំ. រឿងនៃចោរអ្នកទំលាយបង្វិច ។

**គណ្ឌ** ចុំ. ពក, បូស, ដុំ, ថ្គាល់, អ.ន. ឧយ្យានបាលឈ្មោះគណ្ឌៈ ។

**គណ្ឌាគណ្ឌ** គុ. [ គណ្ឌ+អគណ្ឌ ] ទាំងពកតូចទាំងពកធំ, ជាពកតូច និងពកធំ, ពកនិងពកដ៏ចំរើន ។

**គណ្ឌម្ព** ចុំ. [ គណ្ឌ+អម្ព ] ឈើឈ្មោះគណ្ឌម្ពៈ (ស្វាយដែលបុរសឈ្មោះគណ្ឌៈដាំហើយ) ។ . **មត្ថក** ចុំ. ទីបំផុត (ចុង, កំពូល) នៃឈើឈ្មោះគណ្ឌម្ពៈ ។ . **រុក្ខមូល** នចុំ. ប្រទេសជាទីតាំងនៃឈើឈ្មោះ..., ទីជិតនៃដើមឈើឈ្មោះ..., គល់នៃដើមឈើឈ្មោះ...។

**គណ្ឌិកសញ្ញា** ឥ. [ គណ្ឌិក+សញ្ញា ] សញ្ញានៃរគាំង, សេចក្តីសំគាល់នៃរគាំង, .ដោយរគាំង ។

**គណ្ឌិសទ្ទ** ចុំ. [ គណ្ឌិ+សទ្ទ ] សំឡេង (ឬស្នូរ) នៃរគាំង ។



**គណ្ឌុប្បាទយោនិ** ឥ. [ គណ្ឌុប្បាទ+យោនិ ] កំណើតនៃជន្លេន (កំណើតនៃឬសដី) **គណ្ឌុប្បាទ**<គណ្ឌុ+ឧ+បទ+ណ = សត្វញាំងវត្ថុប្រាកដស្មើដោយពកនៃផែនដីឱ្យកើតឡើង; វិ. **គណ្ឌុំ បឋវិយា គណ្ឌសទិសំ ឧប្បាទេតីតិ> គណ្ឌុប្បាទោ, គណ្ឌុំ វច្ចសន្និចយំ ឧប្បាទេតីតិ វា> គណ្ឌុប្បាទោ**) ។ យ.វិ. និងសុចិ ។

**គណ្ហ** គិ. [ គហ+ណ្ហា+ហិ.ប. ] ចូរកាន់, ចូរកាន់យក, ចូរចាប់ ។

**គណ្ហក** គុ. [ គហ+ណ្ហា+ណ្វុ ] អ្នកកាន់យក,... ។

**គណ្ហនសមត្ថ** គុ. [ គណ្ហន+សមត្ថ ] អាចក្នុងកិ.កាន់យក, អាចដើម្បីកិ.កាន់យក ។

**គណ្ហន្តី** គុ. [ គហ+ណ្ហា+អន្ត+ឦ ] កាលកាន់យក ។

**គណ្ហន្តុ** គិ. [ គហ+ណ្ហា+អន្តុ.ប. ] ចូរកាន់យក, ចូរកាន់, ចូរចាប់ ។

**គណ្ហន្ត** គុ. [ គហ+ណ្ហា+អន្ត ] កាលកាន់យក,...។

**គណ្ហស្សុ** គិ. [ គហ+ណ្ហា+ស្សុ.ប. ] ចូរកាន់,... ។

**គណ្ហាតិ** គិ. [ គហ+ណ្ហា+តិ.វ. ] កាន់, កាន់យក,... ។

**គណ្ហាបេតិ** គិ. [ គហ+ណ្ហា+ណាបេ+តិ.វ. ] ញុំាង...ឱ្យកាន់យក,... ។

**គណ្ហាហិ** គិ. [ គហ+ណ្ហា+ហិ.ប. ] ចូរកាន់យក, ចូរកាន់, ចូរចាប់ ។

**គណ្ហិ** គិ. [ គហ+ណ្ហា+ឦ.អជ្ជ. ] កាន់យកហើយ,...។

**គណ្ហិតុកាម** គុ. [ គណ្ហិតុំ+កាម ] អ្នកចង់ដើម្បីកាន់យក, អ្នកមានប្រាថ្នាដើម្បីកាន់យក; វិ. **គណ្ហិតុំ កាមេតីតិ> គណ្ហិតុកាមោ, គណ្ហិតុំ កាមោ អស្សាតិ> គណ្ហិតុកាមោ** ។

**គណ្ហិតុំ** អ. [ គហ+ណ្ហា+ឥ_អា.+តុំ ] ដើម្បីកាន់យក, វីកិ.កាន់យក, ...។

**គណ្ហិត្វា** អ. [ គហ+ណ្ហា+ឥ_អា+ត្វា ] កាន់យកហើយ, ... ។

**គណ្ហិត្ថ** កិ. [ គហ+ណ្ហា+ឥ_អា.+ត្ថ_ហី. ] កាន់យកហើយ, ...។

**គណ្ហិស្សតិ** កិ. [ គហ+ណ្ហា+ឥ_អា.+ស្សតិ_ភ. ] នឹងកាន់យក, ...។

**គណ្ហឹសុ** កិ. [ គហ+ណ្ហា+ឧំ_អជ្ជ. ] កាន់យកហើយ, ...។

**គណ្ហេយ្យ** កិ. [ គហ+ណ្ហា+ឯយ្យ_ស. ] គប្បីកាន់យក, ... ។

**គត** គុ. [ គម+ត ] ទៅហើយ, ដល់ហើយ, ។ - **ការណ** នបុំ. ហេតុនៃ...ទៅហើយ ។ - **កាល** ពុំ. កាលនៃ...ទៅហើយ ។ - **គតដ្ឋាន** នបុំ. ទីនៃ...ទៅហើយៗ ។ - **ដ្ឋាន** នបុំ. ទីនៃ...ទៅហើយ ។ - **ត្ត** នបុំ. ភាវៈជាអ្នកទៅហើយ ។ - **ទហរ** ពុំ. ភិក្ខុកម្លោះអ្នកទៅហើយ ។ - **ទិវស** ពុំ., នបុំ. ថ្ងៃនៃ...ទៅហើយ ។ - **អទ្ធ** គុ. មានផ្លូវឆ្ងាយដល់ហើយ ។ - **អទ្ធី** ពុំ. អ្នកមានផ្លូវឆ្ងាយដល់ហើយ ។ - **បច្ចយ** ពុំ. បច្ច័យនៃ...ទៅហើយ, បច្ច័យគឺភាវៈនៃ...ជាអ្នកទៅហើយ ។ - **បុព្វ** គុ. ធ្លាប់ទៅហើយ, ទៅហើយក្នុងកាលមុន ។ - **បុរិស** ពុំ. បុរសអ្នកទៅហើយ ។ - **ភាវ** ពុំ. ភាវៈនៃ...ជាអ្នកទៅហើយ ។ - **មគ្គ** ពុំ. ផ្លូវនៃ...ទៅហើយ ។



- **វយ** គុ. អ្នកមានវ័យដល់ហើយ, អ្នកមានវ័យទៅហើយ ។ - **វេលា** ឥ. វេលានៃ...ទៅហើយ ។

**គតិ** ឥ. [ គម+តិ ] គតិ, ដំណើរ, កិ.ទៅ; វិ. **គមនំ> គតិ** ។ ភូមិដែលសត្វគប្បីទៅ ឬ ភូមិជាទីទៅនៃសត្វ; វិ. **គន្តព្វាតិ> គតិ, គច្ឆន្តិ ឯត្ថាតិ វា> គតិ** ។ - **វស** ពុំ. អំណាចនៃគតិ ។

**គត្តសម្ពាហន** នបុំ. [ គត្ត+សម្ពាហន ] កិ.ច្របាច់នូវខ្លួន, កិ.គក់នូវខ្លួន, កិ.រឹតនូវខ្លួន, កិ.ទូតនូវខ្លួន (គត្ត នបុំ. <គម ឬ គហ+ត=ធម្មជាតជាគ្រឿងទៅ, ម្យ៉ាងទៀត ធម្មជាតជាគ្រឿងកាន់យកនូវកម្មជាកុសលនិងអកុសល (ខ្លួន); វិ. **គច្ឆតិ គណ្ហាតិ កុសលាកុសលមេតេនាតិ> គត្តំ**) ។

**គទ្រភ** ពុំ. [ គទ+រភ>គទ្រភ ] លា, លាឈ្មោល ។ - **ភារក** ពុំ. ភារៈគឺលាគប្បីនាំទៅ, ទ្រព្យមានទម្ងន់គឺលាគប្បីនាំទៅ ។ - **យោនិ** ឥ. កំណើតនៃលា ។

**គទ្រភី** ឥ. [ គទ្រភ+ឦ ] មេលា, លាញី ។

**គន្តព្វ** គុ. [ គម+តព្វ ] គឺ...គប្បីទៅ, -គួរទៅ ។

**គន្តុកាមតា** ឥ. [ គន្តុកាម+តា ] ភាវៈនៃ...ជាអ្នកចង់ដើម្បីទៅ; វិ. **គន្តុំ កាមេតីតិ> គន្តុកាមោ, គន្តុកាមស្ស ភាវោ> គន្តុកាមតា** ។

**គន្តុំ** អ. [ គម+តុំ ] វីកិ.ទៅ, ដើម្បីទៅ ។

**គន្ត្វា** អ. [ គម+ត្វា ] ទៅហើយ, ដល់ហើយ ។

**គន្ថ** ចុំ. [ គន្ថ+អ ] បករណៈជាទីដោតក្រងនូវសេចក្តី ឬបករណៈជាគ្រឿងប្រកាសនូវសេចក្តី (គម្ពីរ); វិ. **អត្ថេ គន្ថេតិ បកាសេតិ ឯត្ថ ឯតេន វាតិ> គន្ថោ** ។ - **ធុរ** នចុំ. គន្ថធុរៈ, ធុរៈគឺកិ.រៀននូវគម្ពីរ ។

**គន្ថិកត្ថេរ** ចុំ. [ គន្ថិក+ថេរ ] ព្រះថេរៈអ្នករៀននូវគម្ពីរ (គន្ថិក< គន្ថ+ណិក = វិ. **គន្ថំ ឧគ្គណ្ហាតីតិ> គន្ថិកោ**) ។

**គន្ធ** ចុំ. [ គន្ធ+អ ] ក្លិន, គ្រឿងក្រអូប ។ - **កុដិ** ឥ. កុដិដែលគេប្រោះព្រំហើយដោយក្លិនដ៏ជាទិព្វ (គន្ធកុដិ, កុដិមានក្លិន); វិ. **ទិព្វគន្ធេហិ បរិភាវិតា កុដិ> គន្ធកុដិ** ។ - **កុមារ** ចុំ. ឈ្មោះគន្ធកុមារ ឬ កុមារឈ្មោះគន្ធៈ ។ - **គហណភាវេ** នចុំ. កិ. ខ្លាចអំពីកិ.កាន់យកនូវក្លិន ។ - **ចុណ្ណាទិ** គុ. (វត្ថុ) មានវត្ថុមានក្លិន និងលំអិតជាដើម ។ - **ជាត** នចុំ. គន្ធជាត, គុ. មានក្លិនកើតហើយ ។ - **តណ្ហា** ឥ. សេចក្តីប្រាថ្នាក្នុងក្លិន ។ - **តេលប្បទីប** នចុំ. ប្រទីបដ៏ពេញដោយប្រេងមានក្លិន ។ - **បញ្ចង្គុលិក** គុ. កម្មដែលបុគ្គលធ្វើដោយម្រាម៥ គឺបុគ្គលចឹម (លាប, ចុច) ដោយវត្ថុមានក្លិន ។ - **បុប្ផាទិហត្ថ** គុ. មានវត្ថុមានក្លិន និងផ្កាជាដើមក្នុងដៃ ។ - **ភាជន** នចុំ. ភាជនៈសម្រាប់ដាក់នូវវត្ថុមានក្លិន, ភាជនៈសម្រាប់ដាក់នូវគ្រឿងក្រអូប ។ - **មាលា** ឥ. វត្ថុមានក្លិន និងផ្កាកម្រង, គ្រឿងក្រអូបនិងផ្កាកម្រង ។ - **មាលាទិបូជា** ឥ. កិ.បូជាដោយវត្ថុមានគ្រឿងក្រអូបនិងផ្កាកម្រងជាដើម, កិ.បូជាដោយវត្ថុមានវត្ថុមានក្លិន និងផ្កាកម្រងជាដើម ។ - **មាលាទិ-**



**ហត្ថ** គុ. មានវត្ថុមានក្លិននិងផ្កាកម្រងជាដើមក្នុងដៃ; វិ. **គន្ធោ ច មាលា ច> គន្ធមាលា, គន្ធមាលា អាទិ យស្ស តំ> គន្ធមាលាទិ, គន្ធមាលាទិ ហត្ថេសុ យេសំ តេ> គន្ធមាលាទិហត្ថា** ។ - **មាលាវត្ថភេសជ្ជាទិហត្ថ** គុ. មានវត្ថុមានក្លិន និងផ្កាកម្រង និងសំពត់ និងភេសជ្ជៈជាដើមក្នុងដៃ ។ - **រសលោភ** ចុំ. សេចក្តីលោភក្នុងក្លិននិងរស, សេចក្តីជាប់ចិត្តក្នុងក្លិននិងរស ។ - **វហិត** គុ. វៀរហើយចាកក្លិន, ប្រាសហើយចាកក្លិន ។ - **វាត** ចុំ. ខ្យល់ដ៏លាយដោយវត្ថុមានក្លិន, ខ្យល់ដែលលាយហើយដោយគ្រឿងក្រអូប ។ - **វាសបុប្ផធូប** នចុំ. វត្ថុមានក្លិន និងវត្ថុជាគ្រឿងអប់ និងផ្កា និងធូប, គ្រឿងក្រអូបនិងគ្រឿងអប់ និងផ្កា និងធូប ។ - **សាលិតណ្ឌុលភត្ត** នចុំ. ភត្តដែលបុគ្គលចំអិនដោយអង្ករ នៃស្រូវសាលីមានក្លិនក្រអូប ។ - **សេដ្ឋី** ចុំ. សេដ្ឋីឈ្មោះគន្ធៈ ។

**គន្ធកុដិ** ឥ. [ គន្ធ+កុដិ ] កុដិដែលគេប្រោះព្រំហើយដោយក្លិនដ៏ជាទិព្វ (គន្ធកុដិ); វិ. **ទិព្វគន្ធេហិ បរិភាវិតា កុដិ> គន្ធកុដិ** ។ - **ថូបិកា** ឥ. កំពូលនៃគន្ធកុដិ ។ - **ប្បមុខ** គុ. ទីចំពោះមុខនៃគន្ធកុដិ, ទីចំមុខនៃ... ។ - **អភិមុខ** គុ. ទីមានមុខឆ្ពោះទៅកាន់គន្ធកុដិ, ទីមានមុខបែរទៅកាន់គន្ធកុដិ ។

**គន្ធព្វ** ចុំ. [ គន្ធ+អព្វ+អ ] អ្នកបរិភោគនូវអាហារមានក្លិន, ម្យ៉ាងទៀតអ្នកកំរើកដោយអំណាចនៃល្បែងមានកិ.ច្រៀងនិងកិ.រាំជាដើមក្នុងឋានសួគ៌ (ជាឈ្មោះទេវបុត្តអ្នករបាំ); វិ. **គន្ធំ អព្វតិ**

**បរិភុញ្ជតិ> គន្ធព្វោ, គោម្ហិ សគ្គេ ធុនាតិ ភុម្ជតិ គាយននដ្ឋានាធិបសេនាតិ ថា> គន្ធព្វោ** ។ - **បូជា** ឥ. កិ.បូជាដោយល្បែង ឬដោយរបាំ, កិ.បូជានៃទេវបុត្តឈ្មោះគន្ធព្វ ។ - **មានុស** ចុំ. ប្រជុំនៃគន្ធព្វនិងមនុស្ស, គន្ធព្វនិងប្រជុំនៃមនុស្ស, គន្ធព្វនិងមនុស្ស ។

**គន្ធមាទន** ចុំ. [ គន្ធ+មទ ឬមុទ+យុ ] ភ្នំជាទីញ៉ាំងសត្វឱ្យស្រវឹងដោយវត្ថុមានក្លិន ឬភ្នំជាទីញ៉ាំងសត្វដែលចូលទៅឱ្យត្រេកអរដោយវត្ថុមានក្លិន (ភ្នំឈ្មោះគន្ធមាទនៈ); វិ. **គន្ធេហិ មទយតិ ឯកស្មិន្តិ> គន្ធមាទនោ, គន្ធេហិ មោទយតិ ឯតស្មិន្តិ> គន្ធមាទនោ** ។ - **បព្វតគមន** នចុំ. កិ.ទៅកាន់ភ្នំឈ្មោះគន្ធមាទនៈ ។ - **អភិមុខ** គុ. មានមុខឆ្ពោះទៅកាន់ភ្នំឈ្មោះគន្ធមាទនៈ ។

**គន្ធារ** ភ. ន. [ គំ+ធរ+ណ ] ដែនឈ្មោះគន្ធារៈ ។ - **កាសាវពោភ** ចុំ. កិ.បាននូវសំពត់កាសាវៈមានក្នុងដែនគន្ធារៈ, កិ.បាននូវសំពត់កាសាវៈដែលកើតក្នុងដែនគន្ធារៈ ។ - **កាសាវវត្ថ** នចុំ. សំពត់កាសាវៈមានក្នុងដែនឈ្មោះគន្ធារៈ, សំពត់កាសាវៈដែលជននាំមកហើយអំពីដែនឈ្មោះគន្ធារៈ ។

**គន្ធោទក** នចុំ. [ គន្ធ+ឧទក ] ទឹកមានក្លិន, ទឹកក្រអូប ។ - **ឃដ** ចុំ. ក្អមដីពេញដោយទឹកមានក្លិន, ក្អមដីពេញដោយទឹកក្រអូប; វិ. **គន្ធោទកេន បូរោ ឃដោ> គន្ធោទកឃដោ** ។

**គព្ភ** ចុំ. [ គភ+រភ, ផ្លាស់ ភនៃគភជា ព ] គភ៌, ពោះ, ផ្ទៃ, បណ្ដូល, បន្ទប់, ល្វែង ។ - **ទ្វារមូល** នចុំ. ទីជាទីតាំងនៃទ្វារនៃបន្ទប់, ទីជិតមាត់ទ្វារនៃបន្ទប់ ។ - **បរិបាក** ចុំ. កិ.ចាស់ជុំវិញនៃគភ៌ កិ.ចាស់នៃគភ៌ ។ - **បរិហារ** ចុំ. វត្ថុជាគ្រឿងនាំទៅជុំវិញនូវគភ៌, វត្ថុជាគ្រឿងរក្សានូវគភ៌, កិ.រក្សានូវគភ៌; វិ. **គព្ភំ បរិហរន្តិ ឯតេនាតិ> គព្ភបរិហារំ; គព្ភស្ស បរិហរណំ> គព្ភបរិហារោ** ។ - **បាតនភេសជ្ជ** នចុំ. ថ្នាំជាគ្រឿងញ៉ាំងគភ៌ឱ្យធ្លាក់, ថ្នាំសម្រាប់រំលូតនូវគភ៌ឬថ្នាំជាទីញ៉ាំងគភ៌ឱ្យធ្លាក់; (វិ. **គព្ភំ បាតេតិ ឯតេន ឯត្ថ ចាតិ> គព្ភបាតនំ**) ។ - **មំស** នចុំ. សាច់នៃគភ៌ ។ - **វាស** ចុំ. កិ.នៅក្នុងគភ៌ ។ - **វុដ្ឋាន** នចុំ. កិ.ចេញនៃគភ៌, កិ.ចេញនៃសត្វដែលកើតក្នុងគភ៌ (ការសម្រាលកូន) ។ - **សេតិ** នចុំ. របៀងនៃបន្ទប់, របៀងនៃល្វែង ។ - **សហាស្សប្បដិមណ្ឌិត** គុ. ប្រដាប់ចំពោះហើយដោយពាន់នៃបន្ទប់ ។ - **សហាស្ស** នចុំ. ពាន់នៃបន្ទប់, ល្វែង ។



**គព្ភាវក្កន្តិ** ឥ. [ គព្ភ+អវក្កន្តិ ] កិ.ឈានចុះកាន់គភ៌, កិ.ចុះកាន់គភ៌ (អវ+កម+តិ>អវក្កន្តិ ) ។

**គព្ភិនីភាវ** ចុំ. [ គព្ភិនី+ភាវ ] ភាវៈនៃ...ជាអ្នកមានគភ៌ (គព្ភិនី< គព្ភ+ណ្យ+ឥនី = **គព្ភោ យស្សា អត្ថីតិ> គព្ភិនី**) ។

**គព្ភិនីមិតី** ឥ. [ គព្ភិនី+ពិត ] បម្រើគមានគភ៌ ។

**គព្ភិនីវណ្ណ** ចុំ. [ គព្ភិនី+វណ្ណ ] ភេទនៃស្រីមានគភ៌ ។

**គមន** នចុំ. [ គម+យុ ] កិ.ទៅ, កិ.ដល់, កិ.លុះ, ដំណើរ; វិ. **គមនំ. គេតិ> គមនំ** ។ - **កម្ម** នចុំ. កម្មគឺកិ.ទៅ, កម្មដោយកិ.ទៅ,

កម្មជាទីទៅ ។ -កាលេ បុំ. កាលនៃគិ.ទៅ, កាលជាទីទៅ ។ -កិច្ច នបុំ. កិច្ចគឺគិ.ទៅ, កិច្ចដោយគិ.ទៅ ។ -ច្ឆន្ទ បុំ. សេចក្ដីពេញចិត្តក្នុងគិ.ទៅ, សេចក្ដីប្រាថ្នាដើម្បីគិ.ទៅ ។ -ដ្ឋាន នបុំ. ទីជាទីទៅ ។ -អត្ថ បុំ. ប្រយោជន៍ដល់គិ.ទៅ, សេចក្ដីត្រូវការដល់គិ.ទៅ ។ -តា ឥ. ភាវៈនៃគិ.ទៅ ។ -ទិវស បុំ., នបុំ. ថ្ងៃជាទីទៅ ។ -ទ្វារមត្ត គុ. ទីគ្រាន់តែទ្វារជាទីទៅ, ទីត្រឹមតែទ្វារជាទីទៅ ។ -ភាវ បុំ. ភាវៈគឺគិ.ទៅ, ។ -វេលា ឥ. វេលាជាទីទៅ ។ -សីលេ គុ. មានគិ.ទៅជាប្រក្រតី; វិ. **គមនំ សីលមស្សាតិ> គមនសីលោ** ។

**គមនាការ** បុំ. [ គមន+អាការ ] អាការគឺគិ.ទៅ, អាការនៃគិ.ទៅ ។

**គមនាគមន** នបុំ. [ គមន+អាគមន ] គិ.ទៅនិងគិ.មក, ជាទីទៅនិងជាទីមក ។ -មគ្គ បុំ. ផ្លូវជាទីទៅនិងផ្លូវជាទីមក ។

**គមនាភាវ** បុំ. [ គមន+អភាវ ] ការមិនបាននៃគិ.ទៅ ។

**គមិកវត្ត** នបុំ. [ គមិក+វត្ត ] វត្តគឺភិក្ខុគប្បីធ្វើដល់ភិក្ខុអ្នកគួរដើម្បីទៅ, -ដល់ភិក្ខុអ្នកដំណើរ; វិ. **គន្តុំ ភព្វោតិ> គមិកោ, គមិកស្ស ភាតព្វំ វត្តំ > គមិកវត្តំ** ។

**គមិត្វា** កិ. [ គម+អ+ឥ.អា.+ត្វា.បា. ] ទៅហើយ, ដល់ហើយ ។

**គមិស្សតិ** កិ. [ គម+អ+ឥ.អា.+ស្សតិ.ភ. ] នឹងទៅ ។

**គមិំសុ** កិ. [ គម+អ+ឥំសុ.អជ្ជ. ] ទៅហើយ ។



**គម្ភីរ** គុ. [ គម+ឦរ, គុរក.អា. ] ភាវៈប្រព្រឹត្តទៅដោយភាវៈមិនជាប់ជំពាក់ (ជ្រៅ, ជំរៅ); វិ. **គច្ឆតិ អគាធភាវេន បវត្តតីតិ> គម្ភីរោ** ។ -ចារី បុំ. អ្នកត្រាច់ទៅក្នុងទឹកដ៏ជ្រៅ, អ្នកមានគិ.ត្រាច់ទៅក្នុងទឹកដ៏ជ្រៅជាប្រក្រតី ។ -តា ឥ. ភាវៈនៃ...ជារបស់ជ្រៅ ។ -បញ្ញ គុ. អ្នកមានបញ្ញាដ៏ជ្រៅ ។ -បរិខា គុ. មានស្នាមភ្លោះដ៏ជ្រៅ, មានគូដ៏ជ្រៅ ។ -វត្តនី ឥ. ផ្លូវជាទីប្រព្រឹត្តទៅក្នុងទីដ៏ជ្រៅ, ផ្លូវជាទីប្រព្រឹត្តទៅក្នុងចំហុងដ៏ជ្រៅ, ផ្លូវដ៏ជ្រៅ, ចំហុងដ៏ជ្រៅ ។ -វិត្ថត គុ. ទាំងជ្រៅទាំងទទឹង ។ -រហទ បុំ. អន្លង់ដ៏ជ្រៅ ។

**គយាសីស** អ. ន. ប្រទេសឈ្មោះគយាសីសៈ ។

**គយ្ហមាន** គុ. [ គហ+យ+មាន ] គឺ... កាលកាន់យក, -កាលចាប់ ។

**គយ្ហុបគ** គុ. [ គយ្ហ+ឧប+គម+ក្វិ ] ចូលទៅជិតដល់នូវវត្ថុគឺបុ.គប្បីកាន់យក, -គឺបុ. គប្បីចាប់យកបាន; ចូលទៅជិតដល់នូវភាវៈជារបស់គឺបុ. គប្បីចាប់យកបាន ។

**គរហទិន្ន** អ. ន. ឈ្មោះគរហទិន្ន ។ -វត្ថុ បុំ. រឿងនៃសាវ័កនៃនិគ្រន្ថឈ្មោះគរហទិន្ន ។

**គរហន្តិ** កិ. [ គរហ+អ+អន្តិ.វ. ] តិះដៀល ។

**គរហភយភីត** គុ. [ គរហភយ+ភីត ] ខ្លាចហើយអំពីភ័យគឺសេចក្ដីតិះដៀល, ខ្លាចហើយព្រោះភ័យគឺសេចក្ដីតិះដៀល ។

**គរហាមិ** កិ. [ គរហ+អ+មិ.វ. ] តិះដៀល ។

**គរហិតព្វ** គុ. [ គរហ+ឥ_អា.+តព្វ ] គឺ... គប្បីតិះដៀល ។

**គរហិត** គុ. [ គរហ+ឥ_អា.+ត ] គឺ... តិះដៀលហើយ ។

**គរហិស្សតិ** កិ. [ គរហ+អ+ឥ_អា.+ស្សតិ_ភ. ] នឹងតិះដៀល ។

**គរហុប្បាទន** នកុំ. [ គរហ+ឧ+បទ+យុ ] កិ.ញុំាងសេចក្ដីតិះដៀលឱ្យកើតឡើង, កិ.ញុំាងដំណៀលឱ្យកើតឡើង ។

**គរុកត** គុ. [ គរុ+កត ] គឺ... ធ្វើហើយនូវសេចក្ដីគោរព, គឺ... ធ្វើឱ្យជាអ្នកគោរពហើយ, មានសេចក្ដីគោរពធ្វើហើយ ។

**គរុ** ពុំ. [ គរ+ឧ ] អាចារ្យអ្នកស្រោចនូវសេចក្ដីស្រឡាញ់ក្នុងសិស្សទាំងឡាយ (គ្រូ; គុ. ធ្ងន់); វិ. **សិស្សេសុ សិនេហំ គរតិ សិញ្ចតីតិ> គរុ** ។ អភិ. សូចិ មានន័យប្លែកពីនេះដោយច្រើន ។

**គរុក** គុ. [ គរុ+ក_ស. ] ធ្ងន់, ជាមធ្ងន់ ។

**គរុកាបត្តិ** ឥ. [ គរុក+អាបត្តិ ] អាបត្តិដ៏ធ្ងន់ ។

**គរុគព្ភ** គុ. [ គរុ+គព្ភ ] អ្នកមានគភ៌ធ្ងន់; វិ. **គរុ គព្ភោ យស្សា សា> គរុគព្ភា** ។ - **តា** ឥ. ភាវៈនៃ...នោះជាអ្នកមានគភ៌ធ្ងន់ ។

**គរុតរ** គុ. [ គរុ+តរ ] គ្រូវិសេសជាង, បុគ្គលអ្នកគួរគោរពជាង, ធ្ងន់ជាង ។

**គរុធម្ម** ពុ. [ គរុ+ធម្ម ] គរុធម៌ (ធម៌ដ៏ធ្ងន់, ធម៌គួរគោរព) ។



**គរុភារ** ពុំ. [ គរុ+ភារ ] ភារៈដ៏ធ្ងន់, ភារៈជាមធ្ងន់, មានភារៈដ៏ធ្ងន់ ។

**គរុឡ** ពុ. [ គរុ+លា+អ, លា>ឡា>ឡ ] សត្វកាន់យកនូវភារៈដ៏ធ្ងន់ (គ្រុឌ); វិ. **គរុំ ភារំ លាតិ អាទទាតិ គណ្ហាតីតិ> គរុឡោ** ។ ម្យ៉ាងទៀត (គរុឡ<គរ>គរុ+ហន+ណ, ផ្លាស់ហ>ឡ, លុបទីបំផុតធាតុនឹងណបច្ច័យ) សត្វបៀតបៀននូវពិស (គ្រុឌ); វិ. **គរំ វិសំ ហន្តីតិ> គរុឡោ** ។ - **បោតក** ពុំ. កូននៃគ្រុឌ ។

**គឡ** ពុំ. [ គល+អ ឬគិល+អ ] អវយវៈជាគ្រឿងស៊ី, ឬអវយវៈជាគ្រឿងលេបចូលទៅ (ក, បំពង់ក); វិ. **គលន្តិ អទន្តិ អជ្ឈោហរន្តិ អនេនាតិ> គលោ; គិលតិ អនេនាតិ វា> គលោ** ។ - **នាឡិ** ឥ. បំពង់នៃក ។ - **លោហិត** នកុំ. ឈាមក្នុងបំពង់ក, ឈាមនៃក ។ - **វាដក** ពុំ. បំពង់នៃក ។

**គឡប្បមាណ** គុ. [ គល+បមាណ ] មានកជាប្រមាណ, ប្រមាណត្រឹមក ។

**គឡិត្វា** អ. [ គល+ឥ_អា.+ត្វា ] ភ្លាត់ហើយ, រអិលហើយ, កំពាត់ហើយ ។

**គវេសក** ពុំ. [ គវេស+ណ្វុ ] អ្នកស្វែងរក; វិ. **គវេសតីតិ> គវេសកោ** ។

**គវេសថ** កិ. [ គវេស+អ+ថ_វ. ] ស្វែងរក ។

**គវេសន្តិ** កិ. [ គវេស+អ+អន្តិ_វ. ] ស្វែងរក ។

**គវេសន្ត** គុ. [ គវេស+អ+អន្ត ] កាលស្វែងរក, កំពុងស្វែងរក ។

**គវេសមាន** គុ. [ គវេស+អ+មាន ] កាលស្វែងរក,... ។

**គវេសិតា** ឥ. [ គវេសី+តា ] ភាវៈនៃ...នោះជាអ្នកស្វែងរក, ភាវៈនៃ...នោះជាអ្នកមានកិ.ស្វែងរកជាប្រក្រតី; វិ. **គវេសតីតិ> គវេសី, គវេសិតុំ សីលមស្សាតិ> គវេសី, គវេសិស្ស ភាវោ> គវេសិតា** ។

**គវេសិតុំ** អ. [ គវេស+ឥ.អា.+តុំ ] កិ.ស្វែងរក, ដើម្បីស្វែងរក ។

**គហការ** បុំ. [ គហ+ករ+ណ ] បុគ្គលអ្នកធ្វើនូវផ្ទះ, ជាងអ្នកធ្វើនូវផ្ទះ (ជាងផ្ទះ, ជាងផ្ទះគឺតណ្ហា); វិ. **គហំ ករោតីតិ> គហការោ** ។ – **គវេសន** នបុំ. កិ.ស្វែងរកនូវជាងអ្នកធ្វើនូវផ្ទះ ។

**គហកូដ** បុំ. [ គហ+កូដ ] កំពូលនៃផ្ទះ (កំពូលនៃផ្ទះគឺអវិជ្ជា) ។

**គហដ្ឋ** បុំ. [ គហ+ឋា+ក្វិ ] អ្នកតាំងនៅក្នុងផ្ទះ ឬ អ្នកឋិតនៅដោយអំណាចនៃសេចក្តីរីករាយក្នុងផ្ទះ ឬក្នុងកាមគុណ៥ (គ្រហស្ថ); វិ. **គេហេ គេហេ តិដ្ឋតីតិ> គហដ្ឋោ, គេហេ គេហេ បញ្ចកាមគុណេ វា រាគវសេន តិដ្ឋតីតិ វា> គហដ្ឋោ** ។

**គហណ** នបុំ. [ គហ+យុ ] កិ.កាន់, កិ.ចាប់, កិ.រៀន, កិ.ប្រកាន់, សេចក្តីប្រកាន់ ។ – **អត្ថ** បុំ. ប្រយោជន៍ដល់កិ.., ត្រូវការដល់កិ.., ។ – **និស្សិត** គុ. អាស្រ័យហើយនូវ... ។ – **សទិស** គុ. ប្រាកដស្មើដោយ... ។ – **សមយ** បុំ. សម័យជាទីរៀន ។ – **សង្ខាត** បុំ. ពោលគឺកិ.កាន់យក, ពោលគឺសេចក្តីប្រកាន់ ។



**គហណាភាវ** បុំ. [ គហណ+អភាវ ] ការមិនមាននៃកិ.កាន់យក, កិ.រិយាការនៃសេចក្តីប្រកាន់ ។

**គហន** នបុំ. [ គហ+យុ ] ព្រៃជាទីកាន់យកនូវវត្ថុមានធញ្ញសម្ភារៈជាដើមនៃមនុស្ស ឬព្រៃជាទីកាន់យកនូវទីជាលំនៅនៃខ្លួននៃសត្វមានក្ងោកជាដើម (ព្រៃ, ព្រៃស្បាត, គុ. ស៊ាំញ៉ាំ, ស្មុកស្មាញ); វិ. **គណ្ហន្តិ ឯត្ថ មនុស្សា ធញ្ញសម្ភារាទីនីតិ> គហនំ, គណ្ហន្តិ ឯត្ថ មយូរាទយោ សត្តា អត្តនោ និវាសត្ថានន្តិ វា> គហនំ** ។

**គហបតានី** ឥ. [ គហបតិ+ឥនី ] ស្រីជាម្ចាស់នៃផ្ទះ ។

**គហបតិ** បុំ. [ គហ+បតិ ] គហបតី, ជនជាម្ចាស់នៃផ្ទះ ។ – **បុត្ត** បុំ. កូននៃគហបតី ។ – **មហាសាលកុល** នបុំ. ត្រកូលនៃគហបតីមហាសាល, ត្រកូលនៃគហបតីជាមហាសាល (ត្រកូលនៃគហបតីអ្នកមានភោគៈជាសារៈដ៏ធំ) ។

**គហបតិក** បុំ. [ គហបតិ+ក.ស. ] គហបតី, គហបតីតូច ។

**គហិត** គុ. [ គហ+ឥ.អា.+ត ] គឺ...កាន់យកហើយ, គឺ...រៀនហើយ ។ – **កម្ម** នបុំ. កម្មគឺ....កាន់យកហើយ ។ – **កាល** បុំ. កាលនៃ... គឺ...កាន់យកហើយ ។ – **គហិតកហាបណ** បុំ. កហាបណៈដែល...កាន់យកហើយៗ ។ – **គហិតដ្ឋាន** នបុំ. ទីនៃ...គឺ...កាន់យកហើយៗ ។ – **ដ្ឋាន** នបុំ. ទីគឺ...កាន់យកហើយ ។ – **គហិតបទ** នបុំ. បទគឺ...កាន់យកហើយៗ, រៀនហើយ ។ – **គហិត** គុ.

គឺ...កាន់យកហើយៗ ។ - គេហ នបុំ. ផ្ទះគឺ...កាន់យកហើយ ។ - ត្ត នបុំ. ភាវនៃ...ជា....គឺ...កាន់យកហើយ ។ - នាមធេយ្យ បុំ. មានឈ្មោះគឺបុគ្គលទ្រទ្រង់កាន់យកហើយ, មានឈ្មោះគឺ...កាន់យកហើយ ។ - និមិត្ត នបុំ. និមិត្តគឺ....កាន់យកហើយ ។ - ប្បដិញ្ញ គុ. អ្នកមានសេចក្តីប្តេជ្ញាកាន់យកហើយ, អ្នកមានសេចក្តីប្តេជ្ញាគឺ...កាន់យកហើយ, អ្នកមានវាចាគឺបុ.គប្បីដឹងតប គឺ...កាន់យកហើយ ។ - បត្ត បុំ. ពាត្រគឺ...កាន់យកហើយ ។ - ភាជន នបុំ. ភាជនៈគឺ...កាន់យកហើយ ។ - ភាវ បុំ. ភាវៈនៃ...ជា...គឺ...កាន់យកហើយ ។ - មុខ នបុំ. មុខគឺ...កាន់យកហើយ ។ - សាខា ឥ. មែកគឺ...កាន់យកហើយ ។

**គហិតាវសេសក** គុ. [ គហិត+អវសេសក ] ជាចំណែកដ៏សេសចុះ គឺ...កាន់យកហើយ ។

**គហេតព្វ** គុ. [ គហ+អ+តព្វ ] គឺ...គប្បីកាន់យក ។ - គ្គហណ នបុំ. កិ.កាន់យកនូវវត្ថុដែលខ្លួនគប្បីកាន់យក ។ - បិណ្ឌ បុំ. បិណ្ឌៈគឺ... គប្បីកាន់យក, ដុំនៃបាយ ឬដុំនៃអាមិសៈគឺ...គប្បីកាន់យក ។ - យុត្តក គុ. គួរគឺ...គប្បីកាន់យក, គួរដល់វត្ថុជារបស់គឺ...គប្បីកាន់យក ។

**គហេតុំ** អ. [ គហ+អ+តុំ ] ដើម្បីកាន់យក, វីកិ.កាន់យក ។

**គហេត្វា** អ. [ គហ+អ+ត្វា ] កាន់យកហើយ, ចាប់ហើយ ។

**គហេស្សតិ** កិ. [ គហ+អ+ស្សតិ_ភ. ] នឹងកាន់យក, នឹងចាប់ ។



**គាហ** បុំ. [ គហ+អ ] កិ.ចាប់, កិ.កាន់យក, វិ. **គហណំ> គាហោ** ។

**គេឡោគីលតា** ឥ. [ គេឡោគី+លតា ] វល្លិជោម, វល្លិឈ្មោះ គេឡោចី ។

**គាថា** ឥ. [ គេ+ថ+អា_ឥ. ] សទ្ទជាតិនៃបុ. ពោល (គាថា); វិ. **គិយតិ កថិយតីតិ> គាថា** ។ - បទ នបុំ. បទនៃគាថា, បទគឺគាថា ។ - បរិយោសាន នបុំ. កាលជាទីបំផុតចុះជុំវិញនៃគាថា ។ - មត្ត គុ. ពាក្យត្រឹមតែគាថា ។ - ភេទ បុំ. សេចក្តីផ្សេងនៃគាថា ។ - មត្ត គុ. ពាក្យត្រឹមតែគាថា, ពាក្យមានគាថាជាប្រមាណ ។ - វសាន នបុំ. (<គាថា+អវសាន) កាលជាទីបំផុតចុះនៃគាថា ។ - វចន នបុំ. ពាក្យនៃគាថា ។

**គាធ** បុំ. [ គាធ+អ ] ការស្ទង់ចុះ, ការតាំងនៅ, ការតាំងមុក, សេចក្តីលោភ, សេចក្តីចង់បាន, ទីពឹង, លំនៅ, រន្ធ ។

**គាម** បុំ. [ គស+ម ឬគេ+ម ] ប្រទេសជាទីបរិភោគនៃជន ឬប្រទេសជាទីពោលនៃជន (ស្រុក); វិ. **គសន្តិ ឯត្ថាតិ> គាមោ, គាយន្តិ ឯត្ថាតិ វា> គាមោ** ។ - កម្មករណដ្ឋាន នបុំ. ទីជាទីធ្វើនូវកម្មក្នុងស្រុក ។ - ការាម បុំ. (<គាមក+អារាម) អារាមជិតស្រុកតូច ។ - ក្ខេត្តទ្វិបទចតុប្បទយានវាហន នបុំ. ស្រុកនិងខេត្ត (ស្រែ) និងសត្វមានជើងពីរ និងសត្វមានជើង ៤ និងយាន និងវាហនៈ ។ - កាវាស បុំ. អាវាសជិតស្រុកតូច, អាវាសតាំងនៅជិតស្រុក ។ - កិច្ច នបុំ. កិច្ចនៃស្រុក, កិច្ចក្នុងស្រុក ។ - គត គុ. ទៅហើយកាន់ស្រុក ។ - ឃាតកាទិ គុ.

(ទុច្ចរិត) មានកិ.សម្លាប់នូវអ្នកស្រុកជាដើម, (កម្ម) មានកម្មនៃបុ. អ្នកសម្លាប់នូវអ្នកស្រុកជាដើម ។ - **ឃាតាទិកម្ម** នថុំ. កម្មមានកិ.សម្លាប់នូវអ្នកស្រុកជាដើម, កម្មមានកម្មនៃបុ. អ្នកសម្លាប់នូវអ្នកស្រុកជាដើម ។ - **ទារក** ថុំ. ទារកនៃអ្នកស្រុក ។ - **និគម-ជនបទរាជធានី** ឥ. ស្រុកនិងនិគម និងជនបទ និងរាជធានី ។ - **អន្តរ** នថុំ. ចន្លោះនៃស្រុក, រវាងនៃស្រុក, លង្វែកនៃស្រុក ។ - **អន្ត** ថុំ. ទីបំផុតនៃស្រុក, ចុងនៃស្រុក ។ - **ភោជក** ថុំ. ជនអ្នកបរិភោគនូវស្នួយក្នុងស្រុក, គាមភោជក (ចៅហ្វាយស្រុក ឬមេស្រុក); វិ. **គាមេ សុង្កំ ភុញ្ជតីតិ> គាមភោជកោ** ។ - **មក្ខិកា** ឥ. រុយក្នុងស្រុក, រុយស្រុក ។ - **មជ្ឈ** នថុំ. កណ្ដាលនៃស្រុក ។ - **វរ** ថុំ. ស្រុកគឺបុ. គប្បីប្រាថ្នា, ស្រុកស្អួយ, ស្រុកដ៏ប្រសើរ ។ - **វាសី** ថុំ. អ្នកនៅក្នុងស្រុក, អ្នកមានកិ.នៅក្នុងស្រុកជាប្រក្រតី ។ - **សត** នថុំ. រយនៃស្រុក ។ - **សូករបោតក** ថុំ. កូននៃជ្រូកស្រុក ។

**គាមណិ** ថុំ. [ គាម+នី, និ>ណិ+អ ] ជនអ្នកនាំទៅនូវស្រុក (មេភូមិ, មេស្រុក, នាយស្រុក, ជាធំ, ជាប្រធាន); វិ. **គាមំ នេតីតិ> គាមណិ** ។

**គាមាភិមុខ** គុ. [ គាម+អភិមុខ ] មានមុខឆ្ពោះទៅកាន់ស្រុក, មានមុខសំដៅទៅកាន់ស្រុក, មានមុខបែរទៅកាន់ស្រុក ។

**គាមិក** គុ. [ គាម+ណិក ] អ្នកនៅក្នុងស្រុក; វិ. **គាមេ ចរតីតិ> គាមិកោ** ។ - **មនុស្ស** ថុំ. មនុស្សអ្នកនៅក្នុងស្រុក (មនុស្ស



ស្រុកក្រៅ) ។

**គាមុបចារ** ថុំ. [ គាម+ឧបចារ ] ឧបចារៈនៃស្រុក, ទីជាទីត្រាច់ទៅជិតនៃស្រុក, ជុំរបស់ស្រុក ។

**គាយតិ** កិ. [ គេ+អ+តិ_វ. ] ច្រៀង ។

**គាយថ** កិ. [ គេ+អ+ថ_វ. ] ច្រៀង ។

**គាយន** នថុំ. [ គេ+យុ ] កិ.ច្រៀង, ជាទីច្រៀង; វិ. **គាយតេតិ> គាយនំ, គាយតិ ឯត្ថាតិ> គាយនំ** ។ - **ដ្ឋាន** នថុំ. ទីជាទីច្រៀង ។ - **ភាវ** ថុំ. ភាវៈនៃកិ.ច្រៀង, ភាវៈគឺកិ.ច្រៀង ។

**គាយន្ត** គុ. [ គេ+អ+អន្ត ] កាលច្រៀង, កំពុងច្រៀង ។

**គាយន្តិ** កិ. [ គេ+អ+អន្តិ_វ. ] ច្រៀង, រមែងច្រៀង ។

**គាយមាន** គុ. [ គេ+អ+មាន ] កាលច្រៀង, កំពុងច្រៀង ។

**គាយសិ** កិ. [ គេ+អ+សិ_វ. ] ច្រៀង ។

**គាយាបេតិ** កិ. [ គេ+ណាបេ+តិ_វ. ] ឱ្យច្រៀង, ញុំាង...ឱ្យច្រៀង ។

**គាយិ** កិ. [ គេ+អ+ឦ_អជ្ជ. ] ច្រៀងហើយ ។

**គាយិត** គុ. [ គេ+ឥ_អា.+ត ] គឺ...ច្រៀងហើយ ។

**គាយិត្វា** អ. [ គេ+ឥ_អា.+ត្វា ] ច្រៀងហើយ ។

**គាយិស្សតិ** កិ. [ គេ+អ+ឥ_អា.+ស្សតិ_ភ. ] នឹងច្រៀង ។

**គារវ** នពុំ. ពុំ. [ គរុ+ណ ] ភាវៈនៃសេចក្ដីគោរព ឬ សេចក្ដីគោរព; វិ. **គរុស្ស ភាវោ> គារវំ, គរុ ឯវ ចា> គារវោ** ។

**គាវី** ឥ. [ គម+ណ្វី ] សត្វតែងដើរទៅ (មេគោ), វិ. **គច្ឆតីតិ> គាវី** ។

**គាវីរបដ្ឋន** នពុំ. [ គាវីរ+បដ្ឋន ] កំពង់ឈ្មោះគាវីរៈ, កំពង់ជាទីចតឈ្មោះគាវីរៈ ។

**គាវុតិកនិធិកុម្ភី** ឥ. [ គាវុតិក+និធិកុម្ភី ] ឆ្នាំងដ៏ពេញដោយទ្រព្យដីបុ. គប្បីកប់ទុកមានគាវុតជាប្រមាណ, ឆ្នាំងដ៏ពេញដោយកំណប់ទ្រព្យ មានគាវុតជាប្រមាណ, ឆ្នាំងកំណប់មានគាវុតជាប្រមាណ ។

**គាវុតប្បមាណ** គុ. [ គាវុត+បមាណ ] មានគាវុតជាប្រមាណ, ប្រមាណមួយគាវុត ។

**គាវោ** ពុំ. [ គោ+ពហុ.វិ. ] វីគោទាំងឡាយ, នូវ...។

**គាហ** ពុំ. [ គហ+ណ ] កិ.កាន់យក, កិ.ចាប់, សេចក្ដីប្រកាន់; វិ. **គហណំ> គាហោ** ។

**គាហាបិត** គុ. [ គហ+ណាបេ+ឥ_រក.+ត ] គឺ...ញ៉ាំង...ឱ្យចាប់ហើយ; វិ. **គាហាបិយិត្ថាតិ> គាហាបិតោ** ។

**គាហាបេត្វា** អ. [ គហ+ណាបេ+ត្វា ] ញ៉ាំង...ឱ្យចាប់ហើយ, ឱ្យកាន់យកហើយ ។

**គាហាបេស្សន្តិ** កិ. [ គហ+ណាបេ+ស្សន្តិ_ភ. ] នឹងញ៉ាំង...ឱ្យកាន់យក ។



**គាឡ្ហ** គុ. [ គហ+ត ] មាំ, ដ៏មាំ ។ - **ពន្ធន** នពុំ. វត្ថុជាគ្រឿងចងដ៏មាំ, កិ.ចងដ៏មាំ, ចំណងដ៏មាំ ។ - **វគ្គ** គុ. មានកិ.រក្សាដ៏មាំ ។

**គិជ្ឈកូដ** ពុំ. [ គិជ្ឈ+កូដ ] ភ្នំគិជ្ឈកូដ, ភ្នំមានកំពូលប្រាកដស្មើដោយត្មាត, ភ្នំមានកំពូលដូចជាត្មាត ។ - **មត្ថក** ពុំ. ទីបំផុតនៃភ្នំគិជ្ឈកូដ, កំពូលនៃភ្នំគិជ្ឈកូដ ។ **គិជ្ឈ**<គិធ+យ, ផ្លាស់ធ+យ>ឈ, ត្មាត ។

**គិម្ហ** ពុំ. [ គិរ+ម, ផ្លាស់រ>ហ ] គិម្ហរដូវ, រដូវក្ដៅ ។ - **កាល** ពុំ. កាលនៃរដូវក្ដៅ, កាលប្រកបដោយរដូវក្ដៅ, កាលគឺរដូវឈ្មោះគិម្ហៈ ។

**គិរគ្គសមជ្ជ** ពុំ. [ គិរគ្គ+សមជ្ជ ] (មហោស្រពគឺ បុ. គប្បីលេងលើកំពូលនៃភ្នំ; វិ. **គិរិស្ស អគ្គំ> គិរគ្គំ, គិរគ្គេ កីឡិតព្វោ សមជ្ជោ> គិរគ្គសមជ្ជោ** ។

**គិរា** ឥ. [ គេ+អ ] វាចាជាទីពោល ឬ វាចាគឺបុ.គប្បីពោល (ពាក្យ, សំដី); វិ. **គិរន្តិ សទ្ទាយន្តិ ឯត្ថ> គិរា, គាយិតព្វាតិ ចា> គិរា** ។

**គិរីកន្ទរា** ឥ. [ គិរី+កន្ទរ ] ជ្រោះនៃភ្នំ, ច្រកនៃភ្នំ ។

**គិលាន** គុ. [ គិល+អានុ ] កាយដែលលំបាក (ឈឺ, ជម្ងឺ); វិ. **គិលាយតិ គិលមតីតិ> គិលានោ** ។ - **ឧបដ្ឋាក** ពុំ. នពុំ. អ្នកបំរើនូវជម្ងឺ; វិ. **គិលានំ ឧបដ្ឋាតីតិ> គិលានុបដ្ឋាកោ** ។ - **ឧបដ្ឋាន** នពុំ. កិ.បំរើនូវជម្ងឺ, កិ.បំរើនូវបុ.អ្នកឈឺ, នូវអ្នកជម្ងឺ; វិ. **គិលានស្ស ឧបដ្ឋានំ> គិលានុបដ្ឋានំ** ។

**- អាលយ** ចុំ. ពុតជាឈើ, ពុតនៃបុគ្គលឈើ, កិ.បញ្ឆោតជាឈើ ។

**គិលិត** គុ. [ គិល+ឥ_អា.+ត ] គឺ...លេបហើយ, _ស៊ីហើយ ។

**គិលិត្វា** អ. [ គិល+ឥ_អា.+ត្វា ] លេបហើយ ។

**គិហិ** ចុំ. [ គហ+ឦ, ឦ>ឥ ] ជនអ្នកមានផ្ទះ (គហស្ថ); វិ. **គហមេកស្សាត្ថិ> គិហិ** ។ **- កាល** ចុំ. កាលនៃ...ជាគ្រហស្ថ ។ **- និយាម** ចុំ. ទំនងនៃគ្រហស្ថ, បែបនៃគ្រហស្ថ ។ **- បព្វជិត** ចុំ. គ្រហស្ថនិងបព្វជិត ។ **- ព្រាហ្មណ** ចុំ. ព្រាហ្មណ៍ជាគ្រហស្ថ ។ **- ភាវ** ចុំ. ភាវៈនៃ...ជាគ្រហស្ថ, ភាវៈនៃគ្រហស្ថ ។ **- ភោគ** ចុំ. ភោគៈរបស់គ្រហស្ថ ។ **- លិង្គ** នចុំ. ភេទនៃគ្រហស្ថ ។ **- សម្បត្តិ** ឥ. សម្បត្តិនៃគ្រហស្ថ ។ **- ភូត** គុ. ជាគ្រហស្ថ, ជាគ្រហស្ថកើតហើយ ។

**គីត** នចុំ. [ គេ+ត ] ចំនុកគីបុ. គប្បីច្រៀង ឬកិ.ច្រៀង, ចម្រៀង, វិ. **គេយព្វន្តិ> គីតំ, គាយនំ វា> គីតំ** ។ **- កាល** ចុំ. កាលនៃចម្រៀងគឺ...ច្រៀងហើយ ។ **- បដិគីត** នចុំ. កិ.ច្រៀងនិងកិ.ច្រៀងត, កិ.ច្រៀងតនូវកិ.ចម្រៀង, ចម្រៀងតនូវចម្រៀង ។ **- សទ្ទ** ចុំ. សម្លេង ឬ សូរនៃកិ.ច្រៀង, សម្លេងនៃចម្រៀងគឺ...គប្បីច្រៀង ។

**គីវា** ឥ. [ គា+វ្វ ] អវយវៈជាគ្រឿងពោល (ក, សំណាង); វិ. **គាយន្តិ ឯតាយាតិ> គីវា** ។



**គុណក** ចុំ. [ គុណ+ក ] សភាវធម៌ដែលចំរើនឡើងដោយលក្ខណៈរបស់ខ្លួន, ឬសភាវធម៌ជាគ្រឿងប្រកាសនូវលក្ខណៈរបស់ខ្លួន ឬសភាវធម៌ដែលបុ. គួរសន្សំ (គុណ, សេចក្ដីចំរើន, ថ្នាក់, ជាន់, លក្ខណៈ, ចំណែក, សេចក្ដីល្អ) ។ **- កថា** ឥ. វាចាជាគ្រឿងពោលនូវគុណ ឬវាចាជាគ្រឿងពោលប្រារព្ធនូវគុណ; វិ. **គុណំ កថេតិ ឯតាយាតិ> គុណកថា, គុណេ អារព្ភ កថេតិ ឯតាយាតិ វា> គុណកថា** ។ **- ឃោស** ចុំ. សម្លេងដ៏គឹកកងនៃគុណ, សម្លេងដ៏គឹកកងដោយគុណ, សម្លេងជាគ្រឿងគឹកកងដោយគុណ ។ **- តេជ** ចុំ. តេជៈនៃគុណ ។ **- ទេសនា_បរិយត្តិនិស្សត្តវស** ចុំ. អំណាចនៃគុណធម៌ និងទេសនាធម៌ និងបរិយត្តិធម៌ និងនិស្សត្តធម៌ ។ **- ទោស** ចុំ. គុណនិងទោស ។ **- ធំសនតា** ឥ. ភាវៈគឺកិ.កំចាត់បង់នូវគុណ, ភាវៈនៃកិ.កំចាត់នូវគុណ ។ **- មហន្តត្ត** នចុំ. ភាវៈនៃ...ជាអ្នកមានគុណធំ; វិ. **គុណោ មហន្តោ យស្ស សោ> គុណមហន្តោ, គុណមហន្តស្ស ភាវោ> គុណមហន្តត្តំ** ។ **- វុឌ្ឍ** គុ. អ្នកចំរើនដោយគុណ, អ្នកមានគុណដ៏ចំរើន ។ **- សមុទយ** ចុំ. (<សំ+ឧ+អយ+អ, ចុះឋ_អា.) ធម៌ជាដែនតាំងឡើងព្រមនៃគុណ, ធម៌ជាដែនតាំងឡើងព្រមគឺគុណ, ធម៌ជាដែនកើតឡើងនៃគុណ ។ **- សម្បន្ន** គុ. អ្នកដល់ព្រមហើយដោយគុណ, អ្នកមានគុណដល់ព្រមហើយ; វិ. **គុណេន សម្បន្នោ> គុណសម្បន្នោ, គុណោ សម្បន្នោ យស្ស សោ> គុណសម្បន្នោ** ។

**គុណវន្ត** គុ. [ គុណ+វន្តុ ] អ្នកមានគុណ; វិ. **គុណោ យេសម-ត្ថីតិ> គុណវន្តោ** ។

**គុណាតិរេកសម្បទា** ឥ. [ គុណាតិរេក+សម្បទា ] ធម្មជាតិជាគ្រឿងដល់ព្រមដោយទក្ខិណេយ្យបុគ្គលអ្នកមានគុណដ៏ក្រៃលែង, កិ.ដល់ព្រមគឺ ទក្ខិណេយ្យបុគ្គលអ្នកមានគុណដ៏ច្រើន ។

**គុណិត** គុ. [ គុណ+ឥ.អា.+ត ] ដែល...គុណហើយ, ..ទ្វេហើយ, រាប់ហើយ ។

**គុត្ត** គុ. [ គុប+ត ] អ្នកគ្រប់គ្រង, គឺ...គ្រប់គ្រងហើយ ។ - **តា** ឥ. ភាវៈនៃ....ជា...គឺ...គ្រប់គ្រងហើយ ។ - **ទ្វារ** គុ. អ្នកមានទ្វារគ្រប់គ្រងហើយ; វិ. **គុត្តំ ទ្វារំ យេន សោ> គុត្តទ្វារោ** ។

**គុត្តិ** ឥ. [ គុប+តិ ] កិ.គ្រប់គ្រង, កិ.រក្សា; វិ. **គោបនំ> គុត្តិ** ។

**គុម្ពបិដ្ឋិ** នបុំ. [ គុម្ព+បិដ្ឋិ ] ខ្នងនៃគុម្ពឈើ, ខាងក្រោយនៃគុម្ពឈើ ។

**គុម្ពមូល** នបុំ. [ គុម្ព+មូល ] ប្រទេសជាទីតាំងនៃគុម្ពឈើ, ទីជិតនៃគុម្ពឈើ ។

**គុម្ពាភិមុខ** គុ. [ គុម្ព+អភិមុខ ] មានមុខឆ្ពោះទៅកាន់គុម្ពឈើ ។

**គុយ្ហភណ្ឌក** នបុំ. [ គុយ្ហ+ភណ្ឌ+ក ] ភណ្ឌៈគឺបុ. គប្បីលាក់, ភណ្ឌៈគឺអវយវៈដែលបុ. គប្បីលាក់, ភណ្ឌៈគឺគុយ្ហប្រទេស ។

**គុយ្ហប្បដិច្ឆន្ន** គុ. [ គុយ្ហ+បដិច្ឆន្ន ] ទាំងគឺបុ. គប្បីលាក់ទាំងគឺបុ. គប្បីបិទបាំង, បិទបាំងហើយនូវអវយវៈគឺបុ. គប្បីលាក់ ។



**គុហាសយ** បុំ. [ គុហា+អាសយ ] អាស្រ័យនូវមហាភូតរូបដូចជាគុហា, អាស្រ័យនូវហទយរូបហើយប្រព្រឹត្តទៅ ។

**គុឡ** បុំ. [ គុឡ+អ ] ស្ករអំពៅ, ដុំ, សំណុំ, អង្គញ់ ។ - **កីឡា** ឥ. កិ. លេងនូវអង្គញ់ ។ - **បិណ្ឌ** បុំ. ដុំនៃស្ករអំពៅ ។ - **មណ្ឌល** នបុំ. កណ្ដួរជាទីលេងនូវអង្គញ់ ។

**គូថ** បុំ. [ គូថ+អ ] សភាវៈដែលជនបិទបាំងព្រោះភាវៈនៃវត្ថុនោះជារបស់បដិកូល (គូថ, លាមក, អាចម៍); វិ. **បដិកូលត្តា គោបិយតីតិ> គូថោ** ។ - **អាវាដ** បុំ. រណ្ដៅដ៏ពេញដោយលាមក ។ - **កលល** នបុំ. ភក់ដ៏លាយហើយដោយលាមក; វិ. **គូថេហិ សំសដ្ឋំ កលលំ> គូថកលលំ** ។ - **កូប** បុំ. រណ្ដៅដ៏ពេញដោយលាមក ។ - **និរយ** នបុំ. នរកដ៏ពេញដោយលាមក, គូថនរក ។ - **បិណ្ឌ** បុំ. ដុំនៃលាមក, ដុំនៃគូថ ។ - **ភក្ខ** គុ. មានលាមកជាចំណី, មានលាមកជារបស់ស៊ី, មានលាមកជាភក្សាហារ ។ - **សូករបោតិកា** ឥ. កូននៃជ្រូកស៊ីនូវលាមក ។

**គេណ្ឌុក** បុំ. [ គុឌ+ណុក ឬគុទ+ណុក ] ធ្នុក, កូនឃ្លី ។

**គេធវស** បុំ. [ គេធ+វស ] អំណាចនៃសេចក្ដីត្រេកអរ, ..សេចក្ដីជាប់ចិត្ត ។

**គេយ្យ** នបុំ. [ គេ+ណ្យ ] គេយ្យៈ, ពាក្យគឺបុ. ដើម្បីច្រៀង ។

**គេហ** នបុំ. បុំ. [ គហ+អ, ផ្លាស់អនៃគជាឯ ] (សេនាសនៈ) កាន់យកនូវគ្រឿងសម្ភារៈ (ផ្ទះ); វិ. **ឆព្វសម្ភារេ គណ្ហាតីតិ> គេហំ** ។

- **ករណត្ថ** បុំ. ប្រយោជន៍ដល់កិ.ធ្វើនូវផ្ទះ, ត្រូវការដល់កិ.ធ្វើនូវផ្ទះ ។ - **គមនភាវ** បុំ. ភាវៈនៃកិ.ទៅកាន់ផ្ទះ, ។ - **គោបកមត្ត** តុ. ត្រឹមតែជនអ្នកគ្រប់គ្រងនូវផ្ទះ, ត្រឹមតែជនអ្នកចាំនូវផ្ទះ (គេហគោបក<គេហ+គុប+ណ្វុ = វិ. **គេហំ គោបេតីតិ> គេហគោបកោ**) ។ - **ច្ឆាយា** ឥ. ស្រមោលនៃផ្ទះ, ម្លប់នៃផ្ទះ ។ - **ជន** បុំ. ជនក្នុងផ្ទះ, ជនអ្នកនៅក្នុងផ្ទះ ។ - **ឈាបនភយ** នបុំ. ភ័យ (សេចក្តីខ្លាច) អំពីកិ.ឆេះនូវផ្ទះ ។ - **ដ្ឋាន** នបុំ. ទីនៃផ្ទះ, ទីជាទីតាំងនៃផ្ទះ, ទីជាទីធ្វើនូវផ្ទះ ។ - **ទាសី** ឥ. ទាសីក្នុងផ្ទះ, ខ្ញុំស្រីក្នុងផ្ទះ ។ - **បច្ឆាភាគ** បុំ. ប្រទេសជាចំណែកខាងក្រោយនៃផ្ទះ (កន្លៀនៃផ្ទះ) ។ - **បរិក្ខារ** បុំ. បរិក្ខារនៃផ្ទះ, បរិក្ខារក្នុងផ្ទះ ។ - **បវិសនកាល** បុំ. កាលជាទីចូលទៅកាន់ផ្ទះ, កាលនៃកិ.ចូលទៅកាន់ផ្ទះ ។ - **បវេសនមង្គល** នបុំ. មង្គលគឺកិ.ចូលទៅកាន់ផ្ទះ, មង្គលគឺបុ.គប្បីធ្វើក្នុងកាលជាទីចូលទៅកាន់ផ្ទះ, មង្គលជាទីចូលទៅកាន់ផ្ទះ ។ - **ភិត្តិ** ឥ. ជញ្ជាំងនៃផ្ទះ ។ - **ភិត្តិអាទិ** តុ. (ទី) មានជញ្ជាំងនៃផ្ទះជាដើម ។ - **មជ្ឈ** នបុំ. កណ្តាលនៃផ្ទះ ។ - **មានុសក** បុំ. ប្រជុំនៃមនុស្សក្នុងផ្ទះ, ពួកនៃមនុស្សក្នុងផ្ទះ; វិ. **មនុស្សានំ សមូហោ> មានុសកោ** (មនុស្ស+កណ) ។ - **រក្ខទារក** បុំ. ទារកអ្នករក្សានូវផ្ទះ, បុគ្គលអ្នករក្សានូវផ្ទះ និងទារក, ក្មេងចាំនូវផ្ទះ, មនុស្សអ្នកចាំនូវផ្ទះ និងក្មេង ។ - **រក្ខិក** តុ. អ្នករក្សានូវផ្ទះ ។ - **មត្ថក** បុំ. ទីបំផុតនៃផ្ទះ, កំពូលនៃផ្ទះ ។ - **សណ្ឋានាទិវស** បុំ. អំណាចនៃសណ្ឋានមានសណ្ឋាននៃផ្ទះជាដើម, អំណាចនៃ



សណ្ឋានៈ មានសណ្ឋានដូចជាសណ្ឋាននៃផ្ទះជាដើម, អំណាចនៃទ្រង់ទ្រាយមានទ្រង់ទ្រាយនៃផ្ទះជាដើម ។ - **សមីប** តុ. ទីជិតនៃផ្ទះ ។ - **សម្បត្តិ** ឥ. សម្បត្តិគឺផ្ទះ សម្បត្តិក្នុងផ្ទះ ។ - **សាមន្ត** តុ. ទីជិតនៃផ្ទះ ។ - **សាមិក** បុំ. ជនជាម្ចាស់នៃផ្ទះ ។ - **សាមន្ត** តុ. ទីជិតនៃផ្ទះ ។ - **សាមិក** បុំ. ជនជាម្ចាស់នៃផ្ទះ ។

**គេហាភិមុខ** តុ. [ គេហ+អភិមុខ ] មានមុខឆ្ពោះទៅកាន់ផ្ទះ, មានមុខបែរទៅកាន់ផ្ទះ ។

**គេហាភិមុខី** តុ. [ គេហាភិមុខ+ណី ] ប្រែដូច«គេហាភិមុខ» ។

**គោ** បុំ. ឥ. [ គម+ក្វិប្ប ] (សត្វ)តែងដើរទៅ (គោ); វិ. **គច្ឆតីតិ> គោ** ។ - **អាជានីយ** បុំ. គោអាជានេយ្យ, គោដឹងនូវហេតុនិងមិនមែនហេតុដោយក្រៃលែង, គោអាចក្នុងកិ.ដឹងនូវកិច្ចដ៏ប្រសើរ (ចូរមើល អាជានីយ ភាគទី១) ។ - **គណជេដ្ឋក** តុ. ចំរើនបំផុតជាងពួកនៃគោ, ជាច្បងក្នុងហ្វូងនៃគោ, ជាច្បងជាងហ្វូងនៃគោ ។ - **គណ** បុំ. ពួកនៃគោ, ហ្វូងនៃគោ ។ - **មហឹសទាសីទាសខេត្តវត្ថុគាមនិគមជនបទាទិ** តុ. (សត្វនិងសង្ខារ) មានគោ និងក្របី និងទាសី និងទាសៈ និងខេត្ត និងវត្ថុ និងស្រុក និងនិគម និងជនបទជាដើម (ខេត្ត = ស្រែ, ចំការ, វត្ថុ = ទីនៅ, ទីដី, ទីភូមិ) ។

**គោឃាតក** បុំ. [ គោ+ហន+ណ្វុ ] (ជន) អ្នកសម្លាប់នូវគោ; វិ. **គាវោ ហនតីតិ> គោឃាតកោ** ។ - **កម្ម** នបុំ. កម្មនៃជនអ្នកសម្លាប់នូវគោ ។ - **បុត្ត** បុំ. កូននៃជនអ្នកសម្លាប់នូវគោ ។

. **បុត្តវត្ថុ** នបុំ. រឿងនៃកូននៃជនអ្នកសម្លាប់នូវគោ ។

**គោចរ** បុំ. [ គោ+ចរ+អ ] (សភាវៈ) ជាទីប្រព្រឹត្តទៅនៃឥន្ទ្រិយ (គោចរ, អារម្មណ៍, ចំណី); វិ. **គោ ចរតិ បវត្តតិ ឯត្ថាតិ> គោចរោ** ។ ម៉្យាងទៀត អាហារគឺសត្វគប្បីបានក្នុងទីជាទីត្រេចទៅដូចជាទីត្រាច់ទៅនៃគោ ។ . **គ្គាម** បុំ. គោចរគ្រាម (ស្រុកជាទីត្រាច់ទៅដូចទីជាទីត្រាច់ទៅនៃគោ) ។ . **អជ្ឈត្តសង្ខាត** គុ. ពោលគឺធម៌ជាខាងក្នុងជាអារម្មណ៍, ពោលគឺធម៌ប្រព្រឹត្តទៅក្នុងខាងក្នុងជាអារម្មណ៍ជាទីចរទៅនៃឥន្ទ្រិយ ។ . **ភូមិ** ឥ. គោចរភូមិ, ភូមិជាទីត្រាច់ទៅនៃគោ ។ . **សម្បជញ្ញ** នបុំ. សេចក្តីដឹងច្បាស់គឺអារម្មណ៍, សេចក្តីដឹងច្បាស់គឺអារម្មណ៍ជាទីចរទៅនៃឥន្ទ្រិយ, សេចក្តីដឹងច្បាស់ដោយអំណាចនៃអារម្មណ៍, សេចក្តីដឹងច្បាស់ដោយអំណាចនៃអារម្មណ៍ជាទីចរទៅនៃឥន្ទ្រិយ ។ . **សម្បន្ន** គុ. មានគោចរដល់ព្រមហើយ, ដល់ព្រមហើយដោយគោចរ, ដល់ព្រមហើយដោយចំណី ។ . **សង្ខាត** គុ. ពោលគឺអារម្មណ៍, ពោលគឺធម៌ជាទីត្រាច់ទៅនៃឥន្ទ្រិយ ។

**គោណ** បុំ. [ គម+យុ ] (សត្វ) តែងដើរទៅ (គោ); វិ. **គច្ឆតីតិ> គោណោ** ។ . **ជាតិ** ឥ. ជាតិនៃគោ ។ . **សកដាទិ** (វត្ថុ) មានគោនិងរទេះជាដើម ។

**គោតម** បុំ. [ គោតម+ណ ] ជនជាកូនចៅនៃមុនីឈ្មោះគោតម (សមណៈឈ្មោះគោតម, ព្រះពុទ្ធជាគោតម); វិ. **គោតមស្ស មុនិនោ អបច្ចំ> គោតមោ** ។ . **គោត្ត** នបុំ. គោតមគោត្រ, គោត្រនៃជនឈ្មោះគោតមៈ ។ . **សាវក** បុំ. សាវ័កនៃព្រះពុទ្ធជាគោតម ។



**គោតមី** ឥ. [ គោតម+ណ+ឦ ] ស្រីជាពូជពង្សនៃគោតម (ឈ្មោះគោតមី); វិ. **គោតមស្ស អបច្ចំ> គោតមី** ។

**គោធា** ឥ. [ គុធ+អ+អា.ឥ. ] ទន្សង ។ . **បណ្ឌិត** បុំ. ទន្សងជាបណ្ឌិត, គោធបណ្ឌិត ។ . **រាជ** បុំ. ស្តេចទន្សង, ស្តេចនៃទន្សង, ទន្សងជាស្តេច ។ . **មំស** នបុំ. សាច់នៃទន្សង ។

**គោធិក** អ.ន. ភិក្ខុឈ្មោះគោធិកៈ ។ . **ត្ថេរ** បុំ. ព្រះថេរៈឈ្មោះគោធិកៈ ។ . **ត្ថេរបរិនិព្វានវត្ថុ** នបុំ. រឿងនៃបរិនិព្វាននៃព្រះថេរៈឈ្មោះគោធិកៈ ។

**គោប** បុំ. [ គោ+បា+ណ ] (ជន) អ្នករក្សានូវគោ, អ្នកចិញ្ចឹមនូវគោ; វិ. **គាវោ បាតីតិ> គោបោ** ។

**គោបេយ** កិ. [ គុប+ណយ+ហិ.ប.] ចូរគ្រប់គ្រង , ចូររក្សា ។

**គោបយិតុំ** អ. [ គុប+ណយ+ឥ.អា.+តុំ ] ដើម្បីគ្រប់គ្រង, រីកិ.គ្រប់គ្រង ។

**គោបយិំសុ** កិ. [ គុប+ណយ+ឧំ.អជ្ជ.] គ្រប់គ្រងហើយ ។

**គោបានសិវង្ក** គុ. [ គោបានសិ+វង្ក ] វៀចឬកោងដូចជាបង្កង់ផ្ទះ ។

**គោបាលក** បុំ. [ គោ+បាល+ណ្វុ ] (ជន)អ្នករក្សានូវគោ, អ្នកឃ្វាលនូវគោ, អ្នកចាំនូវគោ (អ្នកគង្វាលគោ); វិ. **គាវោ បាលេតីតិ> គោបាលកោ** ។ . **ត្ត** នបុំ. ភាវៈនៃជនអ្នករក្សានូវគោ,

ភារៈនៃ...នោះជាអ្នករក្សានូវគោ ។ . **មារក** ចុំ. មារក (ក្មេង) អ្នករក្សានូវគោ ។

**គោបាលកុល** នចុំ. [ គោបាល+កុល ] ត្រកូលនៃជនអ្នករក្សានូវគោ (អ្នកចិញ្ចឹមនូវគោ) ។ **គោបាល**<គោ+បាល+អ = វិ. **គាវោ បាលេតីតិ> គោបាលោ** ។

**គោបិត** គុ. [ គុប+ឥ.អា.+ត ] គ្រប់គ្រងហើយ, រក្សាហើយ, គឺ... គ្រប់គ្រងហើយ ។

**គោបេតិ** កិ. [ គុប+ណេ+តិ.វ. ] គ្រប់គ្រង, រក្សា, ថែទាំ ។

**គោបេហិ** កិ. [ គុប+ណេ+តិ.វ. ] ចូរគ្រប់គ្រង ។

**គោប្ផក** ចុំ. [ គុប+ផ+ក.ស. ] (អវយវៈ) ដែលគេគ្រប់គ្រង (កជើង); វិ. **គោបិយតីតិ> គោប្ផកោ** ។

**គោមយ** គុ. [ គោ+មយ ] គោម័យ, ករីសដែលគោធ្វើហើយ ឬករីសដែលកើតអំពីគោ (អាចម៍គោ); វិ. **គាវេន បកតំ (ករីសំ)> គោមយំ; គោតោ និព្វត្តំ វា ករីសំ> គោមយំ** ។

**គោយូថ** ចុំ. [ គោ+យូថ ] ហ្វូងនៃគោ; វិ. **គុន្នំ យូថោ> គោយូ-ថោ** ។

**គោសត** នចុំ. [ គោ+សត ] រយនៃគោ ។

**គោសាមិក** ចុំ. [ គោ+សាមិក ] ម្ចាស់នៃគោ ។

**គោហនុក** គុ. [ គោ+ហនុ+ក ] ដើមមានសណ្ឋានដូចជាចង្កានៃគោ ។



**ឃដ** ចុំ. [ ឃដ+អ ] ក្អម, ឆ្នាំង, ពាង ។

**ឃដន** នចុំ. [ ឃដ+យុ ] កិ.ត, កិ.រួមគ្នា, សេចក្តីព្យាយាម, កិ.ខ្ជាប់, កិ.ភ្ជាប់ខ្ជាប់, កិ.ទង្គិច ។ . **វចន** ចុំ. ពាក្យជាគ្រឿងខ្ជាប់ខ្ជប់, ពាក្យជាគ្រឿងត ។

**ឃដប្បមាណ** គុ. [ ឃដ+បមាណ ] មានឆ្នាំងជាប្រមាណ, មានក្អមជាប្រមាណ, ប៉ុនឆ្នាំង, ប៉ុនក្អម ។

**ឃដសិត្ត** គុ. [ ឃដ+សិត្ត ] កំពុងនេះនូវខ្លាញ់, ដែលគេស្រោចដោយខ្លាញ់ ។ ប្រើជា «ឃតសិត្ត» ក៏មាន ។

**ឃដិឱទន** ចុំ. [ ឃដិ+ឱទន ] បាយក្នុងឆ្នាំង, បាយដែលជាប់នៅក្នុងឆ្នាំង ។

**ឃដិកា** ឥ. ដុំ, ពក, ពកឈើ ។

**ឃដិការ** អ.ន. ឈ្មោះឃដិការ (ចុំ. អ្នកធ្វើនូវឆ្នាំង, ស្មូនឆ្នាំង) ។

**ឃដិត្វា** អ. [ ឃដ+ឥ.អា.+ត្វា ] តហើយ, ព្យាយាមហើយ ។

**ឃដិត** គុ. [ ឃដ+ឥ.អា.+ត ] តិបុ.កិនហើយ, ដ៏តាំងនៅក្នុងឆ្នាំង ។

**ឃដិយតិ** កិ. [ ឃដ+ឥ.អា.+យ+តិ.វ. ] ត,...គឺ...ត, ព្យាយាម ។

**ឃដេន្ត** គុ. [ ឃដ+ឯ+អន្ត ] កាលត, កាលព្យាយាម ។

**ឃដេត្វា** អ. [ ឃដ+ឯ+ត្វា ] តហើយ, ព្យាយាមហើយ ។

**ឃដេសិ** កិ. [ ឃដ+អ+ឦ.អជ្ជ., ចុះ ស.អា. ] តហើយ, ព្យាយាមហើយ ។

**ឃដ្ដន** នបុំ. [ ឃដ្ដ+យុ ] កិ.ត, ‑ជំ, ‑កិ. ខ្ទប់, កិ.តាប, កិ.សម្លាប់, កិ. បៀតបៀន, កិ.ទង្គិច ។

**ឃដ្ដេតិ** កិ. [ ឃដ្ដ+អ+តិ‑វ ] ត, គោះ, ជំ, តាប, ខ្ទប់, ផ្ចាត់, កេះ ។

**ឃដ្ដេតុកាម** គុ. [ ឃដ្ដេតុំ+កម+ណ ] ចង់ដើម្បីត, ‑ខ្ទប់, ‑គោះ, ‑ជំ ។

**ឃដ្ដេសិ** កិ. [ ឃដ្ដ+អ+ឦ‑អជ្ជ. ចុះស‑អា. ] គោះហើយ, ជំហើយ, តាបហើយ ។

**ឃន** បុំ. គុ [ ហន+អ ផ្លាស់ ហជាឃ ] ជុំ, តាន់, មេឃ ។ ‑ **កវ‑ កវត្ថុ** នបុំ. ភ្លៀងធ្វើនូវការៈជាដុំ, គ្រឿងធ្វើឱ្យជាដុំ (ភ្លៀងព្រិល) ។ ‑ **កោដិមវដ្ដសុវណ្ណ** នបុំ. មាសឆ្អិនគួរដល់កិ.ជំឱ្យជាដុំ, មាសឆ្អិន (មាសក្រហម) គួរដល់កិ.វៃឱ្យជាដុំ, មាសឆ្អិនមានកំពូលដ៏តាន់ ។ ‑ **កោដិម** គុ. មានកិ.វៃឱ្យជាដុំ, គួរដល់កិ.ជំឱ្យជាដុំ, មានកំពូលដ៏តាន់ ។ ‑ **ឃនដ្ឋាន** នបុំ. ទីនៃសាច់ជាដុំៗ, ទីជាទីតាំងនៃសាច់ជាដុំៗ ។ ‑ **មដ្ឋក** អ.ន. ឈ្មោះឃនមដ្ឋកៈ ។ ‑ **មំស** នបុំ. សាច់ជាដុំ, សាច់ចំឡ្យក ។ ‑ **វដ្ដសុវណ្ណ‑ ផលិកប្បវាឡមយ** គុ. ជាវិការៈនៃមាសឆ្អិនជាដុំ និងកែវផលិក និងកែវប្រពាឡ, សម្រេចហើយដោយមាសឆ្អិនដ៏តាន់ និងកែវផលិក និងកែវប្រពាឡ ។ ‑ **វដ្ដសុវណ្ណមយ** គុ. ជាវិការៈនៃមាសឆ្អិនជាដុំ, ដែលបុគ្គលធ្វើហើយដោយមាសឆ្អិនជាដុំ ។ ‑ **វស្ស** នបុំ. ភ្លៀងជាដុំ, ភ្លៀងព្រិល ។ ‑ **វាស** គុ. មានប្រទេសជាទីនៅដ៏ណែន, មានប្រទេសជាទីនៅដ៏តាន់តាប់, មានទីជាទីនៅដ៏កុះករ ។ ‑ **សុវណ្ណកោដិម** គុ. មានចុងជាវិការៈនៃមាសតាន់, មានមាសជាដុំគួរដល់កិ.ជំ, គួរដល់កិ.វៃនូវមាសជាដុំ ។ ‑ **សេល‑ បព្វត** បុំ. ភ្នំជាវិការៈនៃថ្មជាដុំ, ភ្នំជាវិការៈនៃថ្មតាន់, ភ្នំដែលធម្មជាតតាក់តែងជាថ្មតាន់ ។ ‑ **សេលសទិស** គុ. ប្រាកដស្មើដោយថ្មតាន់, ដូចជាថ្មតាន់ ។



**ឃរ** នបុំ. [ គហ>ឃរ+ណ ] (សេនាសនៈ) កាន់យកនូវទព្វសម្ភារៈ (ផ្ទះ); វិ. **ធព្វសម្ភារេ គណ្ហាតីតិ> ឃរំ** ។ ‑ **ទ្វារ** នបុំ. ទ្វារនៃផ្ទះ, ‑ **បដិបាដិ** ឥ. លំដាប់នៃផ្ទះ ។ ‑ **ពន្ធន** នបុំ. វត្ថុជាគ្រឿងចងគឺផ្ទះ, ចំណងគឺផ្ទះ; វិ. **ឃរំ ឯវ ពន្ធនំ> ឃរពន្ធនំ** ។ ‑ **មានុសក** បុំ. ប្រជុំនៃមនុស្សក្នុងផ្ទះ, ពួកនៃមនុស្សក្នុងផ្ទះ; វិ. **មនុស្សានំ សមូហោ> មានុសកោ, ឃរមានុស‑ កោ> ឃរមានុសកោ** ។ ‑ **សប្ប** បុំ. ពស់ក្នុងផ្ទះ, ពស់អាស្រ័យនូវផ្ទះ (ពស់ផ្ទះ) ។ ‑ **សប្បជាតិក** គុ. ប្រកបដោយជាតិនៃពស់ផ្ទះមានជាតិនៃពស់អាស្រ័យនូវផ្ទះ; វិ. **ឃរសប្បោ> ឃរសប្បោ; ឃរសប្បស្ស ជាតិ> ឃរសប្បជាតិ; ឃរសប្បជាតិយា និយុត្តោ> ឃរសប្បជាតិកោ** ។ ‑ **សាមិនី** ឥ. (ស្ត្រីជាម្ចាស់នៃផ្ទះ ។ ‑ **សូករ** បុំ. ជ្រូកក្នុងផ្ទះ ។ )

**ឃរណី** ឥ. [ ឃរ+នី, នី>ណី+ឦ ] (ស្រី) អ្នកនាំទៅនូវផ្ទះ (មេផ្ទះ); វិ. **ឃរំ នេតីតិ> ឃរណី** ។ អ.ន. ឧបាសិកាឈ្មោះឃរណី ។

**ឃរាវាស** បុំ. [ ឃរ+អា+វស+ណ ] ការនៅអាស្រ័យនូវផ្ទះ, ការនៅគ្រប់គ្រងនូវផ្ទះ; វិ. **ឃរស្ស អាវសនំ> ឃរាវា**

សោ ។ អ្នកនៅគ្រប់គ្រងនូវផ្ទះ, ឃរាវាសៈ; វិ. **ឃរំ អាវសតីតិ> ឃរាវាសោ** ។ - **ពន្ធន** នពុំ. វត្ថុជាគ្រឿងចងពីកិ. នៅគ្រប់គ្រងនូវផ្ទះ, ចំណងគឺឃរាវាស ។

**ឃំសតិ** កិ. [ ឃំស+អ+តិ.វ. ] ក្កួត, ត្រដុស, សង្កៀត ។

**ឃំសន្តី** គុ. [ ឃំស+អន្ត+ឦ ] កាលក្កួត, កាលត្រដុស, កាលសង្កៀត ។

**ឃំសិត្វា** អ. [ ឃំស+ឥ.អា.+ត្វា ] ក្កួតហើយ, ត្រដុសហើយ ។

**ឃំសិយមាន** គុ. [ ឃំស+ឥ.អា.+យ+មាន ] គឺ...កាលក្កួត, គឺ...ត្រដុស ។

**ឃាត** ពុំ. [ ហន>ឃាត+ណ ] កិ.សម្លាប់, កិ.បៀតបៀន; វិ. **ឃាតនំ> ឃាតោ** ។

**ឃាតយេ** កិ. [ ហន>ឃាត+ណយ+ឯយ្យ.ស. ] គប្បីសម្លាប់, គប្បីបៀតបៀន ។

**ឃាតាបេន្ត** គុ. [ ហន+ណាបេ+អន្ត ] កាលញុំាង...ឱ្យសម្លាប់, ឱ្យបៀតបៀន ។

**ឃាតាបេយ្យ** កិ. [ ហន+ណាបេ+ឯយ្យ.ស. ] គប្បីញុំាង...ឱ្យសម្លាប់ ។

**ឃាតិយមាន** គុ. [ ហន+ឥ.អា.+យ+មាន ] គឺ...កាលសម្លាប់ ។

**ឃាតេតព្វ** គុ. [ ហន+ណេ+តព្វ ] គឺ...គប្បីសម្លាប់ ។

**ឃាតេតិ** កិ. [ ហន+ណេ+តិ.វ. ] សម្លាប់, បៀតបៀន ។



**ឃាតេតុ** កិ. [ ហន+ណេ+តុ.ក. ] ចូរសម្លាប់, ចូរបៀតបៀន ។

**ឃាតេត្វា** អ. [ ហន+ណេ+ត្វា ] សម្លាប់ហើយ,... ។

**ឃាតេស្សាមិ** កិ. [ ហន+ណេ+ឯស្សាមិ.ស. ] គប្បីសម្លាប់,... ។

**ឃាតេស្សតិ** កិ. [ ហន+ណេ+ស្សតិ.ភ. ] នឹងសម្លាប់,... ។

**ឃាយិត្វា** អ. [ ឃា+ឥ.អា.+ត្វា, ផ្លាស់អានៃឃាជាអាយ ] ហិតហើយ, ធុំហើយ, ស្រូបហើយ ។

**ឃាសច្ឆាទន** នពុំ. [ ឃាស+ឆាទន ] វត្ថុគឺបុ.គប្បីស៊ី និងវត្ថុជាគ្រឿងបិទបាំង, វត្ថុគឺបុ.គប្បីស៊ី និងវត្ថុជាគ្រឿងស្លៀកដណ្តប់ (បាយនឹងសំពត់) ។ ឃាស<ឃស+ណ = វិ. **ឃសិតព្វន្តិ> ឃសនំ ឃសនំ> ឃាសោ** ។ ឆាទន<ឆទ+យុ = វិ. **ឆាទេតិ ឯតេនាតិ> ឆាទនំ** ។ - **មត្ត** គុ. ត្រឹមតែវត្ថុគឺបុ.គប្បីស៊ី នឹងសំពត់សម្រាប់ស្លៀកដណ្តប់ ។ - **អាទិ** គុ. (វត្ថុ) មានបាយគឺបុ.គប្បីស៊ីនិងសំពត់សម្រាប់ស្លៀកដណ្តប់ជាដើម ។

**ឃុរុឃុរាយតិ** កិ. [ ឃុរុឃុរុ+អាយ+តិ.វ. ] ប្រព្រឹត្តនូវសម្លេងថាឃុរុឃុរុ ។

**ឃោរ** គុ. [ ឃុរ+ណ ] ធម្មជាតិដែលបុគ្គលតែងខ្លាច, ឬធម្មជាតញុំាងភ័យឱ្យកើតឡើង, (ពន្លឺក, ភ្លា, ភ្លៀវភ្លា, ក្លាំងក្លា, អង់អាច, មោះមុត); វិ. **ឃុរយតិ ភីសយតីតិ> ឃោរំ; ឃុរតិ ភយមុប្បាទយតីតិ> ឃោរំ** ។ - **តប** គុ. មានតបៈដ៏ពន្លឹក, អ្នកមានតបៈដ៏ក្លា; វិ. **ឃោរោ តបោ យស្ស**

សោ> ឃោសកេបោ ។ -វិស គុ. មានពិសដ៏ពន្លឺក, មានពិសដ៏ក្លា ។

**ឃោសក** បុំ. [ ឃុស+ណ្វុ ] អ្នកឃោសនា, អ្នកស្រែកប្រកាស ។ អ.ន. កុមារឈ្មោះឃោសកៈ ។ -**ទេវបុត្ត** បុំ. ទេវបុត្តឈ្មោះឃោសកៈ ។

**ឃោសន** នបុំ. [ ឃុស+យុ ] កិ.គឹកកង, ការឃោសនា, សំលេងជាគ្រឿងគឹកកង; វិ **ឃោសយតេតិ> ឃោសនំ ឃោសេន្តិ ឯតេនាតិ> ឃោសនំ** ។ ឥ. ឃោសនា ។ -**កម្ម** នបុំ. កម្មគឺកិ.ឃោសនា, កិ.ស្រែកប្រកាស, -កិ.ញុំាងសម្លេងឱ្យគឹកកង ។

**ឃោស** បុំ. [ ឃុស+ណ ] គឹកកង, កងរំពង, កិ.គឹកកង, ការស្រែកប្រកាស, ការឃោសនា; វិ. **ឃោសនំ> ឃោសោ** ។ សំលេងជាគ្រឿងគឹកកង; វិ. **ឃោសេន្តិ ឯតេន ចា ឯត្ថាតិ> ឃោសោ** ។ -**ប្បមាណិក** គុ. អ្នកប្រកបដោយប្រមាណក្នុងសំលេងដ៏គឹកកង; វិ. **ឃោសប្បមាណេន និយុត្តា> ឃោសប្បមាណិកា** ។

**ឃោសាបេត្វា** អ. [ ឃុស+ណាបេ+ត្វា ] ញុំាងសម្លេងឱ្យគឹកកងហើយ ។

**ឃោសិត** គុ. [ ឃុស+ឥ_អា+ត ] គឺ.....ឱ្យគឹកកងហើយ, គឺ.... ឃោសនាហើយ, គឺ...ស្រែកប្រកាសហើយ ។



**ឃោសិតារាម** បុំ. [ ឃោសិត+អារាម ] វិហារឈ្មោះឃោសិតារាម, អារាមឈ្មោះឃោសិតៈ ។

**ឃោសេតិ** កិ. [ ឃុស+ណេ+តិ_វ. ] ញុំាងឱ្យ.....គឹកកង, ឱ្យឃោស-នា;... ។

**ចក្ក** នបុំ. [ ចក្ក+អ ឬករ+អ ] វត្ថុដែលបៀតបៀននូវផែនដី ឬវត្ថុជាគ្រឿងធ្វើនូវដំណើរ (កង់, គ្រឿងចក្រ); វិ. **ចក្កតិ ព្យថតិ ហឹសតិ ភូមិន្តិ> ចក្កំ; ករោតិ គមនមនេនាតិ> ចក្កំ** ។ - **បាទ** បុំ. ជើងនៃចក្រ; គុ. មានចក្រជាជើង ។ - **ភេទ** បុំ. កិ.ទំលាយនូវចក្រ ។ - **មគ្គ** បុំ. ផ្លូវនៃចក្រ, ផ្លូវនៃកង់ ។ - **មត្ត** គុ. មានចក្រជាប្រមាណ, មានកង់ជាប្រមាណ, ប៉ុនកង់ ។ - **ធុបន** នបុំ. រង្វង់នៃកង់, កិ.ប្រជុំនៃកង់, កិ.ស្ទប់ស្ទៀមនៃកង ។ - **យុគ** នបុំ. គូនៃចក្រ, គូនៃកង់, ។ - **រតន** នបុំ. ចក្ករតន៍, កែវគឺចក្រ ។ - **អាទិ** គុ. អវយវៈនៃរថមានចក្រជាដើម, យានូបករណ៍មានកង់ជាដើម ។

**ចក្កវត្តិ** បុំ. [ ចក្ក+វត្ត+ណិ ] អ្នកញ៉ាំងចក្រឱ្យប្រព្រឹត្តទៅ (ចក្រព័ត្តិ, ស្ដេចចក្រព័ត្តិ); វិ. **ចក្កំ វត្តេតីតិ> ចក្កវត្តិ** ។ **ចក្ករតនំ វត្តេតិ អាកាសេ អត្តនោ បរេហិ តម យតីតិ វា> ចក្កវត្តិ** ។ - **រជ្ជ** នបុំ. ចក្រពត្តិរាជ្យ, ភាវៈនៃស្ដេចចក្រព័ត្តិ ។ - **រាជា** បុំ. ព្រះរាជាអ្នកញ៉ាំងចក្រឱ្យប្រព្រឹត្ត ទៅ, ស្ដេចចក្រព័ត្តិ ។ - **សម្បត្តិ** ឥ. សម្បត្តិនៃស្ដេចចក្រព័ត្តិ ។ - **សិរី** ឥ. សិរីនៃស្ដេចចក្រព័ត្តិ, សិរីនៃស្ដេចអ្នកញ៉ាំងចក្រឱ្យប្រព្រឹត្តទៅ ។

**ចក្កវាឡ** នបុំ. [ ចក្រ+វាឡ ] ចក្រវាឡ, ចក្រវាឡ ។ - **កោដិស-តសហស្ស** នបុំ., សែននៃកោដិនៃចក្រវាឡ ។ - **គព្ភ** បុំ. ល្វែងនៃចក្រវាឡ, ផ្ទៃនៃចក្រវាឡ ។ - **បព្វត** បុំ. ភ្នំឈ្មោះចក្រវាឡ, ចក្រវាឡបព៌ត ។ - **បរិយន្ត** បុំ. ទីបំផុតជុំវិញនៃចក្រវាឡ ។ - **មុខវដ្ដិ** ឥ. កណ្ដាប់នៃកោដ់នៃចក្រវាឡ ។ - **សតស-ហស្ស** បុំ. សែនដែនចក្រវាឡ ។ - **សត** បុំ. រយដែនចក្រវាឡ ។ - **សហស្ស** បុំ. ពាន់ដែនចក្រវាឡ ។



**ចក្ខុ** នបុំ. [ ចក្ខ+ឧ ឬណុ ] ធម្មជាតវែងមើលឃើញនូវរូប (ចក្ខុ, ភ្នែក); វិ. **រូបំ ចក្ខតីតិ> ចក្ខុ** ។ - **ទុព្វល** គុ. អ្នកមានចក្ខុទុព៌ល, អ្នកទុព៌លដោយចក្ខុ, អ្នកមានចក្ខុមានកម្លាំងថយ, អ្នកមានចក្ខុមានកម្លាំងគឺរស្មីប្រាសចេញហើយ ។ - **ទ្វារាទិវស** បុំ. អំណាចដែលប្រព្រឹត្តតាមចក្ខុទ្វារជាដើម ។ - **ទ្វារាទិ** គុ. (ទ្វារ) មានចក្ខុទ្វារជាដើម ។ - **ទ្វារ** នបុំ. ទ្វារគឺចក្ខុ ។ - **បថ** បុំ. គន្លងនៃចក្ខុ ។ - **បាលត្ថេរ** បុំ. ព្រះថេរៈឈ្មោះចក្ខុបាល ។ - **ភូត** គុ. អ្នកមានចក្ខុកើតហើយ, អ្នកមានចក្ខុ, កើតហើយជាចក្ខុ ។ - **វិកលភាវ** បុំ. ការដែល... មានចក្ខុវិកល, ការនៃ...ជាអ្នកវិកលដោយចក្ខុ ។ - **វិញ្ញេ-យ្យាទិ** គុ. មានអារម្មណ៍គឺបុ.គប្បីដឹងច្បាស់ដោយចក្ខុជាដើម ។

**ចក្ខុម** គុ. [ ចក្ខុ+មន្តុ ] អ្នកមានចក្ខុ; វិ. **ចក្ខុ យេសមត្ថីតិ-ចក្ខុមន្តោ** ។

**ចក្ខុមន្តុ** គុ. [ ចក្ខុ+មន្តុ ] អ្នកមានចក្ខុ; វិ. **ចក្ខុ យេសមត្ថីតិ-ចក្ខុមន្តោ** ។

**ចង្កមតិ** កិ. [ ក-កម+អ+តិ ។ ផ្លាស់ករព្ភាសជា ច, ចុះនិ.អា. ] ចង្ក្រម, ឈានទៅ, ដើរទៅ (ដើរទៅមក) ។

**ចង្កមន** នបុំ. [ ក-កម+យុ ] កិ.ចង្ក្រម, ទីជាទីចង្ក្រម; វិ. **ចង្កមិយ**

**គេតិ> ចង្កមនំ; ចង្កមតិ ឯត្ថាតិ> ចង្កមនំ** ។ - **កោដិ** ឥ. ទីបំផុតនៃទីជាទីចង្ក្រម, ចុងនៃទីជាទីចង្ក្រម ។ - **កាល** ចុំ. កាលនៃកិ.ចង្ក្រម, កាលជាទីចង្ក្រម ។ - **ដ្ឋាន** នចុំ. ទីជាទីចង្ក្រម, ទីនៃកិ.ចង្ក្រម, ទីជាទីតាំងនៃកិ.ចង្ក្រម ។ - **និសីទនដ្ឋាន** នចុំ. ទីជាទីចង្ក្រមនិងទីជាទីអង្គុយ ។ - **អាទិ** គុ. (វត្ថុ) មានកិ.ចង្ក្រមជាដើម ។

**ចង្កមន្ត** គុ. [ ក_កម+អ+អន្ត ] កាលចង្ក្រម, កាលឈានទៅ ។

**ចង្កមមាន** គុ. [ ក_កម+អ+មាន ] កាលចង្ក្រម, កាលឈានទៅ ។

**ចង្កមាមិ** កិ. [ ក_កម+អ+មិ+វ. ] ឈានទៅ, ដើរទៅ ។

**ចង្កមិ** កិ. [ ក_កម+អ+ឦ_អជ្ជ. ] ចង្ក្រមហើយ...។

**ចង្កមិតព្វ** គុ. [ ក_កម+ឥ_អា.+តព្វ ] គឺ....គប្បីចង្ក្រម....។

**ចង្កមិស្សាមិ** កិ. [ ក_កម+អ+ឥ_អា+ស្សាមិ.ភ ] នឹងចង្ក្រម...។

**ចង្កោដក** ចុំ. [ កុ_កុណោ+ក+ក_ស.] ប្រអប់ (ចង្កោដក ក៏មាន) ។

**ចជន្ត** គុ. [ ចជ+អ+អន្ត ] កាលលះ, កាលលះបង់ ។

**ចជិត្វា** អ. [ ចជ+ឥ_អា.+ត្វា ] លះហើយ, លះបង់ហើយ ។

**ចជិត្វាន** អ. [ ចជ+ឥ.អា.+ត្វាន ] លះហើយ ។

**ចជេ** កិ. [ ចជ+អ+ឯយ្យ_ស., លុបយ្យ ទុកតែឯ ] គប្បីលះ.....។

**ចជេយ្យ** កិ. [ ចជ+អ+ឯយ្យ_ស. ] គប្បី.....។



**ចណ្ឌ** គុ. [ ចណ្ឌ+អ ] (ជន) ដែលកាច, សាហាវ, ព្រហើន; វិ. **ចណ្ឌតីតិ> ចណ្ឌោ** ។ - **បជ្ជោត** អ.ន. ស្ដេចឈ្មោះចណ្ឌបជ្ជោត ។ - **សោតតីរ** នចុំ. ឆ្នេរមានខ្សែទឹកដ៏កាច, ឆ្នេរនៃមេទឹកមានខ្សែទឹកដ៏កាច ។ - **ហត្ថី** ចុំ. ដំរីកាច, ដំរីសាហាវ ។

**ចណ្ឌាល** ចុំ. [ ចណ្ឌ+អល ] (មនុស្ស) ដែលកាច, -ព្រហើន, -ទៀតទៀន; វិ. **ចណ្ឌាតិ ចិណ្ឌតីតិ> ចណ្ឌាលោ** ។ ឥ. **ចណ្ឌាលី** ។

**ចណ្ឌិក្ក** នចុំ. [ ចណ្ឌ+ណិក ] ភាវៈនៃ....អ្នកកាច, -សាហាវ, -ព្រហើន; វិ. **ចណ្ឌស្ស ភាវោ> ចណ្ឌិក្កំ** ។

**ចតុអបាយសមុទ្ទ** ចុំ. [ ចតុរបាយ+សមុទ្ទ ] សមុទ្រគឺអបាយ៤ ប្រើជា «ចតុរាបាយ» ក៏បាន ។

**ចតុក្ក** នចុំ. [ ចតុ+ក ] មានប្រមាណបួន, (កិ.ប្រហារ) ប្រមាណបួន; វិ. **ចត្តារិ បរិមាណានិ អស្សាតិ> ចតុក្កំ** ។

**ចតុក្ខត្តុំ** អ. [ ចតុ+សកឹ, សកឹ>ខត្តុំ ] វារៈនៃ....បួន, វារៈបួនដង, អស់វារៈបួនដង ។

**ចតុគាវុតមត្ត** គុ. [ ចតុគាវុត+មត្ត ] មានគាវុតបួនជាប្រមាណ, ត្រឹមតែបួនគាវុត ។

**ចតុជ្ជាតិក** គុ. [ ចតុជ្ជាតិ+ណិក ] ប្រកបដោយជាតិបួន, មានជាតិបួន ។ - **គន្ធ** ចុំ. វត្ថុមានក្លិនប្រកបដោយជាតិបួន, គ្រឿងក្រអូបប្រកបដោយជាតិ៤ ។ - **គន្ធោទក** នចុំ. ទឹកលាយដោយ

គ្រឿងក្រអូបដោយជាតិ៤, ទឹកមានក្លិនប្រកបដោយជាតិ៤ ។

**ចតុត្ថ** បុ.សំ. [ ចតុ+ថ>ចតុត្ថ ] ទី៤, ជាគំរប់៤ ។ - **ជ្ឈាន** នពុំ. ឈានទី៤ ។ - **ទ្វារកោដ្ឋក** នពុំ. ក្លោងនៃទ្វារទី៤, ស៊ុមនៃទ្វារជាគំរប់៤ ។ - **ភាគ** ពុំ. ភាគទី៤, ចំណែកទី៤ ។ - **មគ្គញាណ** នពុំ. ញាណដ៏សម្បយុត្តដោយមគ្គទី៤, មគ្គញាណទី៤ ។ - **មគ្គ** ពុំ. មគ្គទី៤ ។ - **វារ** ពុំ. វារៈទី៤, វេនទី៤ ។ - **សទ្ទ** ពុំ. សំឡេងទី៤ ។

**ចតុទ្ទស** បស. [ ចតុ+ទស>ចតុទ្ទស ] ដប់ព្រៃលេងដោយ៤ (ដប់បួន); វិ. **ចតូហិ អធិកា ទស> ចតុទ្ទស** ។

**ចតុទ្ទិស** នពុំ. [ ចតុ+ទិស ] ទិស៤; វិ. **ចតស្សោ ទិសា> ចតុទ្ទិសំ** ។

**ចតុទ្វាតុវវត្ថានវស** ពុំ. [ ចតុទ្ធាតុ+វវត្ថាន+វស ] អំណាចនៃកិ.តាំងចុះនូវធាតុ៤, អំណាចនៃកិ.កំណត់នូវធាតុ៤ ។

**ចតុប្បច្ចយ** ពុំ. [ ចតុ+បច្ចយ ] បច្ច័យ៤ ។ - **ទាយិកា** ឥ. អ្នកឱ្យនូវបច្ច័យ៤; វិ. **ចតុប្បច្ចយេ ទេតីតិ> ចតុប្បច្ចយទាយិកា** ។ - **បូជា** ឥ. កិ.បូជានូវបច្ច័យ៤, កិ.បូជាដោយបច្ច័យ៤ ។ - **សក្ការ** ពុំ. គ្រឿងសក្ការៈគឺបច្ច័យ៤ ។ - **សន្តោស** ពុំ. សេចក្ដីសន្តោសក្នុងបច្ច័យ៤, សេចក្ដីត្រេកអរស្មើក្នុងបច្ច័យ៤, អ្នកត្រេកអរក្នុងបច្ច័យ៤ ។

**ចតុប្បញ្ចនាឡិបត្ត** គុ. [ ចតុ+បញ្ច+នាឡិ+បត្ត ] មាននាឡិ៤ និងនាឡិ៥ ជាប្រមាណ, ត្រឹមតែនាឡិ៤ និងនាឡិ៥ ជាប្រមាណ ។



**ចតុប្បញ្ញាស** ក. សំ. [ ចតុ+បញ្ញាស ] ហាសិបដ៏ព្រៃលេងដោយ៤ (ហាសិបបួន) ។ - **កោដិធន** នពុំ. ទ្រព្យមានកោដិហាសិបបួនជាប្រមាណ, ទ្រព្យរាប់ដោយកោដិ៥៤, ទ្រព្យមានកោដិ ៥០ ដ៏ព្រៃលេងដោយកោដិ ៤ ជាប្រមាណ, ។ - **ធន** ពុំ. ធន៥៤ ។

**ចតុប្បរិសា** ឥ. [ ចតុ+បរិស ] បរិស័ទ៤ ។ - **អន្តរ** ពុំ. ចន្លោះនៃបរិស័ទ៤, រវាងនៃ..., ខាងក្នុងនៃ... ។ - **មជ្ឈ** នពុំ. កណ្ដាលនៃបរិស័ទ៤ ។

**ចតុប្បទ** គុ. [ ចតុ+បទ ] មានបាទ៤, មានជើង៤ ។

**ចតុប្បទិក** គុ. [ ចតុប្បទ+ណិក ] មានបាទ៤, ប្រកបដោយបាទ៤ ។ - **គាថា** ឥ. គាថាប្រកបដោយបាទ៤ ។ - **គាថាវសាន** នពុំ. កាលជាទីបំផុតចុះនៃគាថាប្រកបដោយបាទ៤, កាលជាទីចប់នៃគាថាប្រកបដោយបាទ៤ ។

**ចតុប្បទី** ឥ. [ ចតុប្បទ+ឦ ] មានជើង៤ ។

**ចតុប្បមាណិក** គុ. [ ចតុប្បមាណ+ណិក ] ប្រកបដោយប្រមាណ៤, មានប្រមាណក្នុងវត្ថុ៤ ។

**ចតុព្វិធំ** អ.ព. [ ចតុ+វិធំ ] ប្រការ៤, ៤យ៉ាង; វិ. **ចត្តារោ បការា> ចតុព្វិធំ** ។

**ចតុព្វិធ** គុ. [ ចតុ+វិធ ] មានប្រការ៤, មាន៤យ៉ាង; វិ. **ចត្តារោ វិធា បការា ឯតស្សាតិ> ចតុព្វិធោ** ។ - **សច្ច** នពុំ. សច្ចមាន៤យ៉ាង, សច្ចមានប្រការ៤យ៉ាង ។

**ចតុព្ភាគ** គុ. [ ចតុ+ភាគ ] មានចំណែក៤ ។ - **មត្ត** គុ. មានចំណែក៤ ជាប្រមាណ ។

**ចតុព្ភូមិកចិត្ត** នពុំ. [ ចតុព្ភូមិក+ចិត្ត ] ចិត្តប្រព្រឹត្តទៅក្នុងភូមិ៤ ឬចិត្តប្រកបក្នុងភូមិ៤; **ចតុព្ភូមិយំ ចត្ថីតិ> ចតុព្ភូមិកំ; ចតុព្ភូមិយំ យុញ្ជតីតិ វា> ចតុព្ភូមិកំ** ។

**ចតុម្មគ្គ** ពុំ. [ ចតុ+មគ្គ ] មគ្គ៤ ។ - **និយាម** នពុំ. កិ.កំណត់ក្នុងមគ្គ៤, គុណជាគ្រឿងនាំចេញគឺមគ្គ៤, ទំនងនៃមគ្គ៤ ។ - **សង្ខាត** គុ. គឺបណ្ឌិតពោលថាមគ្គ ៤, ពោលគឺមគ្គ ៤ ។

**ចតុម្មធុរ** គុ. [ ចតុ+មធុរ ] (វត្ថុ) មានរសឆ្ងាញ់៤ ។ - **បុណ្ណ** គុ. ពេញហើយដោយវត្ថុមានរសឆ្ងាញ់៤ ។

**ចតុម្មហាបថ** ពុំ. [ ចតុ+មហាបថ ] ផ្លូវធំ៤, ភូមិភាគជាទីប្រជុំនៃផ្លូវធំ៤ ។

**ចតុម្មហាភូតគុហា** ឥ. [ ចតុម្មហាភូត+គុហា ] គុហាគឺមហាភូតរូប៤, មហាភូតរូប៤ដូចជាគុហា ។

**ចតុម្មាស** ពុំ. [ ចតុ+មាស ] ខែ៤ ។ - **វច្ចយ** ពុំ. កាលជាទីប្រព្រឹត្តកន្លងទៅនៃខែ៤, កាលជាទីប្រព្រឹត្តកន្លងទៅរបស់ខែ៤, កាលជាទីអំណើះនៃខែ៤ ។

**ចតុយោជន** នពុំ. [ ចតុ+យោជន ] យោជន៍៤ ។ - **សហស្សមត្ត** គុ. មានពាន់នៃយោជន៍៤ ជាប្រមាណ ។

**ចតុរង្គ** នពុំ. [ ចតុ+អង្គ, ចុះ វ.អា. ] អង្គ៤ ។ - **សមន្នាគត** គុ. មកតាមព្រមហើយដោយអង្គ៤, ប្រកបដោយអង្គ៤ ។



**ចតុរង្គិនី** ឥ. [ ចតុរង្គ+ឥន៑+ឥ ] ការមានអង្គ៤; វិ. **ចតុរង្គំ យស្សា អត្ថីតិ> ចតុរង្គិនី** ។

**ចតុរស្សបុក្ខរ** ពុំ. [ ចតុរស្ស+បុក្ខរ ] ដីរាងមានជ្រុង៤ ។

**ចតុរាសីតិ** ក.សំ. [ ចតុ+អសីតិ ] ៨០ដ៏ក្រៃលែងដោយ៤ (៨៤) ។ - **យោជនសហស្សគម្ភីរ** គុ. មានជម្រៅមានពាន់នៃយោជន៍ ៨៤ជាប្រមាណ (ជម្រៅ៨ម៉ឺន៤ពាន់យោជន៍) ។ - **យោជនសហស្សមត្ថក** ពុំ. ទីបំផុតនៃពាន់នៃយោជន៍៨៤ ។ - **សហស្ស** ប.សំ. មានពាន់៨៤ជាប្រមាណ (៨៤ ០០០) ។

**ចតុវីសតិម** បូ.សំ. [ ចតុវីសតិ+ម ] ទី២០ក្រៃលែងដោយ៤ (ទី២៤) ។

**ចតុវីសតិយោជនិក** គុ. [ ចតុវីសតិយោជន+ណិក ] ប្រកបដោយយោជន៍២៤ ។

**ចតុសច្ច** នពុំ. [ ចតុ+សច្ច ] សច្ចៈ៤ ។ - **ធម្ម** ពុំ. ធម្មគឺសច្ចៈ៤ ។ - **ពុទ្ធតា** ឥ. ភាវៈនៃ...នោះជាអ្នកត្រាស់ដឹងនូវសច្ចៈ៤ ។ - **វិភាវី** ពុំ. អ្នកសំដែងនូវសច្ចៈ៤, អ្នកញុំាងសច្ចៈ៤ឱ្យកើតប្រាកដ ។

**ចតុសដ្ឋី** ប.សំ. [ ចតុ+សដ្ឋី ] ៦០ដ៏ក្រៃលែងដោយ៤ (៦៤) ។

**ចតុសត** ប.សំ. [ ចតុ+សត ] មានរយ៤ជាប្រមាណ (៤០០) ។

**ចតុសតិប្បដ្ឋានាទិភេទ** ពុំ., គុ. [ ចតុសតិប្បដ្ឋានាទិ+ភេទ ] ផ្សេងដោយធម៌មានសតិប្បដ្ឋាន៤ជាដើម, មានធម៌មានសតិប្បដ្ឋាន ៤ ជាដើមជាប្រភេទ ។

**ចតុស្សត្តតិសហស្សមត្ត** គុ. [ ចតុស្សត្តតិសហស្ស+មត្ត ] មានពាន់៧៤ជាប្រមាណ (៧៤.០០០) ។

**ចតុស្សាលា** ឥ. [ ចតុ+សាលា ] សាលា៤, សាលាមានមុខ៤ ។

**ចតុស្សិន្ធវយុត្ត** គុ. [ ចតុស្សិន្ធវ+យុត្ត ] ប្រកបដោយសេះសិន្ធវៈ៤, ទឹមដោយសេះសិន្ធព៤ ។

**ជេតវន** នបុំ. [ ជេត+វន ] ព្រៃឈើរបស់ព្រះរាជកុមារឈ្មោះជេត (កាលដើម ព្រៃពេលនោះឯង គឺព្រះរាជកុមារឈ្មោះជេតបានដាំ ហើយទ្រង់ជាម្ចាស់នៃព្រៃឈើនិងដីនោះ បានជាគេហៅថា" ជេត-វន ឬ ជេតពន" គឺជាឈ្មោះអារាមមួយនៅជិតក្រុងសាវត្ថី ដែលអនាថបិណ្ឌិកសេដ្ឋី បានទិញអំពីព្រះរាជកុមារនោះដោយតំលៃប្រាក់១៨កោដិ, តំលៃសាងអស់១៨កោដិ, ធ្វើបុណ្យឆ្លងអស់១៨កោដិទៀតរួមជា៥៤កោដិ) ។ - **ទ្វារកោដ្ឋក** បុំ. ខ្លោងនៃទ្វារនៃវត្តឈ្មោះជេតពន, ស៊ុមនៃទ្វារនៃវត្តជេតពន ។ - **បោក្ខរណី-តីរ** នបុំ. ឆ្នេរនៃស្រះបោក្ខរណីជេតពន ។ - **មគ្គ** បុំ. ផ្លូវនៃវត្តជេតពន, ផ្លូវជាទីទៅកាន់វត្តជេតពន ។ - **មហាវិហារ** បុំ. មហាវិហារ (វិហារធំ) ឈ្មោះជេតពន ។ - **សមីប** តុ. ទីជិតនៃវិហារជេតពន ។ - **អាភិមុខ** តុ. អ្នកមានមុខចំពោះកាន់វត្តឈ្មោះជេតពន, អ្នកមានមុខឆ្ពោះទៅកាន់វត្តជេតពន ។

**ជោតិក** តុ. [ ជុតិ+ណិក ] អ្នកមានសេចក្ដីរុងរឿង; វិ. **ជុតិ យស្ស អត្ថីតិ> ជោតិកោ** ។ - **ត្ថេរ** បុំ. ព្រះថេរៈឈ្មោះជោតិកៈ ។ - **សេដ្ឋី** បុំ. សេដ្ឋីឈ្មោះជោតិកៈ ។

**ជោតិបាសាណ** បុំ. [ ជោតិ+បាសាណ ] ថ្មដ៏រុងរឿង, ថ្មមានរស្មីដ៏រុងរឿង ។



**ជោតិយ** តុ. [ ជុតិ+ឥយ ] អ្នកមានសេចក្ដីរុងរឿង ។ អ.ន. សេដ្ឋីឈ្មោះជោតិយៈ ។

**ជោតិរស** តុ. [ ជោតិ+រស ] មានរស្មីដ៏រុងរឿង; វិ. **ជោតិ រសោ រំសិ យស្សាតិ> ជោតិរសោ** ។

**ជោតេត្វា** អ. [ ជុត+ណេ+ត្វា ] ញុំាង... ឱ្យរុងរឿងហើយ, -ឱ្យភ្លឺហើយ ។

**ឈាន** នពុំ. [ ឈេ+យុ ឬឈា+យុ ] (ធម្មជាត) គិតនូវអារម្មណ៍, សំឡឹងយកនូវអារម្មណ៍ ឬ (ធម្មជាត) ដុតនូវនីវរណធម៌ជាសត្រូវ (ឈាន); វិ. **អារម្មណំ ឈាយតីតិ> ឈានំ; បច្ចនីកេ នីវរណធម្មេ ឈាបេតីតិ វា> ឈានំ** ។ **. កីឡា** ឥ. កិ.លេងក្នុងឈាន, កិ.លេងដោយឈាន ។ **. ប្បសុត** គុ. អ្នកខ្វល់ខ្វាយក្នុងឈាន ។ **. រតី** គុ. អ្នកត្រេកអរហើយក្នុងឈាន ។ **. លាភី** គុ. អ្នកបាននូវឈាន, អ្នកមានកិ.បាននូវឈាន, អ្នកមានកិ.បាននូវឈានជាប្រក្រតី (ចូរប្រកបវិគ្គហៈតាមពាក្យប្រែនេះផងចុះ) ។ **. វិបស្សនាមគ្គផលធម្ម** ពុំ. ធម៌គឺឈាននិងវិបស្សនា និងមគ្គ និងផល ។ **. វិបស្សនាមត្ត** គុ. គុណត្រឹមតែឈាននិងវិបស្សនា ។ **. សុខ** នពុំ. សុខក្នុងឈាន, សុខដែលកើតអំពីឈាន ។

**ឈានាទិភេទ** គុ. [ ឈានាទិ+ភេទ ] ផ្សេងដោយគុណវិសេសមានឈានជាដើម, មានមានឈានជាដើមជាប្រភេទ ។

**ឈានាភិញ្ញា** ឥ. [ ឈាន+អភិញ្ញា ] ឈាននិងអភិញ្ញា ។

**ឈានុប្បាទិកា** ឥ. [ ឈាន+ឧ+បទ+ណេ+ឥ.អា.+អា.ឥ. ] អ្នកញ៉ាំងឈានឱ្យកើតឡើង; វិ. **ឈានំ ឧប្បាទេតីតិ> ឈានុប្បាទិកា** ។

**ឈាបនកិច្ច** នពុំ. [ ឈាបន+កិច្ច ] កិច្ចដោយកិ.ដុត, កិច្ចគឺកិ.ដុត, កិច្ចគឺកិ.ញ៉ាំងសរីរៈឱ្យឆេះ (ឈាបន<ឈាប+យុ ឬ ឈា+ណាបេ+យុ); វិ. **ឈាបិយតេតិ> ឈាបនំ** ។



**ឈាបិត** គុ. [ ឈាប+ឥ.អា.+ត ] គឺ...ដុតហើយ, គឺភ្លើងឆេះហើយ ។

**ឈាបិយមាន** គុ. [ ឈាប+ឥ.អា.+យ+មាន ] គឺភ្លើងកាលឆេះ, គឺ...កាលដុត ។

**ឈាបេតិ** កិ. [ ឈាប+ណេ+តិ.វ. ] ដុត, ញ៉ាំង...ឱ្យឆេះ ។

**ឈាបេត្វា** អ. [ ឈាប+ណេ+ត្វា ] ដុតហើយ, ញ៉ាំង...ឱ្យឆេះហើយ ។

**ឈាបេសិ** កិ. [ ឈាប+ណេ+ឦ.អជ្ជ. ] ដុតហើយ, ញ៉ាំង... ឱ្យឆេះហើយ ។

**ឈាបេហិ** កិ. [ ឈាប+ណេ+ហិ.ប. ] ចូរដុត, ចូរញ៉ាំង...ឱ្យឆេះ ។

**ឈាម** គុ. [ ឈេឬឈា+ម ] គឺភ្លើងឆេះហើយ, គឺភ្លើងកំពុងឆេះ ។ **. សិត្ថ** នពុំ. គ្រាប់បាយដែលភ្លើងឆេះហើយ (បាយក្តាំង, បាយខ្លោច) ។ **. កាល** ពុំ. កាលនៃគន្លុកដីគឺភ្លើងកំពុងឆេះ, .ឆេះហើយ ។ **. ខាណុមត្តក** ពុំ. ទីបំផុតនៃដង្គត់គឺភ្លើងឆេះហើយ, ចុងនៃដង្គត់គឺភ្លើងឆេះហើយ ។

**ឈាយ** កិ. [ ឈេ+អ+ហិ.ប., លុបហិ.ប. ] ចូរដុត, ចូរគិត, ចូរពិនិត្យ, ចូរសំឡឹង ។

**ឈាតិ** កិ. [ ឈេ+អ+តិ.វ. ] ដុត, ឆេះ ។

**ឈាយនវស** ពុំ. [ ឈាយន+វស ] អំណាចនៃកិ.ឆេះ, .ដុត ។

**ឈាយន្ត** គុ. [ ឈេ+អ+អន្ត ] កាលដុត,... ។

**ឈាយមាន** គុ. [ ឈេ+អ+មាន ] កាលដុត, កាលឆេះ, គឺភ្លើងកំពុងឆេះ ។

**ឈាយសិ** កិ. [ ឈេ+អ+សិ_វ. ] សញ្ជប់សញ្ជឹង, សុបសៅ, សំកុក, ដុត ។

**ឈាយំ** គុ. [ ឈេ+អ+អន្ត+សិ_វិ., ផ្លាស់ន្ត+សិ_វិ.>អំ ] កាលដុត, (កាល ញុំាងកិលេសឱ្យឆេះ) ។

**ឈាយិត្វា** អ. [ ឈេ+ឥ_អា.+ត្វា ] ឆេះហើយ, ដុតហើយ ។

**ឈាយី** គុ. [ ឈេ+ណី ] អ្នកសំឡឹង, អ្នកពិនិត្យ, អ្នកស្មឹងស្មាធិ៍, អ្នកមានឈាន; វិ. **ឈាយតីតិ> ឈាយី** ។

**ឈាយឹសុ** កិ. [ ឈេ+អ+ឧំ_អជ្ជ. ] ឆេះហើយ, ដុតហើយ ។



**ញត្ត** នពុំ. [ ញាត+ត្ត ] ភាវៈនៃកិ.ដឹង; វិ. **ញាតស្ស ជាននស្ស ភាវោ> ញត្តំ** ។

**ញត្វា** អ. [ ញា+ត្វា ] ដឹងហើយ, ជ្រាបហើយ ។

**ញាណ** នពុំ. [ ញា+យុ ] កិ.ដឹង, សេចក្តីឬធម្មជាតជាគ្រឿងដឹង (ញាណ, ប្រាជ្ញា); វិ. **ញាយតេតិ> ញាណំ** ។ - **ខគ្គ** ពុំ. ព្រះខាន់គឺញាណ, ញាណដូចជាកំបិតកោរ ។ - **អគ្គិ** ពុំ. ភ្លើងគឺញាណ, ញាណដូចជាភ្លើង ។ - **បថ** ពុំ. គន្លងគឺញាណ, ផ្លូវនៃញាណ ។ - **បរិបាក** ពុំ. កិ.ចាស់ទុំពេញនៃញាណ (**បរិបាក**<បរិ+បច+ណ = ចាស់ទុំពេញ, ចាស់ពេញលេញ, ចាស់គ្រប់គ្រាន់, ឆ្អិនល្អ) ។ - **បទីប** ពុំ. ប្រទីបគឺញាណ, ញាណដូចជាប្រទីប ។ - **ផុសនា** ឥ. កិ.ពាល់ត្រូវគឺញាណ, ធម្មជាតិជាគ្រឿងពាល់ត្រូវគឺញាណ, ធម្មជាតិគឺបុគ្គលគប្បីពាល់ត្រូវគឺញាណ ។ - **សម្ប-យុត្ត** គុ. ដ៏សម្បយុត្តដោយញាណ, ដែលប្រកបព្រម ហើយដោយញាណ ។

**ញាណានុភាវ** ពុំ. [ ញាណ+អានុភាវ ] អានុភាពនៃញាណ ។

**ញាត** គុ. [ ញា+ត ] គឺ... ដឹងហើយ; នពុំ. កិ.ដឹង ។

**ញាតក** ពុំ. [ ញា+តិ+ក_ស. ] ជនដែលគេត្រូវស្គាល់ (ញាតិ); វិ. **ញាយេតព្វោតិ> ញាតិ; ញាតិ ឯវ> ញាតកោ** ។

**ញាតត្ថចរិយា** ឥ. [ ញាតិ+អត្ថ+ចរិយា ] កិ.ប្រព្រឹត្តិដើម្បីប្រយោជន៍ដល់ញាតិ, ការប្រព្រឹត្តិដើម្បីជាប្រយោជន៍ដល់ញាតិ ។

**ញាតធម្ម** គុ. [ ញាត+ធម្ម ] អ្នកមានធម៌ដឹងហើយ; វិ. **ញាតោ ធម្មោ យេហិ តេ> ញាតធម្មា** ។

**ញាតបរិញ្ញា** ឥ. [ ញាត+បរិញ្ញា ] ឈ្មោះញាតបរិញ្ញា, ការកំណត់ដឹងដោយកិ.ដឹង, ធម្មជាតិគឺបុគ្គលគប្បីកំណត់ដឹងដែលខ្លួនដឹងហើយ ។

**ញាតភាវ** ពុំ. [ ញាត+ភាវ ] ភាវៈនៃ... ជាគុណជាតគឺខ្លួនដឹងហើយ ។

**ញាតិ** [ ញា+តិ ] (ជន) ដែលគេត្រូវស្គាល់ (ញាតិ); វិ. ចូរមើល "ញាតក" ។ - **ឧបដ្ឋាក** ពុំ. ញាតិនិងជនជាឧបដ្ឋាក ។ - **កុល** នពុំ. ត្រកូលនៃញាតិ ។ - **គណ** ពុំ. ពួកនៃញាតិ, ក្រុមនៃញាតិ ។ - **ជន** នពុំ. ជនជាញាតិ ។ - **ទារក** ពុំ. ទារកជាញាតិ, ទារកនៃញាតិ ។ - **ធីតា** ឥ. ធីតាជាញាតិ, ធីតានៃញាតិ ។ - **បរិវដ្ដ** ពុំ. កិ.វិលទៅជុំវិញនៃញាតិ, ការវិលទៅជុំវិញនៃត្រកូលជាញាតិ (ផ្លូវនៃញាតិ) ។ - **ពន្ធុវិរហិត** គុ ដែលប្រាសហើយចាកញាតិនិងផៅពង្ស ។ - **មជ្ឈ** នពុំ. កណ្ដាលនៃញាតិ ។ - **មិត្ត** ពុំ. ញាតិនិងមិត្រ ។ - **សត** នពុំ. រយនៃញាតិ ។ - **សមាគម** ពុំ. ទីជាទីមកព្រមនៃញាតិ, កាលជាទីប្រជុំនៃញាតិ, កិ.ជួបជុំនៃញាតិ, ការជួបជុំនៃញាតិ ។ - **សង្ឃបុរក្ខត** គុ. គឺពួកនៃញាតិធ្វើក្នុងខាងមុខហើយ, គឺពួកនៃញាតិចោមរោមហើយ (**បុរក្ខត**<បុរ+ករ>ខ+ត) ។ - **សង្ឃវិនាស** ពុំ. សេចក្ដីវិនាសនៃពួកនៃញាតិ ។ - **សំសគ្គ** ពុំ. សេចក្ដីជាប់ព្រមដោយញាតិ, ការជាប់ជំពាក់ដោយញាតិ, ការច្របូកច្របល់ដោយញាតិ (<សំ+សជ+ណ, ជ>



គ>គ្គ, លុបណ) ។ - **សំសដ្ឋ** គុ. ដែលជាប់ព្រមដោយញាតិ, ដែលច្របូកច្របល់ដោយញាតិ (សំ+សជ+ត, ជ+ត>ដ្ឋ) ។ - **សង្គហ** ពុំ. សេចក្ដីសង្គ្រោះដល់ញាតិឬនូវញាតិ ។ - **សាលោហិត** ពុំ ញាតិនិងសាលោហិត, ញាតិនិងជនអ្នកប្រព្រឹត្តទៅមួយអន្លើដោយលោហិត, ញាតិនិងជនអ្នកមានលោហិតស្មើគ្នា, ញាតិនិងជនអ្នកមានលោហិតរួមគ្នា ។ - **សាលោហិតី** ឥ. ស្រីជាញាតិនិងជាសាលោហិត ។ - **សិនេហ** ពុំ. សេចក្ដីស្នេហាចំពោះញាតិ, សេចក្ដីស្រឡាញ់ក្នុងញាតិ ។ - **សុហជ្ជ** នពុំ. ញាតិនិងបុគ្គលជាទីស្រឡាញ់, ញាតិនិងភាវៈនៃបុគ្គលអ្នកមានហឫទ័យល្អ ឬចិត្តល្អ (**សុហជ្ជ**<សុ+ហទ+ណ្យ = វិ. **សុន្ទរំ ហទយមេតស្សាតិ> សុហទោ; សុហទស្ស ភាវោ> សុហជ្ជំ** ។

**ញាតុំ** អ. [ ញា+តុំ ] ដើម្បីដឹង, កិ.ដឹង ។

**ញាបនត្ថ** ពុំ. [ ញាបន+អត្ថ ] ប្រយោជន៍ដល់កិ.ញុំាងបុគ្គលឱ្យដឹង, សេចក្ដីត្រូវការដល់កិ.ញុំាង...ឱ្យដឹង ។

**ញាបេតុកាម** គុ. [ ញាបេតុំ+កម+ណ ] អ្នកប្រាថ្នាដើម្បីញុំាង...ឱ្យដឹង, អ្នកចង់ដើម្បីញុំាងអ្នកណានីមួយឱ្យដឹង ។

**ឋត្វា** អ. [ ឋា+ត្វា ] ឋិតនៅហើយ, តាំងនៅហើយ, ឈរនៅហើយ ។

**ឋបនដ្ឋាន** នពុំ. [ ឋបន+ឋាន ] ទីជាទីតាំងទុក, ទីជាទីតំកល់ទុក ។

**ឋបនោកាស** ពុំ. [ ឋបន+ឱកាស ] ឱកាសជាទីតាំងទុក, ឱកាសជាទីដំកល់ទុក ។

**ឋបយឹសុ** គិ. [ ឋប+ណយេ+ឥំ_អជ្ជ. ] តាំងទុកហើយ, តំកល់ទុកហើយ ។

**ឋបាបេត្វា** អ. [ ឋប+ណាបេ+ត្វា ] ញុំាង...ឱ្យតាំងទុកហើយ, ឱ្យតំកល់ទុកហើយ, -ឱ្យដាក់ហើយ ។

**ឋបាបេសិ** គិ. [ ឋប+ណាបេ+ឦ_អជ្ជ. ] ញុំាង...ឱ្យតាំងទុកហើយ,... ។

**ឋបិត** គុ. [ ឋប+ឥ_អា.+ត ] គឺ...តាំងទុកហើយ, -តំកល់ទុកហើយ, -ដាក់ហើយ ។ -**អាលម្ពក** នពុំ. ផ្លែកន្ទួតព្រៃដែលបុគ្គលតំកល់ទុកហើយ ។ -**កណ្ណិកា** ឥ. ហោជាងគឺ...តំកល់ទុកហើយ ។ -**កំសតាល** ពុំ. ថាសដែល...តំកល់ទុកហើយ ។ -**កិលញ្ជ** ពុំ. កន្ទេលដែល...តាំងទុកហើយ, -តំកល់ទុកហើយ ។ -**កុម្ភណ្ឌ** ពុំ. ផ្លែល្ពៅដែល...ដាក់ហើយ, -តំកល់ហើយ ។ -**ដ្ឋាន** នពុំ. ទីនៃបុគ្គលតំកល់ទុកហើយ ។ -**ឋបិតដ្ឋាន** នពុំ. ទីនៃ...គឺបុគ្គលដំកល់ទុកហើយៗ ។ -**និយាម** ពុំ. ចំនងនៃ...គឺបុគ្គលតាំងទុកហើយ, ការកំណត់នៃ...គឺ... ។ -**ភត្ត** នពុំ. ភត្ត



គឺ... ។ -**ភាគភត្ត** នពុំ. ភត្តជាចំណែកគឺ... ។ -**ភារ** ពុំ. ភារៈនៃ...ជារបស់គឺ... ។ -**មណិរតន** នពុំ. កែវគឺកែវមណីដែល... ។ -**បត្ត** ពុំ. គ្រាន់ តែគឺ... ។ -**មំស** នពុំ. សាច់គឺ... ។ -**វជិរបន្តិ** ឥ. របៀបនៃពេជ្រ ដែល... ។ -**សទិស** គុ. ប្រាកដស្មើដោយទីដែល... ។

**ឋបិយមានោ** គុ. [ ឋប+ឥ_អា.+យ+មាន ] គឺ...កាលតាំងទុក,... ។

**ឋបេត្វា** អ. [ ឋប+ណេ+ត្វា ] ញុំាង...ឱ្យឋិតនៅហើយ, តាំងទុកហើយ, តំកល់ទុកហើយ, ទុកហើយ, លើកលែង, លើកទុក, វៀរលែង ។

**ឋបេន្ត** គុ. [ ឋប+ឯ ឬណេ+អន្ត ] កាលតាំងទុក, កាលដាក់,... ។

**ឋបេសិ** គិ. [ ឋប+ឯឬណេ+ឦ_អជ្ជ.+ត.ភា. ] តាំងទុកហើយ, តំកល់ទុកហើយ ។

**ឋបេហិ** គិ. [ ឋប+ឯ ឬណេ+ហិ_ប. ] ចូរតាំងទុក, ចូរដាក់ ។

**ឋស្សតិ** គិ. [ ឋា+អ+ស្សតិ_ភ. ] នឹងឋិតនៅ ។

**ឋាតព្វ** គុ. [ ឋា+តព្វ ] គឺ...គប្បីតាំងនៅ, គឺ...គប្បីឈរ ។

**ឋាតិ** គិ. [ ឋា+អ+តិ_វ. ] តាំងនៅ, ឋិតនៅ, ឈរនៅ ។

**ឋាតុំ** អ. [ ឋា+តុំ ] ដើម្បីតាំងនៅ, -ឋិតនៅ, -ឈរនៅ ។

**ឋាន** នពុំ. [ ឋា+យុ ] ទី, ទីជាទីតាំង; ហេតុ, ហេតុជាទីតាំង, ហេតុជាទីតាំងនៃផល; គិ.ឋិតនៅ, គិ.ឈរ, ឋានៈ, ជាន់, ថ្នាក់ ។

**ឋានន្តរ** នបុំ. [ ឋាន+អន្តរ ] លំដាប់នៃទី..., លំដាប់នៃទីជាទីតាំង, ឋានន្តរ, ឋានន្តរស័ក្តិ ។ . **ប្បត្ត** គុ. ដល់ហើយនូវលំដាប់នៃទី, .នូវទីជាលំដាប់, .នូវឋានន្តរ, .នូវឋានន្តរស័ក្តិ, មានឋានន្តរស័ក្តិដល់ហើយ ។

**ឋានាទិ** គុ. [ ឋាន+អាទិ ] ឥរិយាបថ មានកិ.ឈរជាដើម; វិ. **ឋានំ អាទិ យស្ស សោ> ឋានាទិ** ។

**ឋិត** គុ. [ ឋា+ត, អានៃឋា>ឥ ] ឋិតនៅហើយ, តាំងនៅហើយ, ឈរនៅហើយ ។ . **កាល** បុំ. កាលនៃ...តាំងនៅហើយ ។ . **កេវដ្ដ** បុំ. ព្រានប្រមង់អ្នកឈរនៅហើយ, ព្រានសំណាញ់អ្នកឈរនៅហើយ ។ . **ក្ខណ** បុំ. ខណៈនៃ...តាំងនៅហើយ, .ឈរនៅហើយ ។ . **ដ្ឋាន** នបុំ. ទីនៃ...តាំងនៅហើយ,... ។ . **ត្ត** នបុំ. ភាវៈនៃ...ជា...តាំងនៅហើយ ។ . **ទុព្វលរុក្ខសទិស** គុ. ប្រាកដស្មើដោយដើមឈើមានកម្លាំងគឺទោសប្រទូស្ត (មានកម្លាំងថយ, មានកម្លាំងខ្សោយ) តាំងនៅហើយ ។ . **និសិន្នដ្ឋានាទិ** គុ. (មី) មានទីនៃខ្លួនឈរហើយនិងទីនៃខ្លួនអង្គុយហើយជាដើម ។ . **បុត្ត** បុំ. បុត្រអ្នកតាំងនៅហើយ ។ . **បុរិស** បុំ. បុរសអ្នកឈរនៅហើយ ។ . **ភាវ** បុំ. ភាវៈនៃ...ជា...តាំងនៅហើយ ។ . **មជ្ឈន្តិក** បុំ. សម័យនៃព្រះអាទិត្យប្រព្រឹត្តទៅក្នុងទីពាក់កណ្តាលតាំងនៅហើយ, វេលាថ្ងៃត្រង់តាំងនៅហើយ ។ . **សរីរ** គុ. អ្នកមានសរីរៈតាំងនៅហើយ ។

**ឋិតក** គុ. [ ឋា+ត+ក.ស. ] អ្នកឋិតនៅ, អ្នកឈរនៅ; វិ. **តិដ្ឋតីតិ> ឋិតោ; ឋិតោ ឯវ> ឋិតកោ** ។



**ឋិតិ** ឥ. [ ឋា+តិ, អានៃឋា>ឥ ] កិ.ឋិតនៅ, កិ.តាំងនៅ; វិ. **ឋានំ> ឋិតិ** ។ . **ភាវ** បុំ. ភាវៈនៃកិ.តាំងនៅ ។

**ឋិតិក** គុ. [ ឋា+តិ+កស. ] លំដាប់, ជាលំដាប់ (តាមទំលាប់ថាអ្នកកាន់បញ្ជី); វិ. **ឋាបនំ> ឋិតិ; ឋិតិ ឯវ> ឋិតិកា; (ឋិតិកាតិ ឋបិតាតិ)** ។ យ.វិ. ។

**ឌដ្ឋ** គុ. [ ឌំស+ត>ឌដ្ឋ ] ដី... ខាំហើយ, -ចឹកហើយ ។

**ឌយ្ហនភាវ** ពុំ. [ ឌយ្ហន+ភាវ ] ភាវៈដីកិ.ដុត, -កិ.ឆេះ (ប្រើជា "ឌយ្ហន..." ក៏មាន) ។

**ឌយ្ហន្ត** គុ. [ ឌហ+យ+អន្ត ] កាលដុត, កាលឆេះ, កាលរលាក ។

**ឌយ្ហមាន** គុ. [ ឌហ+យ+មាន ] ដីភ្លើងកាលឆេះ, -កំពុងឆេះ ។ - **គេហ** នបុំ. ផ្ទះដីភ្លើងកំពុងឆេះ ។

**ឌយ្ហរេ** កិ. [ ឌហ+យ+តិ-វ.ឬអន្តិ-វ. ] ដីភ្លើងរមែងឆេះ, ដី... ដុត ។

**ឌយ្ហិតុំ** អ. [ ឌហ+យ+ឥ-អា.+តុំ ] ដើម្បីឆេះ, ដើម្បីរលាក ។

**ឌហតិ** កិ. [ ឌហ+អ+តិ-វ. ] រមែងឆេះ, ដុត, រលាក ។

**ឌហតុ** កិ. [ ឌហ+អ+តុ-ប. ] ចូរឆេះ, ចូរដុត, ចូររលាក ។

**ឌយ្ហនវស** ពុំ. [ ឌយ្ហន+វស ] អំណាចនៃកិ.ឆេះ, -កិ.ដុត, -កិ.រោលរាល ។

**ឌយ្ហន្ត** គុ. [ ឌហ+យ+អន្ត ] កាលដុត, កាលឆេះ ។

**ឌហំ** គុ. [ ឌហន្ត+សិ-វិ., ផ្លាស់ន្ត+សិ-វិ.>អំ ] កាលដុត, កាលឆេះ ។

**ឌហិត្វា** អ. [ ឌហ+ឥ-អា+ត្វា ] ដុតហើយ... ។

**ឌំសន** នបុំ. [ ឌំស+យុ ] កិ.ចឹក, ជាទីចឹក, -ខាំ, -ពិច ។ - **ដ្ឋាន** នបុំ. ទីជាទីចឹក,.. ។ - **ភយ** នបុំ. ខ្លាចអំពីកិ.ចឹក, ភ័យអំពីកិ. ខាំ ។



**ឌំសាបេតិ** កិ. [ ឌំស+ណាបេ+តិ-វ. ] ញុំាង...ឱ្យចឹក, -ឱ្យខាំ ។

**ឌំសាបេត្វា** អ. [ ឌំស+ណាបេ+ត្វា ] ញុំាង...ឱ្យចឹកហើយ, -ឱ្យខាំហើយ ។

**ឌំសាបេន្ត** គុ. [ ឌំស+ណាបេ+អន្ត ] កាលញុំាង...ឱ្យចឹក, -ឱ្យខាំ ។

**ឌំសិ** កិ. [ ឌំស+អ+ឦ-អជ្ជ.+ស-អា. ] ចឹកហើយ, ខាំហើយ ។

**ឌំសិតុំ** អ. [ ឌំស+ឥ-អា.+តុំ ] ដើម្បីចឹក, -ខាំ ។

**ឌំសិត្វា** អ. [ ឌំស+ឥ-អា.+ត្វា ] ចឹកហើយ, ខាំហើយ ។

**ឌាហក** គុ. [ ឌហ+ណ្វុ ] អ្នកដុត; ភ្លើង, ភ្លើងឆេះ ។

**ឌាហ** ពុំ. [ ឌហ+ណ ] សេចក្ដីក្ដៅក្រហាយ, សេចក្ដីរោលរាល, សេចក្ដីអន្ទះអន្ទែង ។

**តក្ករ** ពុ. [ ត+ករ+អ ] អ្នកធ្វើនូវធម្មវចនៈនោះ, អ្នកធ្វើនូវកម្មនោះ, អ្នកធ្វើនូវ...នោះ; វិ. **តំ ករោតីតិ> តក្ករោ** ។

**តក្កសិល** អ.ន. ក្រុងឈ្មោះតក្កសិលា ។ - **គាមិសត្ថវាហ** ពុំ. ឈ្មួញអ្នកទៅកាន់ក្រុងតក្កសិលា, ពាណិជទៅកាន់ក្រុងតក្កសិលា, ជនអ្នកនាំទៅនូវពួកអ្នកទៅកាន់ក្រុងតក្កសិលា (**សត្ថវាហ**< សត្ថ+វហ+ណ ជាវចនៈនៃវាណិជនិងអាបណិក) ។ - **ជាតក** នពុំ. តក្កសិលជាតក, ជាតកដ៏បណ្ឌិតកំណត់ដោយព្រះរាជាជាធំក្នុងក្រុងតក្កសិលា ។ - **នគរ** នពុំ. ក្រុងតក្កសិលា ។ - **មគ្គ** ពុំ. ផ្លូវជាទីទៅកាន់ក្រុងតក្កសិលា ។ - **វជ្ជ** នពុំ. ភាវៈនៃ...ជាស្ដេចក្នុងក្រុងតក្កសិលា ។

**តក្កាទិអម្ពិល** នពុំ. [ តក្កាទិ+អម្ពិល ] រសជូរមានទឹកដោះជូរជាដើម ។

**តគរ** នពុំ. [ តគិ+អរ ] ក្រស្នា ។ - **ចន្ទន** នពុំ. ក្រស្នានិងចន្ទន៍, ក្លិននៃក្រស្នានិងចន្ទន៍ ។ - **ចន្ទនី** ឥ. ក្រស្នានិងចន្ទន៍, ក្លិននៃក្រស្នានិងចន្ទន៍ ។ - **មល្លិកា** ឥ. ក្រស្នានិងក្លាំពាក់, ក្រស្នានិងម្លិះ, ក្លិននៃក្រស្នានិងក្លាំពាក់ ។ - **សិខិបច្ចេកពុទ្ធ** ពុំ. ព្រះបច្ចេកពុទ្ធឈ្មោះតគរសិខី ។

**តច** ពុំ. [ តច+អ ] (អវយវៈ) រក្សានូវសរីរៈ (ស្បែក, សម្បក); វិ. **តចតិ បាលេតីតិ> តចោ** ។ - **បញ្ចកកម្មដ្ឋាន** នពុំ. កម្មដ្ឋានមានស្បែកជាគំរប់៥, កម្មដ្ឋានមានប្រមាណ៥ នៃស្បែក ។ - **បរិច្ឆិន្ន** ពុ. គឺស្បែកបិទបាំងហើយ, ដែលបិទបាំងហើយ



ដោយស្បែក ។

**តជ្ជក** ពុំ. [ តជ្ជ+ណ្វុ ] (ជន) អ្នកចាំង ឬអ្នកឈ្លួស (ជាងឈើ); វិ. **តជ្ជតិ តនុករោតីតិ> តជ្ជកោ** ។

**តជ្ជន** ពុ. [ តជ្ជ+អ+យុ ] ការចាំង, ការឈ្លួស, ការជម្រះ ។

**តជ្ជាបេត្វា** អ. [ តជ្ជ+ណាបេ+ត្វា ] ញុំាង...ឱ្យចាំងហើយ, -ឱ្យឈ្លួសហើយ ។

**តជ្ជាបេតិ** គិ. [ តជ្ជ+ណាបេ+ព្យ_អជ្ជ.+ត.វា. ] ញុំាង...ឱ្យចាំងហើយ, -ឱ្យឈ្លួសហើយ, ឱ្យជម្រះហើយ ។

**តជ្ជិតុ** គិ. [ តជ្ជ+អ+ឧំ_អជ្ជ. ] ចាំងហើយ, ច្រាសហើយ, ឈ្លួសហើយ ។

**តជ្ជេត្វា** អ. [ តជ្ជ+ឯ+ត្វា ] ចាំងហើយ, ច្រាសហើយ, ឈ្លួសហើយ ។

**តជ្ជិត** ពុ. [ តជ្ជ+ឥ_អា.+ត ] គឺ...គម្រាមហើយ, -គ្រហឹម, -គំរាមហើយ ។

**តជ្ជិស្សតិ** គិ. [ តជ្ជ+អ+ឥ_អា.+ស្សតិ_ភ. ] នឹងគម្រាម ។

**តជ្ជេត្វា** អ. [ តជ្ជ+ឯ+ត្វា ] គម្រាមហើយ ។

**តជ្ជេន្ត** ពុ. [ តជ្ជ+ឯ+អន្ត ] កាលគម្រាម,... ។

**តជ្ជេស្សតិ** គិ. [ តជ្ជ+ឯ+ស្សតិ_ភ. ] នឹងគម្រាម,... ។

**តដតដាយន្ត** ពុ. [ តដតដ+អាយ+អន្ត ] កាលប្រព្រឹត្តនូវសំឡេង

ថាតដតដះ ។

**តដតដាយមាន** [ តដតដ+អាយ+មាន ] កាលប្រព្រឹត្តនូវសំឡេងថា តដតដះ ។

**តណ្ឌុល** ពុំ. អង្ករ ។ . **កណមត្ត** គុ. មានអង្ករបាក់ជាប្រមាណ, មានចុងនៃអង្ករជាប្រមាណ ។ . **ទោណ** នពុំ. ទោណៈនៃអង្ករ, អង្ករមានទោណៈជាប្រមាណ ។ . **នាឡិមត្ត** គុ. វត្ថុត្រឹមតែនាឡិនៃអង្ករ, អង្ករមាននាឡិជាប្រមាណ ។ . **នាឡិ** ឥ. នាឡិនៃអង្ករ, នាឡិដ៏ពេញដោយអង្ករ ។ . **អាទិបាថេយ្យ** នពុំ. វត្ថុជាប្រយោជន៍ក្នុងផ្លូវមានអង្ករជាដើម, ស្បៀងមានអង្ករជាដើម ។

**តណ្ហក្ខយ** ពុំ. [ តណ្ហា+ខយ ] ធម៌ជាទីអស់ទៅនៃតណ្ហា; វិ. **តណ្ហានំ ខយោ> តណ្ហក្ខយោ** (តណ្ហក្ខយ បើជាឈ្មោះរបស់ មគ្គ ត្រូវប្រែថា ជាគ្រឿងអស់ទៅនៃតណ្ហា; ជាឈ្មោះរបស់ផល ត្រូវប្រែថា សេចក្ដីអស់ទៅនៃតណ្ហា; ជាឈ្មោះរបស់និព្វាន ត្រូវប្រែថា ជាទីអស់ទៅនៃតណ្ហា) ។ . **អន្ត** ពុំ. ទីបំផុតនៃធម៌ជាទីអស់ទៅនៃតណ្ហា ។ . **រតិ** គុ. អ្នកត្រេកអរហើយក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ។

**តណ្ហា** ឥ. [ តស+ណ្ហ+អា_ឥ ] សេចក្ដីស្រេកឃ្លាន, សេចក្ដីប្រាថ្នា, សេចក្ដីចង់, ចំណង់ (ធម្មជាតិជាគ្រឿងញុំាងសត្វឱ្យតក់ស្លុត; វិ. **តាសេតិ ឯតាយាតិ> តណ្ហា**) ។ . **ឧស្សាទាភាវ** ពុំ. កិ.មិនមាននៃការខ្ពស់ឡើងនៃតណ្ហា, កិ.មិនមាននៃកិ.ផុសឡើងនៃតណ្ហា, កិ.មិនមាននៃកិ.ក្រាស់ឡើងនៃតណ្ហា ។ . **គតិក** គុ. អ្នកប្រព្រឹត្តទៅក្នុងគតិនៃតណ្ហា ។ . **គាហសង្ខាត** គុ. ពោលគឺកិ.កាន់យកនៃតណ្ហា, គឺបណ្ឌិតពោលថាកិ.ចាប់កាន់នៃតណ្ហា ។ . **ទិដ្ឋិនិស្សយ** ពុំ. និស្ស័យគឺតណ្ហានិងទិដ្ឋិ, តណ្ហានិស្ស័យនិងទិដ្ឋិនិស្ស័យ (ធម៌ជាគ្រឿងអាស្រ័យគឺតណ្ហានិងទិដ្ឋិ) ។ . **នុសយ** ពុំ. តណ្ហានុស័យ, ធម៌ជាគ្រឿងដេករឿយៗគឺតណ្ហា, កិលេសជាទីដេកតាមគឺតណ្ហា ។ . **ពន្ធន** នពុំ. វត្ថុជាគ្រឿងចងគឺតណ្ហា, ចំណងគឺតណ្ហា ។ . **ភវបរិក្ខីណ** គុ. មានតណ្ហានិងភពអស់រលីងហើយ ។ . **ភាវ** ពុំ. កិ.មិនមាននៃតណ្ហា ។ . **មានទិដ្ឋិឥញ្ជិត** នពុំ. កិលេសជាតជាគ្រឿងញាប់ញ័រគឺតណ្ហានិងមានះនិងទិដ្ឋិ, កិលេសជាតគឺបុគ្គលឱ្យញាប់ញ័រគឺតណ្ហានិងមានះនិងទិដ្ឋិ ។ . **លតា** ឥ. វល្លិគឺតណ្ហា, តណ្ហាដូចជាវល្លិ ។ . **វគ្គវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវសេចក្ដីនៃតណ្ហាវគ្គ ។ . **វឌ្ឍកី** ពុំ. ជាងឈើគឺតណ្ហា ។ . **វន** នពុំ. ព្រៃគឺតណ្ហា, តណ្ហាដូចជាព្រៃ ។ . **វរត្តា** ឥ. ព្រ័ត្រគឺតណ្ហា ។ . **វសិក** គុ. អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា, អ្នកលុះក្នុងអំណាចនៃតណ្ហា, អ្នកធ្លាក់ចុះក្នុងអំណាចនៃតណ្ហា; វិ. **តណ្ហាវសេ វត្តតីតិ> តណ្ហាវសិកោ** (គួរចងថា គច្ឆតិតទ្ធិត, បកតិតទ្ធិតផងចុះ) ។ . **វស** ពុំ. អំណាចនៃតណ្ហា, អំណាចនៃសេចក្ដីប្រាថ្នា ។ . **វិបរីត** សេចក្ដីវិបរិតនៃតណ្ហា ។ . **សន្តាវ** ពុំ. សេចក្ដីក្ដៅក្រហាយព្រោះដោយអំណាចនៃតណ្ហា ។ . **សម** គុ. ស្មើដោយតណ្ហា ។ . **សិនេហមក្ខិត** គុ. គឺជ័រគឺតណ្ហាប្រឡាក់ហើយ, ដែលប្រឡាក់ហើយដោយជ័រគឺតណ្ហា ។ . **សោត** នពុំ. ក្រសែនៃតណ្ហា ។

**តតិយ** ប្ង.សំ. [ តិ+តិយ ] បុំ. ទី៣, គំរប់៣; វិ. **តិណ្ណំ បូរណោ> តតិយោ**; ឥ. **តិស្សន្នំ បូរណី> តតិយា**; នបុំ. **តិណ្ណំ បូរណំ> តតិយំ** ។ - **ផល** នបុំ. ផលទី៣ ។ - **មាស** បុំ. ខែទី៣ ។ - **វារ** បុំ. វារៈទី៣, វេនទី៣, លើកទី៣ ។ ល ។

**តតោនិទាន** គុ. [ តតោ+និទាន ] មានទុក្ខនោះជាគ្រឿងប្រគល់ឱ្យនូវផល, មានទុក្ខនោះជាហេតុ, មាន...នោះជា... ។

**តត្ត** គុ. [ តប+ត ] ដ៏ក្តៅ, ក្តៅហើយ, គឺភ្លើងឱ្យក្តៅហើយ ។ - **កបាល** បុំ., នបុំ. អំបែងដ៏ក្តៅ ។ - **ភាវ** បុំ. ភាវៈនៃ...ជារបស់ក្តៅហើយ ។

**តថប្បដិវេធនត្ត** បុំ. [ តថ+បដិវេធ+អត្ត ] សេចក្តីជាគិ.ចាក់ធ្លុះចំពោះនូវសេចក្តីពិត, សេចក្តីជាគិ.ត្រាស់ដឹងដោយពិត, សេចក្តីជាគិ.ចាក់ធ្លុះនូវតច្ឆៈជារបស់ពិត ។

**តថភាវ** បុំ. [ តថ+ភាវ ] ភាវៈនៃពាក្យនោះជាពាក្យពិត, ភាវៈនៃសច្ចៈនោះជាធម៌ពិត ។

**តថា** និ. [ ត+ថា ] ប្រការៈនោះ, ដោយប្រការៈនោះ, យ៉ាងនោះ, ដូច្នោះ ។ ពា ។ - **ករណភាវ** បុំ. ភាវៈនៃគិ.ធ្វើយ៉ាងនោះ, ភាវៈគឺគិ.ធ្វើដោយប្រការៈនោះ ។

**តថាគត** បុំ. [ តថា+អាគត, ឬតថា+គត ] ព្រះពុទ្ធទ្រង់មកហើយដោយប្រការៈនោះ, ព្រះពុទ្ធទ្រង់ទៅហើយដោយប្រការៈនោះ (ព្រះតថា-គត); វិ. **តថា អាគតោតិ> តថាគតោ; តថា គតោ-**



**តិ> តថាគតោ** ។ - **សាវក** បុំ. សាវកនៃព្រះតថាគត ។ - **គារវ** បុំ. ភាវៈនៃសេចក្តីគោរពចំពោះព្រះតថាគត, សេចក្តីគោរពក្នុងព្រះតថាគត ។ - **ប្បដិវេទិត** គុ. គឺព្រះតថាគតឱ្យដឹងទូទៅហើយ, គឺព្រះតថាគតទ្រង់ប្រកាសហើយ ។

**តថានិបន្ន** គុ. [ តថា+និបន្ន ] ដេកហើយយ៉ាងនោះ, កំពុងដេកដូច្នោះ ។

**តថារូប** គុ. [ តថា+រូប ] មានសភាពយ៉ាងនោះ, មានរូបដូច្នោះ; វិ. **តថា រូបំ យស្ស សោ> តថារូបោ** ។

**តថាវិធ** គុ. [ តថា+វិធ ] មានប្រការៈយ៉ាងនោះ; វិ. **តថា វិធោ ឯតស្សាតិ> តថាវិធោ** ។

**តទង្គ** នបុំ. [ ត+អង្គ, ចុះទ_អា. ] អង្គនោះ, អង្គនៃ...នោះ, អង្គនោះៗ ។ - **វស** បុំ. អំណាចនៃអង្គនោះ ។ - **វិក្ខម្ភន-សមុច្ឆេទប្បដិប្បស្សទ្ធិនិស្សរណវិមុត្តិ** ឥ. តទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ និងសមុច្ឆេទវិមុត្តិ និងបដិប្បស្សទ្ធិវិមុត្តិ និងនិស្ស-រណវិមុត្តិ, គិ.ផុតស្រឡះដោយអំណាចនៃអង្គនោះ និងគិ.ផុតស្រឡះដោយអំណាចនៃគិ.សង្កត់សង្កិន និងគិ.ផុតស្រឡះដោយអំណាចនៃគិ.កាត់ផ្តាច់ និងគិ.ផុតស្រឡះដោយអំណាចនៃគិ.រម្ងាប់ចំពោះ និងគិ.ផុតស្រឡះដោយអំណាចនៃគិ.រលាស់ចេញ ។ - **វិ-មុត្តិ** ឥ. តទង្គវិមុត្តិ, គិ.ផុតវិសេសដោយអង្គនោះ, គិ.រួចស្រឡះដោយអង្គនោះ ៗ ។

**តទនន្តរ** នបុំ. [ ត+អនន្តរ, ចុះទ_អា. ] លំដាប់នៃកាលនោះ, លំដាប់

អំពី...នោះ ។

**តទនុរូប** គុ. [ ត+អនុរូប, ចុះទ_អា. ] មានសភាពដ៏សមគួរដល់...នោះ, ដ៏សមគួរដល់...នោះ ។

**តទភិមុខ** គុ. [ ត+អភិមុខ, ចុះទ_អា. ] មានមុខឆ្ពោះទៅកាន់...នោះ ។

**តទហ** [ ត+អហ, ចុះទ_អា. ] ថ្ងៃនោះ ។

**តទហុជាត** គុ. [ តទហ+ជាត, យកអ នៃ ហ>ឧ ] ដែលទើបនឹងកើតក្នុងថ្ងៃនោះ, កើតហើយក្នុងថ្ងៃនោះ (អហ_ សព្ទនេះកាលបើមចូលជាបទសមាសហើយទៀងតែយកស្រៈអរបស់ខ្លួនជាឧខ្លះ, ជាឱខ្លះ) ។

**តទហុប្បព្វជិត** គុ. [ តទហ+បព្វជិត ] ដែលទើបនឹងបួសក្នុងថ្ងៃនោះ, បួសហើយក្នុងថ្ងៃនោះ ។

**តទា** ក.វ. [ ត+ទា ] ក្នុងកាលនោះ, គ្រានោះ ។

**តទុដ្ឋាយ** វ. [ ត+ឧដ្ឋាយ, ចុះទ_អា. ] តាំងឡើងហើយអំពី... នោះ ។

**តទុបិយ** គុ. [ ត+ឧបិយ ] ដ៏សមគួរដល់...នោះ, ដ៏សមគួរដល់ជាយេនោះ ។

**តនុក** គុ. [ តនុ+ក.ស. ] ស្រាល, ស្តើង, ស្រាលស្តើង, តូច ។

**តនុត្ត** នបុំ. [ តនុ+ត្ត ] ភាវៈនៃ...ដ៏ស្រាល,...; វិ. **តនុស្ស ភាវោ> តនុត្តំ** ។



**តនុភាវ** បុំ. [ តនុ+ភាវ ] ភាវៈនៃ...នោះជាធម្មជាតិដ៏ស្រាល, ភាវៈនៃពុទ្ធនោះជាធម្មជាតិស្រាលស្តើង, ភាវៈជាចិត្តស្រាល ។

**តនុភូតសោក** គុ. [ តនុភូត+សោក ] អ្នកមានសេចក្តីសោកដ៏ស្រាល, អ្នកមានសេចក្តីសោកដ៏ស្រាលកើតហើយ ។ ភូត នេះប្រែក៏បាន មេក៏បាន ។

**តនុសរីរ** គុ. [ តនុ+សរីរ ] អ្នកមានសរីរៈដ៏ស្រាល; វិ. **តនុ សរីរំ អស្សាតិ> តនុសរីរោ** ។ **តនុ**<តនុ+ឧ = គុ. ស្រាល, ស្តើង, តូច, ល្អិត; ឥ. ខ្លួន, សរីរៈ, កាយ, រាងកាយ ។

**តន្ត** នបុំ. [ តនុ+ត ] វត្ថុដែលគេលាត, _លា, _សន្ទឹង, (តម្បាញ); វិ. **តនិយតិ វិត្ថារិយតីតិ> តន្តំ** ។ _ **វាយ** បុំ. ជនអ្នកត្បាញនូវតម្បាញ (ជាងតម្បាញ); វិ. **តន្តំ វាយតីតិ> តន្តវាយោ** ។ _ **សាលា** ឥ. រោងនៃតម្បាញ ។

**តន្តិ** ឥ. [ តនុ+តិ ] ធម្មជាតិដែលគេហា, _ព្រដាង, _សន្ទឹង (ខ្សែ); វិ. **តនិយតិ វិត្ថារិយតីតិ> តន្តិ** ។ ឥ. ជាបែបយ៉ាង, ជាបែបផែន ។

**តបចរណ** នបុំ. [ តប+ចរ+យុ ] កិ.ប្រព្រឹត្តិនូវតបៈ; វិ. **ចរិយ.តេតិ> ចរណំ; តបស្ស ចរណំ> តបចរណំ** ។

**តបតិ** កិ. [ តប+អ+តិ_វ. ] ក្តៅ, ក្តៅក្រហាយ, រុងរឿង ។

**តបន្ត** គុ. [ តប+អ+អន្ត ] កំពុងក្តៅ, កំពុងកំដៅ, កំពុងពោលកំដៅ, (កំពុងរំអែរ) ។

**តប** ពុំ. [ តប+អ ] គុណធម៌ជាទីញាំងកិលេសឱ្យក្ដៅ ឬជាគ្រឿងញាំងកិលេសឱ្យក្ដៅ (តបៈ); វិ. **កិលេសេ តាបេតិ ឯត្ថ ចា ឯកេនាតិ> តបោ** ។ **-បរិក្ខារ** ពុំ. បរិក្ខារសម្រាប់ប្រព្រឹត្តនូវតបៈ, បរិក្ខារនៃតបៈ ។ **-បរិហានិ** នពុំ. សេចក្ដីសាបសូន្យនៃតបៈ ។

**តបសី** គុ. [ តប+សី ] អ្នកមានតបៈ; វិ. **តបោ យស្ស អត្ថីតិ> តបសី** ។

**តបោវន** នពុំ. [ តប+វន ] ព្រៃគឺតបៈ, ព្រៃជាទីធ្វើនូវព្យាយាមជាគ្រឿងញាំងកិលេសឱ្យក្ដៅ ។ បកស្រៈ អ របស់ប ជា ឱ ។

**តប្បច្ចយ** ពុំ. [ ត+បច្ចយ ] បច្ច័យនៃ... នោះ ។

**តប្បន** នពុំ. [ តប+យ+អន ] ការក្ដៅក្រហាយ, សេចក្ដីក្ដៅក្រហាយ, ជាទីក្ដៅក្រហាយ, (សេចក្ដីឆ្អែត) ។ **-ដ្ឋាន** នពុំ. ទីជាទីក្ដៅក្រហាយ, ទីគឺសេចក្ដីក្ដៅក្រហាយ ។

**តប្បន្ត** គុ. [ តប+យ+អន្ត ] កាលក្ដៅក្រហាយ, កំពុងក្ដៅ ។

**តប្បមាន** គុ. [ តប+យ+មាន ] កំពុងពោល, កំពុងកំដៅ, (កំពុងឆ្អែត) ។

**តប្បតិ** គិ. [ តប+យ+តិ_វ. ] ក្ដៅ, ក្ដៅក្រហាយ ។

**តព្វិបរីត** គុ. [ ត+វិបរីត ] ដែលវិបរីតចាក...នោះ, ដែលផ្ទុយចាក...នោះ (**វិបរីត**<វិ+បរិ+ឥ+ត = វិបរីត, ផ្ទុយ, ខុស, ទំនាស់ ) ។



**តមវិនោទន** គុ. [ តម+វិ+នុទ+យុ ] អ្នកបន្ទោបង់នូវងងឹត ឬអ្នកបន្ទោបង់នូវងងឹតដោយប្រក្រតី; វិ. **តមំ វិនោទេតិ សីលេនាតិ> តមវិនោទនោ** ។

**តមសា** [ តម+នា.វិ., យកនា.វិ.>អា, ចុះស.អា. ] គឺងងឹត ។

**តមោភូត** គុ. [ តម+ភូត ] មានងងឹតកើតហើយ, ជាលោកងងឹត ។

**តម្ព** គុ. ក្រហម, មានពណ៌ក្រហម; លោហៈមានពណ៌ក្រហម ។ **-ទាឋិកចោរឃាតក** គុ. បុរសអ្នកសម្លាប់នូវចោរឈ្មោះតម្ពទាឋិក, អ្នកសម្លាប់នូវចោរមានចង្កូមដ៏ក្រហម ។ **-ភាជនប្បូរ** គុ. ដ៏ពេញក្នុងភាជន៍ជាវិការៈនៃលោហៈមានពណ៌ក្រហម, ដ៏ពេញក្នុងភាជន៍មានពណ៌ក្រហម, ជាវិការៈនៃទង់ដែង ។ **-មត្តិកា** ឥ. ដីមានពណ៌ក្រហម, ដីល្អិតមានពណ៌ក្រហម ។

**តយា** ពុ.ស. [ តុម្ហ+នា.វិ.>តយា ] គឺអ្នក, គឺលោក,.. ។

**តយោជនវត្ថុ** នពុំ. [ តយោជន+វត្ថុ ] រឿងនៃជនបីនាក់ ។

**តរមានរូប** គុ. [ តរមាន+រូប ] មានរូបរហ័សរហួន, មានសភាពរហ័សរហួន ។

**តរុណ** គុ. [ តរ+ឧណ ] កម្លោះ, ក្រមុំ, ជំទង់, ក្មេង, ខ្ចី (វិ. **កាលភាវំ តរតីតិ> តរុណោ, -ណា, -ណំ**) ។ **-កាល** ពុំ. កាលនៃ...នៅក្មេង,... ។ **-តាលក្ខន្ធប្បមាណ** គុ. មានដើមនៃត្នោតជំទង់ជាប្រមាណ, ប៉ុនដើមនៃត្នោតជំទង់ ។ **-ទារកកាល** ពុំ. កាលនៃទារកនៅក្មេង ។ **-បុត្ត** គុ. មានកូនខ្ចី ។

- **ភាវ** បុំ. ភាពនៃខ្លួនជាស្រីក្រមុំ, ..នៅក្មេង ។ - **មកុល** នបុំ. ក្រពុំខ្ចី, នោបខ្ចី; ខ្ចីនឹងក្រពុំ ។ - **វច្ឆ** បុំ. មានកូនខ្ចី, មានកូនគោខ្ចី ។ - **វិបស្សន** គុ. មានវិបស្សនានៅខ្ចី ។ - **សក្កភាវ** បុំ. ភាវៈនៃខ្លួនជាព្រះឥន្ទក្មេង, ..កម្លោះ ។ - **សក្ក** បុំ. ព្រះឥន្ទក្មេង, ..កម្លោះ ។ - **សីហ** បុំ. សីហៈក្មេង ។ - **ឥត្ថី** ឥ. ស្ត្រីក្មេង, ស្ត្រីក្រមុំ, ស្ត្រីជំទង់ ។

**តលមត្ត** គុ. [ តល+មត្ត ] ត្រឹមតែផ្ទៃ,ប៉ុនផ្ទៃ, មានផ្ទៃជាប្រមាណ ។

**តលសត្តិក** [ តល+សត្តិ+ក ] លើកពែងគឺផ្ទៃដៃ ។ - **សិក្ខាបទ** នបុំ. តលសត្តិកសិក្ខាបទ, សិក្ខាបទគឺបណ្ឌិតកំណត់ដោយលើកពែងគឺផ្ទៃដៃ ។

**តវ** បុ.ស. [ តុម្ហ+ស.វិ.>តវ ] នៃអ្នក, ដល់អ្នក,... ។

**តសន្តិ** កិ. [ តស+អ+អន្តិ.វ. ] តក់ស្លុត, រន្ធត់ ។

**តសរ** បុំ. [ តស+អរ ] ខ្នារ ។ - **បត្តិ** ឥ. កញ្ជ្រែងនៃខ្នារ, កញ្ជ្រែងដាក់នូវខ្នារ ។

**តសិត** គុ. [ តស+ឥ.អា.+ត ] គឺតណ្ហាឱ្យតក់ស្លុតហើយ, គឺ...ឱ្យតក់ស្លុតហើយ ។

**តស** បុំ. [ តស+អ ] សេចក្ដីតក់ស្លុត, អ្នកតក់ស្លុត ។

**តស្មា** វិ.ស.និ. [ ត+ស្មា.វិ. ] ព្រោះហេតុនោះ, ហេតុដូចនោះ ។

**តស្មឹ** វិ.ស.និ [ ត+ស្មឹ.វិ. ] នោះ, ក្នុង...នោះ ។



**តំខណំ** កា.ស. [ តំ+ខណ+ស្មឹ.វិ, ផ្លាស់ស្មឹ.វិ>អំ ] ក្នុងខណៈនោះ ។ - **ទិដ្ឋចោរ** បុំ. ចោរគឺខ្លួនឃើញហើយក្នុងខណៈនោះ ។ - **និព្វត្ត** គុ. ដែលកើតហើយក្នុងខណៈនោះ ។

**តំខណានុរូប** គុ. [ តំខណ+អនុរូប ] ដ៏សមគួរដល់ខណៈនោះ ។

**តំតំការណា** នបុំ. [ តំតំ+ការណ ] នូវហេតុនោះនោះ ។

**តំតំមគ្គវជ្ឈ** គុ. [ តំតំមគ្គ+វជ្ឈ ] គឺមគ្គនោះៗសម្លាប់ហើយ, គឺព្រះអរិយៈសម្លាប់ហើយដោយមគ្គនោះ ៗ

**តំទិដ្ឋមត្ត** គុ. [ តំទិដ្ឋ+មត្ត ] គ្រាន់តែគឺ...ឃើញហើយនូវព្រះឥន្ទនោះ, ..នូវ... នោះ ។

**តំទិវសំ** កា.ស. [ តំទិវស+ស្មឹ.វិ. ] ក្នុងថ្ងៃនោះ ។

**តំមុហុត្តទិដ្ឋក** គុ. [ តំមុហុត្ត+ទិដ្ឋក ] អ្នក...ឃើញហើយអស់កាលមួយរំពេចនោះ, ដែល...ឃើញហើយក្នុងមួយរំពេចនោះ ។

**តំវត្ថុក** គុ. [ តំ+វត្ថុ+ក ] មាន...នោះជាវត្ថុ ។

**តុំ** បុ.ស. [ តុម្ហ+សិ.វិ.>តុំ ] រឺអ្នក, រឺឯង,... ។

**តាណោ** នបុំ. [ តា+យុ ] សេចក្ដីទីពឹង, ទីពុំនាក់, ទីពឹងផ្អែក, ជាទីជ្រកកោន ។ - **តា** ឥ. សេចក្ដីទីពឹង, ភាវៈនៃសេចក្ដីទីពឹង,... ។ - **អត្ថ** បុំ. ប្រយោជន៍ដល់សេចក្ដីទីពឹង,... ។ - **ភាវ** បុំ. ភាវៈនៃ...ជាទីពឹង, ភាវៈនៃធម្មជាតិជាទីពឹងផ្អែក,... ។

**តាត** អា.ពិ. ជាពាក្យសម្រាប់ហៅចំពោះតែបុរសថា បពិត្របិតា, ..ឪ,

-ឪពុក; នៃអ្នក, -កូន,... ។

**តាទិភាវសណ្ឋិត** គុ. [ តាទិភាវ+សណ្ឋិត ] អ្នកតាំងនៅព្រមហើយដោយភាពជាតាទិបុគ្គល, អ្នកតាំងនៅព្រមហើយដោយភាពនៃខ្លួនជាអ្នកមានតាទិគុណ,... ។

**តាទិស** គុ. [ ត+ទិស+ក្វិ ] ដូចនោះ, ប្រាកដដូចនោះ; វិ. **សោ ឥវ ទិស្សតីតិ> តាទិសោ** ។

**តាទី** គុ. [ ត+ទិស+ក្វិ ] អ្នកនឹងធឹង, អ្នកជាតាទិបុគ្គល, អ្នកមានតាទិគុណ, អ្នកប្រាកដដូចនោះ (អ្នកមិនញាប់ញ័រដោយលោកធម៌) ។

**តាបនា** ឥ.ន. ឈ្មោះតាបនា ។

**តាបស** បុំ. [ តប+ណ ] អ្នកមានតបៈ, បព្វជិតអ្នកមានធម៌ជាគ្រឿងញុំាងកិលេសឱ្យក្តៅ (តាបស); វិ. **តបោ អស្ស អត្ថីតិ> តាបសោ** ។ - **បព្វជ្ជ** ឥ.វិ. បួសនៃបុគ្គលជាតាបស, បួសដោយភាវៈនៃខ្លួនជាតាបស (បួសជាតាបស) ។

**តាបិត** គុ. [ តប+ណេ+ត ] គឺ...ឱ្យក្តៅហើយ ។

**តាបេតិ** កិ. [ តប+ណេ+តិ.វ. ] ញុំាង...ឱ្យក្តៅ, កំដៅ ។

**តាបេត្វា** អ. [ តប+ណេ+ត្វា ] ញុំាង...ឱ្យហើយ, កំដៅហើយ ។

**តាបេន្ត** គុ. [ តប+ណេ+អន្ត ] កាលញុំាង....ឱ្យក្តៅ, កាលកំដៅ ។

**តាម្ព** គុ. ក្រហម, មានពណ៌ក្រហម ។ - **បណ្ណិទីប** បុំ. កោះ ឬទ្វីបឈ្មោះតាម្ពបណ្ណិ (ទ្វីបជាទីនៅនៃជនអ្នកមានបាតដៃក្រហម) ។



- **វម្មិកសទិស** គុ. ប្រាកដស្មើដោយដំបូកមានពណ៌ក្រហម ។

**តាយស្សុ** កិ. [ តា+ណាយ+ស្សុ.ប. ] ចូររក្សា, ចូរគ្រប់គ្រង, ចូរពិញ្ញឹប (តាមទំលាប់ថាចូរចម្លង) ។

**តារកា** ឥ. [ តារ+ក.ស.+អា.ឥ. ] ផ្កាយ; **តារា ឯវ> តារកា** ។ - **សញ្ញា** ឥ. សេចក្តីសំគាល់ដោយផ្កាយ ។ - **គណ** បុំ. ពួកនៃផ្កាយ ។

**តារយន្ត** គុ. [ តរ+ណយ+អន្ត ] កាលញុំាង...ឱ្យឆ្លង, កាលចម្លង ។

**តារេន្តិ** កិ. [ តរ+ណេ+អន្តិ.វ. ] ញុំាង...ឱ្យឆ្លង, ចូរចម្លង ។

**តារេហិ** កិ. [ តរ+ណេ+ហិ.ប. ] ចូរញុំាង...ឱ្យឆ្លង, ចូរចម្លង ។

**តាលក្ខន្ធប្បមាណ** គុ. [ តាលក្ខន្ធ+បមាណ ] មានដើមនៃត្នោតជាប្រមាណ, ប៉ុនដើមនៃត្នោត ។

**តាលច្ឆិទ្ទ** នបុំ. [ តាល+ឆិទ្ទ ] ប្រហោងនៃកូនសោ (ខ្លះថាប្រហោងនៃស្លឹកត្នោត) ។ ប្រើជា **តាឡច្ឆិទ្ទ** ក៏មាន ។

**តាលដ្ឋិក** នបុំ. [ តាល+អដ្ឋិក ] គ្រាប់នៃត្នោត ។

**តាលដ្ឋិខន្ឌ** បុំ. [ តាល+អដ្ឋិ+ខណ្ឌ ] កំណាត់នៃគ្រាប់ត្នោត, បំណែកនៃគ្រាប់ត្នោត ។

**តាលបណ្ណ** នបុំ. [ តាល+បណ្ណ ] ស្លឹកនៃត្នោត ។

**តាលបត្តវេឋក** គុ. [ តាលបត្ត+វេឋ+ណ្វុ ] អ្នកក្រុំ (វេច, ខ្ចប់, មូរ) នូវស្លឹកនៃត្នោត ។

**តាលប្បមាណ** គុ. [ តាល+បមាណ ] មានដើមត្នោតជាប្រមាណ ។

**តាលវណ្ដ** នពុំ. [ តាល+វណ្ដ ] ផ្ចិត, ផ្ចិតស្លឹកត្នោត (ផ្ចិតជាវិការៈនៃស្លឹកត្នោត) ។

**តាលវារ** បុំ. [ តាល+វារ ] វារៈនៃកូនសោ, វេនជាទីទុកនូវកូនសោ ។

**តាល, តាឡ** គុ. ត្នោត, កូនសោ, រនាំង ។

**តាវ** និ. ដរាបនោះ, ប៉ុណ្ណោះ, មុន, សិន, ក្នុងខណៈនោះ, ដោយពិត,... ។

**តាវកាលិកត្ថ** បុំ. [ តាវកាលិក+អត្ថ ] សេចក្ដីថាកាយនោះជារបស់ប្រព្រឹត្តទៅក្នុងកាលត្រឹមនោះ, អត្ថថាប្រព្រឹត្តទៅតាមកាលកំណត់ (សេចក្ដីថាកាយនោះដូចជារបស់ខ្ចីគេ) ។

**តាវតក** គុ. [ តាវត+ក ] មានប្រមាណប៉ុណ្ណោះ, មានប្រមាណត្រឹមនោះ ។

**តាវតា** និ. ដោយហេតុមានប្រមាណប៉ុណ្ណោះ, -ត្រឹមនោះ, ដោយកាលមានប្រមាណប៉ុណ្ណោះ, -ត្រឹមនោះ ។

**តាវត្តឹស** គុ. [ តាវត្តឹស+ណ ] មានឋានឈ្មោះតាវត្តិង្សៈជាទីនៅអាស្រ័យ (ឋានឈ្មោះតាវត្តិង្សៈ, -ទេវលោកឈ្មោះតាវត្តិង្សៈ); វិ. **តីហិ អធិកា តឹស> តេត្តឹស; តេត្តឹស ឯវ> តាវត្តឹសំ; តាវត្តឹសំ និវាសោ ឯតេសន្តិ> តាវត្តឹសា (ទេវា)** ។ . **ទេវនគរ** នពុំ. នគរនៃទេវតាឈ្មោះតាវត្តិង្ស ។ . **ទេវលោក** បុំ. ទេវលោកឈ្មោះតាវត្តិង្ស, លោកជាទីនៅនៃ



ទេវតាជាន់តាវត្តិង្ស ។ . **ភវន** នពុំ. ភពជាទីកើតនៃទេវតាឈ្មោះតាវត្តិង្ស ។

**តាវមហន្ត** គុ. [ តាវ+មហន្ត ] ធំប៉ុននោះ, ធំប៉ុណ្ណោះ, ធំត្រឹមនោះ, ធំរាំប៉ុនោះ ។

**តាស** បុំ. [ តស+ណ ] សេចក្ដីតក់ស្លុត ឬអ្នកតក់ស្លុត; វិ. **តសនំ> តាសោ; តសតីតិ វា> តាសោ** ។ . **ករណ** នពុំ. កិ. ធ្វើនូវសេចក្ដីតក់ស្លុត ។

**តាសេត្វា** អ. [ តស+ណេ+ត្វា ] ឱ្យតក់ស្លុតហើយ ។

**តាឡិត** គុ. [ តឡ+ឥ_អា.+ត ] គឺបុគ្គលវាយហើយ, -ដេញហើយ, -ជិះហើយ, -គោះហើយ, -ប្រហារហើយ ។

**តាឡិយមាន** គុ. [ តឡ+ឥ_អា.+យ+មាន ] គឺបុគ្គលកាលវាយ,... ។

**តាឡេន្ត** គុ. [ តឡ+ណេ+អន្ត ] កាលវាយ,... ។

**តិក** គុ. [ តិ+ក ] មានប្រមាណ៣, ពួក៣; វិ. **តីណិ បរិមាណានិ អស្សាតិ> តិកំ** (បកតិសំខ្យាតាំងពីទ្វិ, តិ, ជាដើមឡើងទៅបើបានចុះកបច្ច័យនៅខាងចុងទៅជា " ទ្វិក ឬ ទុក, តិក, ចតុក្ក " ដូច្នេះត្រូវដឹងថាជាពួកបរិមាណតទ្ធិត មានន័យដូចនេះដែរ) ។ . **ចតុក្កជ្ឈាន** នពុំ. ឈានមានប្រមាណ៣ និងឈានមានប្រមាណ៤, ឈានពួកបីនិងឈានពួកបួន ។

**តិកិច្ឆាបេតិ** កិ. [ កិ_កិត+ឆ+ណាបេ+តិ_វ ] ញ៉ាំង...ឱ្យរក្សា, ឱ្យថែទាំ ។

**ពិកិច្ឆា** ឥ. [ កិ.កិត+ឆ+ស+អា.ឥ. ] កិ.រក្សា, កិ.ថែទាំ; វិ. **តិកិច្ឆនំ តិកិច្ឆា** ។

**ពិកិច្ឆិត** គុ. [ កិ.កិត+ឆ+ឥ.រា.+ត ] ដ៏រក្សាហើយ, ថែទាំហើយ ។

**ពិកិច្ឆិតា** ស. [ កិ.កិត+ឆ+ឥ.រា.+តា ] រក្សាហើយ, ថែទាំហើយ, ព្យាបាលហើយ ។

**ពិក្ខត្តុំ** និ. [ តិ+សក៌>តិក្ខត្តុំ ] វារៈនៃ...៣, (វារៈ៣ដង, ៣លើក, ៣គ្រា) ។

**ពិខិណា** គុ. [ តិជ, ជ>ខ+ឥន, ឥន>ឥណ ] មុត, ដ៏មុត, ដ៏ក្លា, ដ៏ខ្លាំងក្លា, ក្លាហាន, ពូកែ, ដ៏ឆើត, ជំនាញ, មោះមុត, អង់អាច ។ . **ធារ** គុ. មានមុខដ៏មុត ។ . **ផល** គុ. មានផលដ៏ក្លា ។ . **ភេសជ្ជ** នពុំ. ថ្នាំដ៏ក្លា, ថ្នាំដ៏ក្លាហាន ។ . **មទ** គុ. មានសេចក្តីស្រវឹងដ៏ក្លាហាន,... ។

**ពិគាវុតិក** គុ. [ តិគាវុត+ឥក ] មានគាវុត៣ជាប្រមាណ; ប្រកបដោយគាវុត៣; វិ. **តីណិ គាវុតានិ> តិគាវុតំ; តិគាវុតេន និយុត្តោ> តិគាវុតិកោ** ។

**ពិគាវុតប្បមាណ** គុ. [ តិគាវុត+បមាណ ] មានគាវុតបីជាប្រមាណ (១គាវុតត្រូវជា១០០សិន) ។

**ពិចីវរ** នពុំ. [ តិ+ចិវរ ] ត្រៃចីវរ, ចីវរបី; វិ. **តីណិ ចីវរានិ> តិចីវរំ** ។

**ពិដ្ឋ** កិ. [ ឋា>តិដ្ឋ+អ+ហិ.ប., ពុទ្ធរបៀបហិ.ក. ] ចូរតាំងនៅ, ចូរឋិតនៅ, ចូរឈប់ ។

**ពិដ្ឋតិ** កិ. [ ឋា+អ+តិ.វ. ] ឋិតនៅ, តាំងនៅ ។

**ពិដ្ឋតុ** កិ. [ ឋា+អ+តុ.ក. ] ចូរឋិតនៅ, ចូរតាំងនៅ, ចូរឈប់ ។

**ពិដ្ឋេ** កិ. [ ឋា+អ+ឯ.ក. ] ចូរឋិតនៅ,... ។

**ពិដ្ឋដ្ឋាន** នពុំ. [ តិដ្ឋ+ឋាន ] ទីជាទីតាំងនៅ,... ។

**ពិដ្ឋេយ្យាសិ** កិ. [ ឋា+អ+ឯយ្យាសិ.ស. ] គប្បីតាំងនៅ,.... ។

**ពិណ** នពុំ. [ តិណ+អ ] តិណជាតតិសត្វមានគោជាដើមតែងស៊ី (ស្មៅ); វិ. **តិណិយតេ គោណាទីហិ អទិយតេ ខាទិយតេតិ> តិណំ** ។ . **ករឡ** នពុំ. រង្វេលជាវិការៈនៃស្មៅ, រង្វេលដ៏បុគ្គលធ្វើដោយស្មៅ ។ . **កលាប** ពុំ. បាច់នៃស្មៅ, សំណុំនៃស្មៅ ។ . **កាជ** ពុំ. ព្រែកនៃស្មៅ ។ . **គហន** នពុំ. ស្បាតនៃស្មៅ, ស៊ុមព្រុមនៃស្មៅ ។ . **អគ្គ** គុ. ចុងនៃស្មៅ ។ . **អត្ថ** ពុំ. ប្រយោជន៍ដល់ស្មៅ ។ . **ទោស** គុ. មានស្មៅជាទោស, មានស្មៅជាគ្រឿងប្រទូស្ត ។ . **បរិភោគ** ពុំ. ស្មៅជាដែល, ស្មៅជារបស់ដែល ។ . **បាទុកា** គុ. ទ្រនាប់ជើងជាវិការៈនៃស្មៅ ។ . **រាសិ** ពុំ. គំនរនៃស្មៅ ។ . **វល្លិបលិវេឋិត** គុ. ដ៏ស្មៅនិងវល្លិព័ទ្ធព័ទ្ធហើយ; (ឆ្លុះជាតិវល្លិនៃស្មៅរុំព័ទ្ធហើយ) ។ . **សាកិយ** ពុំ. ឈ្មោះតិណសាកិយៈ (សាកិយៈស្មៅ) ។ . **ហារក** គុ. អ្នកនាំមកនូវស្មៅ (អ្នករែកនូវស្មៅ); វិ. **តិណានិ ហរតីតិ> តិណហារកោ** ។

**តិណុក្កា** ឥ. [ តិណ+ឧក្កា ] គប់ភ្លើងជាវិការៈនៃស្មៅ; គប់ភ្លើងគឺបុគ្គលធ្វើដោយស្មៅ; វិ. **តិណេហិ កតា ឧក្កា> តិណុក្កា** ។

**តិណ្ណ** គុ. [ តរ+ត, ត>ណ្ណ, លុបរ ] ឆ្លងហើយ, គឺ...ឆ្លងហើយ ។

**តិណ្ហ** គុ. [ តិជ+ហ, ជ>ណ ] មុត,... (ជាវេវចនៈនៃតិខិណ) ។

**តិតាលមត្ត** គុ. [ តិតាល+មត្ត ] មានដើមត្នោតបីដើមជាប្រមាណ (មានជួរនៃដើមត្នោតបីជាប្រមាណ, បីជួរដើមត្នោត) ។

**តិតិក្ខតិ** កិ. [ តិ_តិជ+ខ+តិ_វ. ] អត់ទ្រាំ, អត់ធន់ ។

**តិតិក្ខា** ឥ. [ តិ_តិជ+ខ+អា_ឥ. ] សេចក្ដីអត់ទ្រាំ, ការអត់ធន់; វិ. **តិតិក្ខនំ ខមនំ> តិតិក្ខា** ។ **. សង្ខាត** គុ. ពោលគឺសេចក្ដីអត់ទ្រាំ, គឺបណ្ឌិតពោលថាសេចក្ដីអត់ធន់ ។

**តិតិក្ខិស្សំ** កិ. [ តិ_តិជ+ខ+ឥ_អា.+ស្សំ_ក. ] នឹងអត់ទ្រាំ, នឹងអត់ធន់ ។

**តិត្តិ** ឥ. [ តិប+តិ ] សេចក្ដីឆ្អែត, ការឆ្អែត, កិ.ឆ្អែតស្កប់ស្កល់ ។ ក្ន. តិជ+តិ = ល្វីង, រសល្វីង។

**តិត្តិក** គុ. [ តិត្តិ+ណិក ] បានរសល្វីង ។

**តិត្ថមគ្គ** បុំ. [ តិត្ថ+មគ្គ ] ផ្លូវជាទីទៅកាន់កំពង់ទឹក, ផ្លូវត្រង់កំពង់ទឹក ។

**តិត្ថាមុខី** គុ. [ តិត្ថ+អភិមុខី ] អ្នកមានមុខឆ្ពោះទៅកាន់កំពង់ទឹក ។

**តិត្ថាយតន** នបុំ. [ តិត្ថ+អាយតន ] កំពង់ទឹក, លទ្ធិដូចជាកំពង់ទឹក ។



**តិត្ថិយ** បុំ. [ តិត្ថ+ណិយ ] តិរ្ថិយ (និគ្រន្ថអ្នកមានលទ្ធិដូចជាកំពង់ជាទីឆ្លង) ។ **. វត្ត** នបុំ. រឿងនៃតិរ្ថិយ ។ **. សាវក** បុំ. សាវ័កនៃតិរ្ថិយ ។ **. អារាម** បុំ. អារាមនៃតិរ្ថិយ ។

**តិថិការណានក្ខត្តយោគ** បុំ. [ តិថិ+ការណ+នក្ខត្ត+យោគ ] កិ. ប្រកបដោយនក្ខត្តឫក្សមានតិថីជាហេតុ, កិ.ប្រកបនៃនក្ខត្តឫក្សគឺហេតុនៃតិថី ។

**តិទស** គុ. [ តិ+ទស ] ទេវតាអ្នកនៅក្នុងបុរីឈ្មោះតិទសៈ, ទេវតាអ្នកនៅក្នុងឋានត្រៃត្រឹង្ស (ទេវតាអ្នកមានបរិមាណបី; វិ. **តិស្សោ ទសា បរិមាណា យេសន្តិ> តិទសា**; អភិ. សុ.) ។

**តិទិវង្គត** គុ. [ តិទិវ+គត ] អ្នកទៅហើយកាន់ត្រៃទិព, អ្នកទៅហើយកាន់ឋានសួគ៌ (អ្នកទៅហើយកាន់លោកជាទីលេងនៃទេវតាបីរូប) ។

**តិន្ត** គុ. [ តិម+ត ] ទទឹកហើយ, សើមហើយ ។ **. ចីវរក** គុ. អ្នកមានចីវរទទឹកហើយ; វិ. **តិន្តំ ចីវរំ យេសំ តេ> តិន្តចីវរកា** ។ **. មុខ** គុ. អ្នកមានមុខទទឹកហើយ ។

**តិបិដកធរ** គុ. [ តិបិដក+ធរ+អ ] អ្នកទ្រទ្រង់នូវបិដកបី, ...នូវព្រះត្រៃបិដក (អ្នកចេះចាំនូវព្រះត្រៃបិដក); វិ. **តិបិដកំ ធារេតីតិ> តិបិដកធរោ** ។

**តិបុសមត្ត** គុ. [ តិបុស+មត្ត ] មានផ្លែឪឡឹកជាប្រមាណ, ប៉ុនផ្លែឪឡឹក ។

**តិបុ** នបុំ. សំណ, សំណភក់ ។ **. បរិខា** ឥ. គូឬស្នាមភ្លោះដីពេញដោយ

សំណាកក់, គូនៃសំណាកក់ ។

**តិព្វ** គុ. ក្លា, ដ៏ខ្លាំងក្លា ។ . **រាគ** គុ. អ្នកមានរាគៈដ៏ក្លា, អ្នកមានរាគៈដ៏ក្លៀវក្លា ។

**តិមិរបុញ្ញ** កុំ. [ តិមិរ+បុញ្ញ ] ដុំនៃអ័ព្ទ, ដុំនៃពពក, ដុំនៃងងឹត, គំនរនៃ... ។

**តិម្ពរូសក** កុំ. [ តិម្ពរូ+ឱស+ក.ស.+វ.រក. ] ផ្លែទន្លាប់ ។ . **អាទិទាន-មគ្គ** គុ. កុសលត្រឹមតែកិ.ឱ្យនូវវត្ថុមានផ្លែនៃទន្លាប់ជាដើម ។

**តិយាមមត្ត** គុ. [ តិយាម+មត្ត ] មានយាមបីជាប្រមាណ, ត្រឹមតែយាមបី ។

**តិយាមរត្តិ** ឥ. [ តិយាម+រត្តិ ] រាត្រីមានយាមបី; វិ. **តយោ យាមា ឯត្ថាតិ> តិយាមា; តិយាមា រត្តិ> តិយាមរត្តិ** ។

**តិយោជន** នកុំ. [ តិ+យោជន ] យោជន៍បី; វិ. **តិណ្ណំ យោជនានំ> តិយោជនំ** ។ . **ភូមិ** ឥ. ផែនដីមានយោជន៍បីជាប្រមាណ ។ . **មត្ថក** កុំ. ទីបំផុតនៃយោជន៍បី ។ . **សតាយាម** គុ. មានបណ្ដោយមានរយនៃយោជន៍បីជាប្រមាណ ។ . **សតិក** គុ. មានរយនៃយោជន៍បីជាប្រមាណ, ប្រកបដោយរយនៃយោជន៍បី ។ . **សតុព្វេធ** គុ. មានកិ.ខ្ពស់ឡើងអស់ចិមានរយនៃយោជន៍បីជាប្រមាណ, មានរយនៃយោជន៍បីជាចំណែកខ្ពស់ ។ . **សហស្សវិត្ថត** គុ. មានទទឹងមានពាន់នៃយោជន៍បីជាប្រមាណ, មានពាន់នៃយោជន៍បីជាចំណែកទទឹង ។



**តិរច្ឆាន** កុំ. [ តិរ+អញ្ច, អញ្ច>ច្ឆ+យុ ] សត្វទៅទទឹង, ឬសត្វទៅក្នុងវៀង (តិរច្ឆាន); វិ. **តិរិយំ អញ្ចតីតិ> តិរច្ឆានោ;** (អភិ.សុចិ) ។ (តិរ+ឆាន) សត្វទៅក្នុងខាងក្រោម (តិរច្ឆាន); វិ. **តិរោ អញ្ចោ គច្ឆន្តីតិ> តិរច្ឆានា;** (ឃ.អភិ.) ។ . **កថា** ឥ. វាចាជាគ្រឿងពោលនូវតិរច្ឆាន ឬពោលប្រាស្រ័យនូវតិរច្ឆាន ។ . **ហោនិបទ** នកុំ. ស្នាមជើងជាទីទៅកាន់កំណើតនៃតិរច្ឆាន ។ . **យោនិ** ឥ. កំណើតនៃតិរច្ឆាន ។

**តិរច្ឆានគត** គុ. [ តិរច្ឆាន+គត ] តិរច្ឆាន, សត្វតិរច្ឆាន; **តិរច្ឆានោ ឯវ> តិរច្ឆានគតោ** (គត-ស័ព្ទនេះមានកន្លែងខ្លះមិនមែនជា "សកត្ថ" ទេអាចប្រែថា "ទៅ, ដល់, កើត" តាមដំណើរសេចក្ដីបាន; ដូ. **តិរច្ឆានេសុ បដិសន្ធិគ្គហណវសេន គតោ ឧបន្នោតិ> តិរច្ឆានគតោ**) ។ . **ត្ត** នកុំ. ភាវៈនៃ...នោះជាសត្វតិរច្ឆាន, .ជាសត្វទៅហើយកាន់កំណើតនៃតិរច្ឆាន ។

**តិរណបរិញ្ញា** ឥ. [ តិរណ+បរិញ្ញា ] ធម្មជាតិគឺ...គប្បីកំណត់ដឹងដោយការពិចារណា (ឈ្មោះតិរណបរិញ្ញា) ។ ប្រើថា " តីរបរិញ្ញា" ក៏បាន ។

**តិរោ** ព. ទទឹង, ក្នុងទទឹង, ខាងក្រៅ ។

**តិរេត្វា** វ. [ តិរ+ណេ+ត្វា ] ពិចារណាហើយ, ត្រួតត្រាហើយ, ថ្លៃលកហើយ ។ ប្រើថា " តីរេត្វា" ក៏បាន ។

**តិរោកុឌ្ឌ** នកុំ. [ តិរោ+កុឌ្ឌ ] ខាងក្រៅនៃជញ្ជាំង; វិ. **កុឌ្ឌស្ស តិរោ**

> តិរោកុឌ្ឌំ ។ . អាទិ គុ. (សូត្រ) មានតិរោកុឌ្ឌសូត្រជាដើម ។ . អនុមោទនា ឥ. ធម្មកថាជាគ្រឿងរីករាយតាមដោយអំណាចនៃតិរោកុឌ្ឌសូត្រ ។

**តិលក** [ តិល+ក ] ប្រជ្រុយ (មោសមានល្ងជាប្រមាណ; ទោសប៉ុនគ្រាប់ល្ង) ។

**តិលកាហតគត្ត** គុ. [ តិលក+អាហត+គត្ត ] មានខ្លួនគឺប្រជ្រុយបៀតបៀនទូទៅហើយ, មានខ្លួនសៅហ្មងហើយដោយប្រជ្រុយ ។

**តិលក្ខណ** នពុំ. [ តិ+លក្ខណ ] ត្រៃល័ក្ខណ៍, លក្ខណៈ៣, ធម្មជាតជាគ្រឿងកំណត់៣យ៉ាង ។

**តិល** នពុំ. ល្ង ។ . តណ្ឌុលសប្បិផាណិតវត្ថុថាទនាទិបុណ្ណ គុ. ដ៏ពេញដោយវត្ថុមានល្ង និងអង្ករ និងទឹកដោះថ្លា និងទឹកអំពៅ និងវត្ថុជាគ្រឿងចិចចាំងគឺសំពត់ជាដើម ។ . តណ្ឌុលសប្បិ-ផាណិតាទិ គុ. (វត្ថុ) មានល្ង និងអង្ករ និងសប្បិ និងទឹកអំពៅជាដើម ។ . តេល នពុំ. ប្រេងនៃល្ង, ប្រេងដែលកើតអំពីល្ង, ប្រេងដែលបុគ្គលធ្វើហើយអំពីល្ង ។ . មត្ត គុ. មានល្ងជាប្រមាណ, ប៉ុនល្ង ។

**តិលសង្គុលិកា** ឥ. [ តិលសង្គុល+ណិក.ឥ. ] នំឬចំណីដែលលាយដោយល្ង (នំល្ង, នំម្រាបល្ង); វិ. តិលេហិ មិស្សា សង្គុលា> តិលសង្គុលា; តិលសង្គុលា ឯវ> តិលសង្គុលិកា ។ ប្រើជា" តិលសង្គុលិកា ក៏បាន ។



**តិវស្សិក** គុ. [ តិវស្ស+ណិក ] មានឆ្នាំបី, ប្រកបដោយឆ្នាំបី, ប្រព្រឹត្តទៅក្នុងកាលវស្សាបី

**តិវិធ** គុ. [ តិ+វិធ ] មានបការៈបី, មានបីយ៉ាង; វិ. តយោ វិធា ប. ការា យស្សាតិ> តិវិធំ ។ . សុចរិត នពុំ. សុចរិតមានបការៈបី, សុចរិតមានបីយ៉ាង, កម្មគឺបុគ្គលប្រព្រឹត្តល្អមានបីយ៉ាង ។

**តិសរណគត** គុ. [ តិសរណ+គត ] អ្នកដល់ហើយនូវត្រៃសរណៈ, អ្នកកាន់សរណៈបីដល់ហើយ ។

**តិស្ស** ន. ព. ភិក្ខុឈ្មោះតិស្សៈ ។ . ត្ថេរវត្ថុ នពុំ. រឿងនៃព្រះថេរៈឈ្មោះតិស្សៈ ។ . មហាវិហារ ពុំ. វិហារធំឈ្មោះតិស្សៈ ។ . ករីស គុ. ប្រាកដស្មើដោយភិក្ខុឈ្មោះតិស្សៈ ។

**តឹស** ស. សាមសិប ។ . ធុត្ត ពុំ. អ្នកលេង៣០នាក់ ។ . មត្ត គុ. មាន៣០ជាប្រមាណ, មានប្រមាណ៣០ ។ . យោជនកន្តារ ពុំ. ផ្លូវលំបាកមានយោជន៍៣០ជាប្រមាណ ។ . យោជនមត្ត នពុំ. ប៉ុប្រកបដោយយោជន៍៣០, មិមានយោជន៍៣០ជាប្រមាណ ។ . យោជនិក គុ. ប្រកបដោយយោជន៍៣០, មានយោជន៍៣០ជាប្រមាណ ។

**តីរ** នពុំ. ច្រាំង, ត្រើយ, ច្រាំង ។

**តីរេត្វា** អ. [ តីរ+ណេ+ត្វា ] ពិចារណាហើយ, ត្អាបស្ទង់ហើយ ។

**តុន្ន** គុ. [ តុទ+ន ] ចាក់ ។ . កុដ្ឋ ពុំ. ក្តមចេទ ។ . ខេត្តភូមិ ឥ. ផែនដីនៃស្រែទេ ។ . គព្ភប្បវេណ នពុំ. កិ.ព្យាំងល្វែងមមេឡា

ពេញ, កិ.បំពេញនូវល្វែងទទេ ។ - **គព្ភ** បុំ. ល្វែងទទេ, បន្ទប់ទទេ ។ - **គ្គហណភាវ** បុំ. ភាវៈគឺកិ.កាន់យកទទេ ។ - **ជិណ្ណ** គុ. ចាស់ទទេ ។ - **បច្ឆិ** ឥ. កញ្ច្រែងទទេ ។ - **បត្តហត្ថ** គុ. មានបាត្រទទេក្នុងដៃ ។ - **ចាដិ** ឥ. ភាជនៈទទេ ។ - **បោឋិល** អ.ន. ភិក្ខុឈ្មោះតុច្ឆបោឋិលៈ (ភិក្ខុអ្នកមានស្លឹករឹតទទេ) ។ - **ភាជន** នបុំ. ភាជនៈទទេ ។ - **ភាវ** បុំ. ភាវៈនៃ...ជារបស់ទទេ ។ - **រវិ** កិ.វិ. ស្រែកទទេ, រងាវទទេ ។ - **រូប** គុ. មានរូបទទេ, មានសភាពទទេ ។ - **វិហារ** បុំ. វិហារទទេ, វត្តទទេ ។ - **សកដ** នបុំ. រទេះទទេ ។ - **សភាវ** គុ. មានសភាពទទេ ។ - **ហត្ថ** គុ. មានដៃទទេ ។

**តុដ្ឋ** គុ. [ តុស+ត ] ត្រេកអរហើយ ។ - **ចិត្ត** គុ. អ្នកមានចិត្តត្រេកអរហើយ; វិ. **តុដ្ឋំ ចិត្តំ យស្ស សោ> តុដ្ឋចិត្តោ** ។ - **ភាវ** បុំ. ភាវៈនៃ...ជាអ្នកត្រេកអរហើយ ។ - **មនុស្ស** បុំ. មនុស្សអ្នកត្រេកអរហើយ ។ - **មានស** គុ. អ្នកមានចិត្តត្រេកអរហើយ, អ្នកមានឆន្ទៈមានក្នុងចិត្តត្រេកអរហើយ ។ - **បហដ្ឋ** គុ. ទាំងត្រេកអរហើយទាំងរីករាយហើយ, អ្នកត្រេកអរហើយរីករាយហើយ ។

**តុដ្ឋិ** ឥ. [ តុស+តិ, តិ>ដ្ឋិ, លុបស ] សេចក្ដីត្រេកអរ; វិ. **តុស្សនំ> តុដ្ឋិ** ។ - **ទាយ** បុំ. ចំណែកគឺបុគ្គលគប្បីឱ្យដោយសេចក្ដីត្រេកអរ, រង្វាន់គឺបុគ្គលគប្បីឱ្យដោយសេចក្ដីត្រេកអរ ។ - **ភាវ-មង្គុភាវវស** បុំ. អំណាចនៃភាវៈនៃសេចក្ដីត្រេកអរ និងភាវៈ



នៃសេចក្ដីអៀនខ្មាស់ ។

**តុណ្ឌ** នបុំ. [ តុទ+រ ] ចំពុះ, ចំពុះមាត់; មាត់, ព្រួញ ។

**តុណ្ឌិល** អ.ន. ជ្រូកឈ្មោះតុណ្ឌិលៈ ។

**តុណ្ឌិលោវាទ** បុំ. [ តុណ្ឌិល+ឱវាទ ] ឱវាទនៃជ្រូកឈ្មោះតុណ្ឌិលៈ ។

**តុណ្ហី** អ.និ. ស្ងៀម, អ្នកស្ងៀម, អ្នកមានសេចក្ដីស្ងៀម ។ - **ភាវមត្ត** គុ. ដោយអាការគ្រាន់តែភាវៈនៃ...ជាអ្នកស្ងៀម, ដោយហេតុត្រឹមតែ... ។ - **ភាវ** បុំ. ភាវៈនៃ...ជាអ្នកស្ងៀម ។ - **ភូត** គុ. ជាអ្នកស្ងៀម ។ - **មាសី** គុ. (<តុណ្ហី+អាស+ណី, ចុះម.អា.) អ្នកអង្គុយស្ងៀម; វិ. **តុណ្ហី អាសតីតិ> តុណ្ហីមាសី** ។

**តុន្ន** នបុំ. [ តុទ+ត ] បំណះ ។

**តុម្ហាកំ** បុ.ស. [ តុម្ហ+នំ.វិ. ] នៃអ្នកទាំងឡាយ,... ។

**តុម្ហាទិស** គុ. [ តុម្ហ+ទិស+ក្វិ ] ប្រាកដដូចជាអ្នក,... ។

**តុម្ហាទិសី** ឥ. [ តុម្ហ+ទិស+ក្វិ, ចុះឦ ] ប្រាកដដូចជានាង,... ។

**តុម្ហេ** បុ.ស. [ តុម្ហ+យោ.វិ. ] ឯអ្នកទាំងឡាយ, នូវ... ។

**តុរិតតុរិតំ** កិ.វិ. រួសរាន់, ឆាប់ៗ, ភ្លាមៗ, រហ័សៗ ។

**តុរិយ** នបុំ. តន្ត្រី ។ - **តាឡិតវាទិតនិគ្ឃោសសទ្ទ** បុំ. សំឡេងដ៏គឹកកងនៃតន្ត្រីគឺបុគ្គលប្រគំហើយ (តាឡិត .សព្ទនេះថា" វាយ, ដេញ, ដំ, ក្រួត, ទះ") ។

**តុលា** ឥ. [ តុល+អ+អា.ឥ. ] (ធម្មជាតិ) សម្រាប់ថ្លឹង (ធ្នឹម, ជញ្ជីង, ត្រាជូ); វិ. **តុលយតិ មិនាតិ ឯតាយាតិ> តុលា** ។ **- កូដាទិ** ត. (អំពើកោង) មានអំពើកោងដោយជញ្ជីងជាដើម ។ **- សង្ឃាដទ្វារកវាដវាតបានតោរណសិលទនិដ្ឋកា** ឥ. ធ្នឹម និងក្រប និងសន្ទះនៃទ្វារ និងបង្អួច និងបង្កង់ និងក្បឿង ។

**តុលិតធម្ម** ត. [ តុលិត+ធម្ម ] អ្នកមានធម៌ថ្លឹងហើយ ។

**តុវដំ** ក.វិ. ឆាប់, រួសរាន់, រហ័ស, ភ្លាម ។

**តុវំ** ឬ.ត. [ តុម្ហ+សិ.វិ ឬអំ.វិ. ] រីអ្នក, នូវអ្នក,... ។

**តុសតិ** ក. [ តុស+អ+តិ.វ. ] ត្រេកអរ ។

**តុសិត** ភ.ន. ភពឬទេវលោកឈ្មោះតុសិត ។ **- បុរ** នបុំ. បុរីឈ្មោះតុសិត ។ **- ភវន** នបុំ. ឋានជាទីកើតនៃទេវតាឈ្មោះតុសិត, ភពឈ្មោះតុសិត ។ **- វិមាន** នបុំ. វិមានក្នុងភពឈ្មោះតុសិត ។

**តុសិត្វា** អ. [ តុស+ឥ.អា.+ត្វា ] ត្រេកអរហើយ ។

**តុសិស្សតិ** ក. [ តុស+អ+ឥ.អា.+ស្សតិ.ភ. ] នឹងត្រេកអរ ។

**តុស្សតិ** ក. [ តុស+យ+តិ.វ. ] ត្រេកអរ ។

**តុស្សនភាវ** បុំ. [ តុស្សន+ភាវ ] ភាវៈនៃសេចក្តីត្រេកអរ, ភាវៈគឺសេចក្តីត្រេកអរ ។

**តុស្សិ** ក. [ តុស+យ+ឦ.អជ្ជ. ] ត្រេកអរហើយ ។



**តូលបិចុ** នបុំ. [ តូល+បិចុ ] ប៉ុយនៃសំឡី, ប៉ុយនៃគរ ។

**តេ** ឬ.ត. [ តុម្ហ+ស.វិ. ] នៃអ្នក, ដល់អ្នក ,... ។

**តេជន** នបុំ. [ តិជ+យុ ] ព្រួញ, កូនសរ ។

**តេជសា** បុំ. [ តេជ+នា.វិ., ផ្លាស់នា.វិ.>អា, ចុះស.អា. ] ដោយតេជៈ (តេជ-សព្ទនេះប្រែបានច្រើនយ៉ាងគឺ ព្រះអាទិត្យ, អានុភាព, អំណាច, ភ្លើង) ។

**តេជវន្តតរ** ត. [ តេជវន្តុ+តរ ] អ្នកមានតេជៈជាង (តេជវន្តុ< តេជ+វន្តុ ) ។

**តេជោកសិណ** នបុំ. [ តេជ+កសិណ ] តេជោកសិណ, កម្មដ្ឋានមានភ្លើងជាកសិណ ។ **- សមាបត្តិវស** បុំ. អំណាចនៃសមាបត្តិមានតេជោកសិណជាអារម្មណ៍ ។ **- អារម្មណ** ត. មានតេជោកសិណជាអារម្មណ៍ ។

**តេជោធាតុ** ឥ. [ តេជ+ធាតុ ] តេជោធាតុ, ឈានមានតេជោធាតុជាអារម្មណ៍ ។

**តេត្តឹស** ត.សំ. [ តិ+តឹស ] ៣០លើសដោយ៣ (៣៣); វិ. **តីហិ អធិកា តឹស> តេត្តឹស** ។ **- កុម្ភ** បុំ. ពាង៣៣ ។ **- ទេវបុត្ត** បុំ. ទេវបុត្រ៣៣រូប ។

**តេន** ក.វិ. ដោយហេតុនោះ, ព្រោះហេតុនោះ ។

**តេនហិ** និ. បើដូច្នោះ, ដូច្នោះ, ដូច្នោះមានតែ,... ។

**តេបិដក** នបុំ. [ តិបិដក+ណ ] ប្រជុំនៃបិដក៣, ពួកនៃបិដក៣ ឬអ្នករៀននូវបិដក៣, អ្នកទ្រទ្រង់នូវបិដក៣; វិ. **តិណ្ណំ បិដកានំ សមូហោ> តេបិដកំ; តិបិដកំ ឧគ្គណ្ហាតិ ធារេតីតិ វា> តេបិដកោ** ។ . **បរិយត្តិប្បភេទ** បុ. អ្នកបែកធ្លាយក្នុងបរិយត្តិគឺពួកនៃបិដក៣, ការបែកធ្លាយក្នុងបរិយត្តិគឺប្រជុំនៃបិដក៣ ។ . **ពុទ្ធវចនសង្ខាត** គុ. ពាក្យគឺពុទ្ធវចនៈគឺប្រជុំនៃបិដក៣, គឺបណ្ឌិតពោលថាពុទ្ធវចនៈគឺពួកនៃបិដក៣ ។ . **ភិក្ខុ** បុ. ភិក្ខុអ្នករៀន ឬអ្នកទ្រទ្រង់នូវបិដក ៣ ។

**តេភាតិកជដិល** បុ. [ តេភាតិក+ជដិល ] ជដិលជាបងប្អូន៣នាក់ ។

**តេភូមិក** គុ. [ តិភូមិ+ណិក ] ប្រព្រឹត្តទៅក្នុងភូមិ៣, ប្រកបក្នុងភូមិ៣ ។ វត្តិតទ្ធិត, និយុត្តតទ្ធិត ។ . **ធម្ម** បុ. ធម៌ប្រព្រឹត្តទៅក្នុងភូមិ៣ ។ . **វដ្ដសង្ខាត** គុ. ពាក្យគឺវដ្ដៈប្រព្រឹត្តទៅក្នុងភូមិ៣ ។ . **សុចរិតានុភាវ** បុ. អានុភាពនៃសុចរិតប្រព្រឹត្តទៅក្នុងភូមិ៣ ។

**តេមនកាល** បុ. [ តេមន+កាល ] កាលជាទីទទឹក, កាលជាទីសើម ។

**តេមាស** បុ. [ តិ+មាស+ណ ] ប្រជុំនៃខែ៣ (ត្រីមាស); វិ. **តិណ្ណំ មាសានំ សមូហោ> តេមាសោ** ។ . **ចាតុម្មាសព្ភន្តរ** បុ. កាលជាទីប្រព្រឹត្តកន្លងទៅនៃប្រជុំនៃខែ៣ និងប្រជុំនៃខែ៤ ។ . **អព្ភន្តរ** នបុំ. ខាងក្នុងនៃប្រជុំនៃខែ៣ ។

**តេមិ** កិ. [ តិម+អ+មិ.អដ្ឋ. ] ទទឹកហើយ, សើមហើយ ។



**តេមេតុ** កិ. [ តិម+អ+តុ.អដ្ឋ. ] ទទឹកហើយ, សើមហើយ ។

**តេមេត្វា** អ. [ តិម+ណេ+ត្វា ] ញ៉ាំង...ឱ្យទទឹកហើយ, ...ឱ្យសើមហើយ ។

**តេរស** ត.សំ. [ តិ+ទស>តេរស ] ១០លើសដោយ៣ (១៣); វិ. **តីហិ អធិកា ទស> តេរស** ។ . **ធុតង្គគុណមត្ត** គុ. ហេតុត្រឹមតែគុណគឺធុតង្គ១៣ ។ . **សង្ឃាទិសេសាបជ្ជន** នបុំ. កិ. ការត្រូវអាបត្តិឈ្មោះសង្ឃាទិសេស១៣ ។ . **ហត្ថាយាម** គុ. មានបណ្ដោយមានហត្ថ១៣ជាប្រមាណ, មានបណ្ដោយនៃហត្ថ១៣ ។

**តេរសម** បូ.សំ. [ តេរស+ម ] ទី១៣, គំរប់១៣ ។

**តេល** នបុំ. ប្រេង ។ . **តិលតណ្ឌុលសប្បិផាណិតាទិ** គុ. (វត្ថុ) មានប្រេង និងល្ង និងអង្ករ និងទឹកដោះថ្លា និងទឹកអំពៅជាដើម ។ . **នាឡិ** ឥ. នាឡិនៃប្រេង, នាឡិដាក់នូវប្រេង, នាឡិដ៏ពេញដោយប្រេង ។ . **បិលោតិកា** ឥ. សំពត់ចាស់ដែលជ្រលក់ដោយប្រេង, កំណាត់សំពត់ដែលបុគ្គលជ្រលក់ដោយប្រេង ។ . **បូរ** គុ. ដ៏ពេញដោយប្រេង ។ . **ផាណិតាទិពិន្ទុ** នបុំ. តំណក់នៃវត្ថុមានប្រេងនិងទឹកអំពៅជាដើម ។ . **ពិន្ទុ** នបុំ. តំណក់នៃប្រេង ។

**តេវិជ្ជ** គុ. [ តិ+វិជ្ជា ] អ្នកមានវិជ្ជា៣, អ្នកទ្រទ្រង់នូវវិជ្ជា៣; វិ. **តិស្សោ វិជ្ជា យស្ស សោ> តេវិជ្ជោ** ។

**តេវីសតិម** ប្ង.សំ. [ តេវីសតិ+ម ] ទី២៣, គំរប់២៣ ។

**តោមរ** បុំ. [ តុម+អរ, ម>ម ] (អាវុធ) ជាគ្រឿងដែលជនចាក់ (លំពែងស្នែងក្របី); វិ. **តុជ្ជតេ អនេនាតិ> តោមរោ** ។

**តោសេតិ** កិ. [ តុស+ណេ+តិ_វ. ] ឱ្យត្រេកអរ ។

**តោសេន្តុ** កិ. [ តុស+ណេ+អន្តុ_ប. ] ចូរឱ្យត្រេកអរ ។

**តោសេសិ** កិ. [ តុស+ណេ+ឦ_អជ្ជ.,ទុះស_ភ. ] ឱ្យត្រេកអរហើយ ។



**ថកន** នបុំ. [ ថក+យុ ] កិ.បិទ, កិ.ចុក ។

**ថកេត្វា** អ. [ ថក+ឯ+ត្វា ] បិទហើយ, ចុកហើយ ។

**ថញ្ញ** នបុំ. [ ថន+ណ្យ ] រសដែលកើតអំពីដោះ (ដោះ, ទឹកដោះ); វិ. **ថនតោ សម្ភូតំ> ថញ្ញំ** ។

**ថណ្ឌិលសាយិកា** ឥ. [ ថណ្ឌិល+សាយិក ] កិ.ដេកលើផែនដី ។

**ថទ្ធ** គុ. រឹង, រឹងថ្លឹង, រឹងរូស ។ _**ភាវ** បុំ. ភាវៈនៃហឫទ័យដ៏រឹងថ្លឹង, ភាវៈនៃ...ជាវត្ថុរឹង ។ _**មច្ឆរី** គុ. អ្នកមានសេចក្ដីកំណាញ់រឹងថ្លឹង, ស្វិតស្វាញ ។ _**សរីរ** គុ. មានសរីរៈដ៏រឹង ។ _**ហទយ** គុ. អ្នកមានហឫទ័យរឹងថ្លឹង ។

**ថន** នបុំ. [ តន+អ, ត>ថ ] ដោះ ។ _**បាន** នបុំ. កិ.បៅនូវដោះ ។ _**បាយី** បុំ. អ្នកបៅនូវដោះ, អ្នកមានកិ.បៅនូវដោះជាប្រក្រតី ។ **បាយី**<បា+ណី ។

**ថម្ភ** បុំ. [ ថម្ភ+អ ឬថរ+វត្ត ] សសរ ។

**ថរុមូល** នបុំ. [ ថរុ+មូល ] គល់នៃដង ។

**ថល** នបុំ. [ ថល+អ ] គោក, ទីគោក, ទួល ។ _**ដ្ឋាន** នបុំ. ទីគោក ។ _**និន្ន** គុ. ទាំងគោកទាំងទំនាប, ទីគោកនិងទីទំនាប ។ _**បថ_ជលបថាទិ** គុ. (ផ្លូវ) មានផ្លូវគោកនិងផ្លូវទឹកជាដើម, មានផ្លូវនៃគោកនិងផ្លូវនៃទឹកជាដើម ។

**ថវិកា** ឥ. ថង់ (ថង់យាម, ស្លោកបាត្រ) ។

**ថាម** ពុំ. [ ឋា+ម, ឋ>ថ ] កម្លាំង, កម្លាំងចិត្ត ។ ‑ **ពល** នបុំ. កម្លាំងចិត្តនិងកម្លាំងកាយ ។ ‑ **សម្បន្ន** គុ. ដល់ព្រមហើយដោយកម្លាំង, មានកម្លាំងដល់ព្រមហើយ ។

**ថាលិ** នបុំ. [ ថល+ណ ] ភាជនៈ, ថាស, ចាន, សៀន ។

**ថាលកមណ្ឌន** នបុំ. [ ថាលក+មណ្ឌន ] កិ.ប្រដាប់នូវភាជនៈ..., កិ.ញុំាងភាជនៈឱ្យថ្លាស្អាត ។

**ថាវរ** គុ. [ ឋា+វរ, ឋ>ថ ] សភាវៈតាំងនៅ (មាំ, តាំងមាំ, មាំមួន, ស្ថាពរ); វិ. **តិដ្ឋតីតិ> ថាវរោ** ។

**ថិរ** គុ. [ ឋា+ឥរ, ឋ>ថ ] (ធម្មជាតិ) រមែងប្រព្រឹត្តទៅ (មាំ, មាំមួន, ខ្ជាប់ខ្ជួន); វិ. **ឋាតិ បវត្តតីតិ> ថិរោ** ។ ‑ **ករ** គុ. ធ្វើឱ្យមាំ, គឺ...ធ្វើឱ្យមាំ ។ ‑ **ចេតស** គុ. អ្នកមានចិត្តមាំមួន ។ ‑ **តរ** គុ. មាំជាង, មាំវិសេស, ខ្ជាប់ខ្ជួនជាង ។ ‑ **តា** គុ. ភាវៈនៃ...ជាអ្នកមាំមួន ។ ‑ **ប្បត្តតា** ភាវៈនៃ...ជាអ្នកដល់ហើយនូវសេចក្ដីមាំមួន ។ ‑ **ភាវករណ** នបុំ. កិ.ឬជាគ្រឿងធ្វើនូវភាវៈនៃ...ឱ្យជាអ្នកមាំមួន ។

**ថីន** នបុំ. [ ថិន+អ, វិការៈឥ>ឦ ] សេចក្ដីរួញរា, សេចក្ដីរួញនៃចិត្ត, សេចក្ដីងងុយ; វិ. **ថិននំ ចិត្តស្ស សង្កោចនំ> ថីនំ** ។

**ថីនមិទ្ធ** នបុំ. [ ថីន+មិទ្ធ ] សេចក្ដីរួញរានិងសេចក្ដីរាយមាយ, សេចក្ដីរួញរានៃចិត្តនិងសេចក្ដីរាយមាយនៃចិត្ត, សេចក្ដីរួញរានិងសេចក្ដីងោកងក់ (មិទ្ធ<មិធ ឬមិហ+ត = សេចក្ដីរាយមាយ, សេចក្ដី



រាយមាយនៃចិត្ត, សេចក្ដីងោកងក់, ការដេកលក់; វិ. **មិទ្ធនំ ចិត្តស្ស សតិចហានំ> មិទ្ធំ**) ។

**ថីនមិទ្ធាភិភូត** គុ. [ ថីនមិទ្ធ+អភិភូត ] គឺថីនៈនិងមិទ្ធៈគ្របសង្កត់ហើយ, គឺសេចក្ដីរួញរានិងសេចក្ដីរាយមាយគ្របសង្កត់ហើយ (គឺការងងុយនិងការដេកលក់គ្របសង្កត់ហើយ) ។

**ថុណូបនីត** គុ. [ ថុណា+ឧបនីត ] គឺបុគ្គលនាំចូលទៅហើយកាន់សសរ, គឺបុគ្គលនាំចូលទៅហើយកាន់បង្គោល (ចងភ្ជាប់និងបង្គោលហើយសម្លាប់) ។

**ថុតិ** ឥ. [ ថុ+តិ ] សេចក្ដីសរសើរ, សេចក្ដីស្ញើច ។

**ថុតុំ** អ. [ ថុ+តុំ ] ដើម្បីសរសើរ ។

**ថុសរាសិ** ពុំ. [ ថុស+រាសិ ] គំនរនៃអង្កាម ។

**ថូល** គុ. ធាត់, ធំ, ថ្លោស, ក្រាស់, ក្រើម, ។ ‑ **កម្ពល** ពុំ. សំពត់កម្ពលមានសាច់ក្រាស់ ។ ‑ **ផុសិតក** គុ. មានតំណក់ដ៏ថ្លោស ។ ‑ **ផុសិត** គុ. (ភ្លៀង) មានតំណក់ដ៏ថ្លោស ។ ‑ **សរីរកាល** ពុំ. កាលនៃខ្លួនមានសរីរៈធាត់ ។ ‑ **សរីរ** គុ. មានសរីរៈធាត់, ‑ថ្លោស ។ ‑ **សាដកទានមត្ត** គុ. (ការបរិច្ចាគ) ត្រឹមតែកិ. ឱ្យនូវសំពត់សាដកមានសាច់ក្រាស់, ‑ដ៏គ្រោតគ្រាត ។ ‑ **សាដក** គុ. សាដកមានសាច់ក្រាស់, សាដកមានសាច់ដ៏គ្រោតគ្រាត ។

**ថេនេត្វា** អ. [ ថេន+ណេ+ត្វា ] លួចហើយ ។

**ថេយ្យាវហារាទិ** គុ. [ ថេយ្យាវហារ+អាទិ ] មានថេយ្យាវហារជា

ដើម ។

**ថេរករណ** នពុំ. [ ថេរ+ករ+យុ ] ជាគ្រឿងធ្វើនូវភាវៈនៃខ្លួនជាអ្នកនាំមុន, ជាគ្រឿងធ្វើនូវភាវៈនៃខ្លួនជាថេរៈ (ថេរអ្នកប្រកបដោយគុណមានសីលជាដើមដ៏នាំមុន (ព្រះថេរៈ); វ. **ថិរេហិ ធម្មេហិ សីលាទិគុណេហិ សមន្នាគតោ> ថេរោ**) ។

**ថេរនវាទិ** គុ. [ ថេរនវ+អាទិ ] (ភិក្ខុ) មានភិក្ខុជាថេរៈនិងភិក្ខុថ្មីជាដើម ។

**ថេរវិសប្បទីប** ពុំ. [ ថេរវិស+បទីប ] ជាប្រទីបក្នុងវង្សនៃព្រះថេរៈ, ដូចជាប្រទីបក្នុងវង្សនៃព្រះថេរៈ ។

**ថេរាសន** នពុំ. [ ថេរ+អាសន ] អាសនៈនៃព្រះថេរៈ ។

**ថេរី** ឥ. [ ថេរ+ឦ ] ថេរី, នាងថេរី ។

**ថេរុបដ្ឋាន** នពុំ. [ ថេរ+ឧបដ្ឋាន ] ទីជាទីបំរើនៃព្រះថេរៈ, ទីជាទីបំរើនូវព្រះថេរៈ, កិ.បំរើនូវព្រះថេរៈ ។ - **កាល** ពុំ. កាលជាទីបំរើនូវព្រះថេរៈ ។

**ថោកំ** កិ. វិ. តិច, បន្តិច, បន្តិចបន្តួច (ថុច+ណ) ។

**ថោកិក** គុ. [ ថោក+ណិក ] មានប្រមាណតិច ។

**ថោមេត្វា** អ. [ ថោម ឬថុច+ណេ+ត្វា ] សរសើរហើយ, ស្ញើចហើយ ។

**ថោមេន្ត** គុ. [ ថោម+ណេ+អន្ត ] កាលសរសើរ, កាលស្ញើច ។

**ថោមេន្តិ** កិ. [ ថោម+ណេ+អន្តិ_វ. ] សរសើរ, ស្ញើច ។



**ទករក្ខស** ពុំ. [ ទក+រក្ខ+ស ] យក្សជាជនរក្សានូវខ្លួនក្នុងទឹក (នៃជន) ឬបិសាចអ្នករក្សានូវទឹក (អារក្សទឹក, បិសាចឬខ្មោចទឹក); វ. **ឧទកេ រក្ខតិ អត្តានំ ឯតស្មាតិ> ឧទករក្ខសោ; ឧទកំ រក្ខតីតិ វា> ឧទករក្ខសោ** ។ - **កាល** ពុំ. កាលនៃ...ជាអារក្សទឹក, -ជាបិសាចអ្នករក្សានូវទឹក; -ជាខ្មោចទឹក ។

**ទក្ខិណ** គុ. ខាងស្តាំ, ខាងត្បូង ។ - **អំសកូដ** ពុំ. ចង្កូយនៃស្មាខាងស្តាំ ។ - **កណ្ណសោត** នពុំ. ប្រហោងនៃត្រចៀកខាងស្តាំ ។ - **អក្ខិ** នពុំ. ភ្នែកខាងស្តាំ ។ - **ចក្កវាឡមុខវដ្ដិ** ឥ. កណ្ដាប់នៃមាត់នៃចក្កវាឡក្នុងទិសខាងត្បូង ។ - **ទិសា** ឥ. ទក្ខិណទិស, ទិសខាងត្បូង ។ - **ទ្វារ** នពុំ. ទ្វារខាងត្បូង ។ - **នាសិកាសោត** នពុំ. ប្រហោងនៃច្រមុះខាងស្តាំ ។ - **បស្ស** នពុំ. ខាងខាងស្តាំ, ចំហៀងខាងស្តាំ ។ - **បាទតល** នពុំ. ផ្ទៃនៃជើងខាងស្តាំ ។ - **ភិត្តិ** ឥ. ជញ្ជាំងខាងត្បូង, ជញ្ជាំងក្នុងទិសខាងត្បូង ។ - **ហត្ថតល** នពុំ. ផ្ទៃនៃដៃខាងស្តាំ ។ - **ហត្ថ** ពុំ. ដៃខាងស្តាំ ។ - **ហត្ថបស្ស** នពុំ. ខាងនៃព្រះហស្តខាងស្តាំ, ចំហៀងនៃ... ។

**ទក្ខិណាបថ** ពុំ. [ ទក្ខិណា+អាបថ ] ជនបទឈ្មោះទក្ខិណាបថ ។

**ទក្ខិណុត្តរទ្វារ** នពុំ. [ ទក្ខិណ+ឧត្តរ+ទ្វារ ] ទ្វារខាងត្បូងនិងទ្វារខាងជើង, ទ្វារកើតក្នុងទិសខាងត្បូងនិងទ្វារមានក្នុងទិសខាងជើង ។

**ទក្ខិណេយ្យ** គុ. [ ទក្ខិណា+ណេយ្យ ] អ្នកគួរនូវទក្ខិណាទាន, អ្នកគួរ (ដើម្បីទទួល) នូវវត្ថុទានបាយជាដើម គឺបុគ្គលគប្បីឲ្យ (ទក្ខិណេយ្យបុគ្គល); វ. **ទាតព្វាតិ> ទក្ខិណា; តំ អរហតីតិ>**

ទក្ខិណេយ្យោ (ទក្ខិណា<មា+ក្ខិណា+អា.ឥ.) អ្នកគួរនូវទាន គឺបុគ្គលគប្បីជឿនូវផលនៃកម្មហើយឱ្យ; មួយទៀតអ្នកគួរនូវធម្មជាតិជាហេតុចំរើនដោយសម្បត្តិតាមបំណង (នៃសត្វ); វិ. កម្មផលំ សទ្ទហិត្វា ទាតព្វទានំ> ទក្ខិណា; ទក្ខិណំ ឧក្កាន្តិ សក្កា ឯកាយ យថាធិប្បេតាហិ សម្បត្តីហិតិ ទា> ទក្ខិណា; តំ អរហតីតិ> ទក្ខិណេយ្យោ (ទក្ខ+ឥណេ+អា.ឥ.) ។ . បុគ្គល ពុំ. បុគ្គលអ្នកគួរនូវទក្ខិណាទាន, បុគ្គលជាទក្ខិណេយ្យៈ,... ។ . សម្បទា ឥ. កិ.ដល់ព្រមដោយទក្ខិណេយ្យបុគ្គល, សម្បទាគឺទក្ខិណេយ្យបុគ្គល ។

ទក្ខិណោទក នពុំ. [ ទក្ខិណា+ឧទក ] ទឹកគឺបុគ្គលគប្បីឱ្យដើម្បីមានសម្បត្តិជាគ្រឿងចំរើន, ទឹកជាគ្រឿងចំរើន (ទឹកស្មោចក់); វិ. ទក្ខន្តិ ឯកាយាតិ> ទក្ខិណា; ទក្ខិណាយ ទាតព្វំ ឧទកំ> ទក្ខិណោទកំ ។ . ប្បតិដ្ឋាន នពុំ. កិ.ញុំាងទក្ខិណោទកឱ្យតាំងនៅចំពោះ, កិ.តាំងទុកចំពោះនូវទឹកស្មោចក់ ។

ទក្ខិស្សតិ កិ. [ ទិស>ទក្ខ+អ+ឥ.អា.+ស្សតិ.ភ. ] នឹងឃើញ ។

ទក្ខេម្មុ កិ. [ ទិស>ទក្ខ+អ+ឯយ្យាម.ស., ឯយ្យាម>ឯមុ ] គប្បីឃើញ ។

ទជ្ជា កិ. [ ទា>ទជ្ជ+អ+ឯយ្យ.ស. ] គប្បីឱ្យ; អ. ឱ្យហើយ (ទា+ត្វា>ទជ្ជា) ។

ទដ្ឋុកាម ត្រ. [ ទដ្ឋុំ+កម+ណ ] អ្នកចង់ដើម្បីឃើញ, អ្នកប្រាថ្នាដើម្បីឃើញ ។



ទដ្ឋុំ អ. [ ទិស+តុំ ] ដើម្បីឃើញ, ដើម្បីជួប ។

ទឌ្ឍ ត្រ. [ ទហ+ត ] គឺ... ភ្លើងឆេះហើយ ។ . កាល ពុំ. កាលនៃ... គឺភ្លើងឆេះហើយ ។

ទណ្ឌក ពុំ. [ ទណ្ឌ+ក.ស. ] កំណាត់ឈើ, ឈើច្រត់, ដំបង, ដង, បង្គង ។ . មធុបដល នពុំ. ធ្លិតនៃឃ្មុំទាំងបង្គង, ធ្លិតនៃឃ្មុំមួយអន្លើដោយបង្គង, សម្បុកនៃ... ។

ទណ្ឌ ពុំ. [ ទណ្ឌ+អ; ទម+ឌ; ទឌ+អ ] ពិន័យ, អាជ្ញា, ឈើច្រត់, ដំបង, ដង ។ . កម្ម នពុំ. ទណ្ឌកម្ម, កម្មគឺបុគ្គលគប្បីធ្វើដោយអាជ្ញា ។ . ករណាបីឡិត ត្រ. គឺ...បៀតបៀនហើយដោយកិ.ធ្វើនូវអាជ្ញា, គឺកិ.ធ្វើនូវអាជ្ញាបៀតបៀនហើយ ។ . កោដិ ឥ. ចុងនៃឈើច្រត់, ទីបំផុតនៃឈើច្រត់ ។ . តជ្ជិត ត្រ. អ្នកគឺអាជ្ញាគម្រាមហើយ, អ្នកគឺ...គម្រាមហើយដោយអាជ្ញា ។ . ទីបក នពុំ. ប្រទីបមានដង ។ . បរាយន ត្រ. អ្នកមានឈើច្រត់ជាទីប្រព្រឹត្តទៅក្នុងខាងមុខ ។ . ពលិអាណាទិ ត្រ. (កម្ម) មានកំណាត់ឈើនិងពលី (គ្រឿងបូជា) និងអាជ្ញាជាដើម ។ . វត្តវណ្ណនា ឥ. កថាជាគ្រឿងពណ៌នានូវទណ្ឌវត្ត ។ . ហត្ថគោបាលកសទិស ត្រ. ប្រាកដស្មើដោយបុគ្គលអ្នករក្សានូវគោមានដំបងក្នុងដៃ, ដូចជាបុរសអ្នកឃ្វាលនូវគោមានដំបងក្នុងដៃ ។

ទណ្ឌាភិហត ត្រ. [ ទណ្ឌ+អភិហត ] គឺដំបងបៀតបៀនចំពោះហើយ, គឺ...សំពងហើយដោយដំបង, គឺបុគ្គលគោះហើយដោយដំបង,

តី...បៀតបៀនចំពោះដោយដំបង ។

**ទត្ត** អ.ន. ឈ្មោះទត្តៈ ។

**ទត្វា** អ. [ ទា+ត្វា ] ឱ្យហើយ ។

**ទទតោ** គុ. [ ទទន្ត+ត.វិ., ផ្លាស់ន្ត+ត.វិ>តោ ] កាលឱ្យ ។

**ទទន្ត** គុ. [ ទា-ទា+អន្ត ] កាលឱ្យ, កំពុងឱ្យ ។

**ទទមាន** គុ. [ ទា-ទា+មាន ] កាលឱ្យ, កំពុងឱ្យ ។

**ទទាតិ** កិ. [ ទា-ទា+អ+តិ-វ. ] ឱ្យ, រមែងឱ្យ ។

**ទទាមិ** កិ. [ ទា-ទា+អ+មិ-វ. ] ឱ្យ ។

**ទទាម្ហសេ** កិ. [ ទា-ទា+អ+ម្ហសេ-ហី. ] ឱ្យ, ឱ្យហើយ ។

**ទទេយ្យ** កិ. [ ទា-ទា+អ+ឯយ្យ-ស. ] គប្បីឱ្យ, គួរឱ្យ, ត្រូវឱ្យ ។

**ទទេយ្យាសិ** កិ. [ ទា-ទា+អ+ឯយ្យាសិ-ស. ] គប្បីឱ្យ,... ។

**ទទេយ្យុំ** កិ. [ ទា-ទា+អ+ឯយ្យុំ-ស. ] គប្បីឱ្យ ។

